លេខ ១១
ឆ្នាំ២០២១

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



# បុព្វកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ស្នូលមួយ ក្នុងចំណោមកម្មវិធីកែទម្រង់ សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ចល្អ។ កម្ពុជានឹងកសាងបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយរឹងមាំ ដែលឈានទៅសម្រេចបានលទ្ធផលហិរញ្ញវត្ថុចុងក្រោយ (Fiscal Outcomes) ទាំង៣ នៃមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល រួមមាន (១) បូរណភាពនៃការគោរពវិន័យថវិកា, (២) ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ (៣) ស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ ។

នៅក្នុងបរិការណ៍ នៃឆ្នាំ២០២០, ពិភពលោកទាំងមូល បានឆ្លងកាត់នូវបទពិសោធ និងស្ថានភាពខុសពីការរំពឹងទុកដោយសារការរាតត្បាត នៃជំងឺកូវីដ-១៩ ហើយព្រះរាជាណាចក្រកម្ពុជា ក៏ពុំត្រូវបានលើកលែងផងដែរ ។ មានសំណួរជាច្រើនត្រូវបានចោទសួរថា តើកិច្ចការកែទម្រង់នានាអាចសម្រេចបានតាមគោលដៅដែលបានគ្រោងទុក ឬយ៉ាងណា? ខ្ញុំអាចសន្និដ្ឋានបានថា វិបត្តិនៃជំងឺកូវីដ-១៩ បានក្លាយជាវិញ្ញាសា ដើម្បីសាកល្បងភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ។ ឆ្លងកាត់ដំណាក់កាលដ៏លំបាកនៃឆ្នាំ ២០២០, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានៅរក្សាបានស្ថានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការធានាបានចីរភាព នៃការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងលទ្ធភាពវិភាជឡើងវិញនូវចំណាយក្នុងឆ្នាំ ឆ្លើយតបបានទៅនឹងកិច្ចការអាទិភាព ដែលកើតមានថ្មីៗ ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានា ក្នុងផ្នែកសេដ្ឋកិច្ច និងសង្គម ។ ជាមួយនឹងស្ថានភាពដែលអាចគ្រប់គ្រងបាន និងលទ្ធផលល្អប្រសើរកន្លងមកនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ បានផ្តល់ជាមូលដ្ឋានចម្បងឱ្យរាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពក្នុងការដោះស្រាយនូវវិបត្តិផ្នែកសុខាភិបាលជាយថាហេតុជូនប្រទេសជាតិ ក៏ដូចជាការសម្រាលជីវភាពប្រជាពលរដ្ឋក្រីក្រតាមរយៈការដាក់ចេញនូវវិធានការនានាជាច្រើន ក៏ដូចជាសម្របសម្រួល, បន្ធូរបន្ថយភាពតានតឹង និងលើកស្ទួយស្ថានភាពអាជីវកម្មជាពិសេស សហគ្រាសធុនតូច និងមធ្យម ឱ្យល្អប្រសើរក្នុងអភិក្រមប្រុងប្រយ័ត្នខ្ពស់ ។ ប្រការនេះបានបង្ហាញយ៉ាងច្បាស់លាស់ថា កិច្ចខិតខំប្រឹងប្រែងក្នុងការងារកែទម្រង់បានផ្តល់ផលវិជ្ជមាន ក្នុងការកសាងសមត្ថភាពនៃប្រព័ន្ធហិរញ្ញវត្ថុមួយឱ្យរឹងមាំ ដែលជា "ឧបករណ៍គោលនយោបាយ" បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា ។

ទោះបីជាយ៉ាងនេះក្តី, ប្រសិនបើប្រៀបធៀបទៅនឹងស្តង់ដារ និងឧត្តមានុវត្តជាអន្តរជាតិ, ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា នៅមានគម្លាតនៅឡើយ ហើយទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជាក៏ស្ថិតនៅលើវិថីវែងឆ្ងាយបន្តទៀត ក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន ដែលក្នុងនោះកាលានុវត្តភាព និងបញ្ហាប្រឈមនានា នឹងកើតមានឡើងជាបន្តបន្ទាប់ដែលចាំបាច់ទាមទារ ឱ្យបន្តយកចិត្តទុកដាក់កែលម្អ និងពង្រឹងបន្ថែមទៀត លើការងារកែទម្រង់ និងធ្វើអាទិភាវូបនីយកម្មលើសកម្មភាពសំខាន់ថ្មីៗទៀត ដើម្បីឆ្លើយតបជាមួយស្ថានភាពជាក់ស្តែង ព្រមទាំងការតម្រង់ឆ្ពោះទៅរកគណនេយ្យភាពសមិទ្ធកម្ម នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ។

សម្រាប់ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលេខ១១ សម្រាប់ឆ្នាំ២០២១ នេះ នឹងក្លាយជាឧបករណ៍ជំនួយស្មារតី និងផ្តល់តម្លៃបន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណជនដើម្បីបន្តលើកកម្ពស់ការយល់ដឹង ព្រមទាំងគាំទ្រដល់ទិសដៅ និងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា៕

ថ្ងៃពុធ ១៣ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ទោះបីជាស្ថានការណ៍នៃជំងឺកូវីដ-១៩ នៅបន្តរីករាលដាល និងបង្កឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាយ៉ាងណា ក៏ដោយតាមរយៈការអនុវត្តនូវគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាព និងចំគោលដៅ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការដឹកនាំចង្អុលបង្ហាញប្រកបដោយភាពឈ្លាសវៃរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ស្ថានភាពហិរញ្ញវត្ថុសាធារណៈកម្ពុជានៅមានលក្ខណៈប្រសើរ ឆ្លុះបញ្ចាំងតាមរយៈការធានាបានចីរភាពនៃការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងលទ្ធភាពវិភាជន៍ឡើងវិញនូវចំណាយក្នុងឆ្នាំឆ្លើយតបបានទៅនឹងអាទិភាព ដែលកើតមានថ្មីៗ ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានាក្នុងផ្នែកសេដ្ឋកិច្ច និងសង្គម។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃ ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP3) ឆ្នាំ២០១៦ ដល់២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដោយប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability-PFA) បានបង្ហាញឱ្យឃើញថាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាត្រូវ បានកែលម្អជាបណ្តើរ និងនៅមានការងារសេសសល់មួយចំនួន ដែលមានវឌ្ឍនភាព និងទិសដៅច្បាស់លាស់ស្របតាមបរិការណ៍កម្ពុជា និងស្តង់ដារជាឧត្តមានុវត្តអន្តរជាតិ ជាពិសេសក្នុងដំណាក់កាលលំបាកនៃវិបត្តិកូវីដ-១៩។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានសម្រេចបន្តអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP3) រយៈពេល២ ឆ្នាំទៀត (២០២១-២០២២) និងត្រូវបានឱ្យឈ្មោះជា “**ផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២ (CAP3+2) ឆ្នាំ២០២១-២០២២**” ក្នុងគោលបំណងសំខាន់ឆ្ពោះទៅកសាងនូវលក្ខខណ្ឌចាំបាច់ទាំងឡាយ ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង “**វប្បធម៌សមិទ្ធកម្ម**” ក្នុងក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូល។

ដើម្បីបន្តលើកកម្ពស់ការយល់ដឹង និងជំរុញការគាំទ្រដល់ទិសដៅ និងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) តែងតែធ្វើការបញ្ជ្រាបការយល់ដឹងថ្មីៗបន្ថែមពាក់ព័ន្ធនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាផ្សព្វផ្សាយនូវសមិទ្ធផលដែលសម្រេចបានជាបន្តបន្ទាប់ជូនដល់សាធារណជនតាមរយៈ កម្រងខ្សែវីដេអូ កាសែត វិទ្យុ ទូរទស្សន៍ ការបណ្តុះបណ្តាល សិក្ខាសាលា ព្រឹត្តិបត្រកម្មវិធីកែទម្រង់ និងឧបករណ៍ផ្សព្វផ្សាយផ្សេងៗទៀត។ តួយ៉ាង, សម្រាប់ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលេខ១១ នេះ នឹងចងក្រងនូវព្រឹត្តិការណ៍ថ្មីៗ សុន្ទរកថា និងទស្សនៈ មតិ របស់ថ្នាក់ដឹកនាំ ព្រមទាំងអត្ថបទពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានតម្លៃជាច្រើន ដែលអាចផ្តល់តម្លៃបន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណៈជន ដែលចង់ឈ្វេងយល់អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល៕

ថ្ងៃព្រហស្បតិ៍ ១កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២១

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

*ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - លេខ១១- ឆ្នាំ២០២១*


## ព្រឹត្តិការណ៍

**ទំព័រទី០១**
កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០

## អត្ថបទ

**ទំព័រទី០៥**
ខ្លឹមសារសង្ខេបនៃការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ ឆ្នាំ២០១៦-២០២០

**ទំព័រទី១១**
ការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២ ឆ្នាំ២០២១-២០២២ (CAP3+2)

**ទំព័រទី១៥**
កិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) និងសាលាលីក្វាន់យូ

**ទំព័រទី១៧**
បរិបទការងារថ្មីក្នុងអំឡុងពេលនៃវិបត្តិជំងឺរាតត្បាតផ្លូវដង្ហើម (កូវីដ-១៩)

**ទំព័រទី១៩**
គតិពិចារណាលើសុខដុមនីយកម្មនៃមុខងារសវនកម្ម និងអធិការកិច្ច : បទពិសោធប្រទេសកូរ៉េ

**ទំព័រទី២៣**
ទិដ្ឋភាពនៃតួនាទី ភារកិច្ច និងយន្តការស្ថាប័ននៃមុខងារសវនកម្ម និងអធិការកិច្ចក្នុងវិស័យសាធារណៈកម្ពុជា

**ទំព័រទី២៨**
បទពិសោធស្តីពីការអនុវត្តទំនាក់ទំនង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ទំព័រទី៣១**
ការដាក់ឱ្យអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទាំងស្រុងក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន

**ទំព័រទី៣៤**
ការទូទាត់តាមអេឡិចត្រូនិក(EFT) ពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទៅកាន់ប្រព័ន្ធធនាគារ របស់ធនាគារកាណាឌីយ៉ា

**ទំព័រទី៣៥**
ការប្រមូលចំណូលពន្ធដារ កាលានុវត្តភាព និងបញ្ហាប្រឈម ក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩

**ទំព័រទី៣៨**
ការប្រមូលចំណូលគយ កាលានុវត្តភាព និងបញ្ហាប្រឈម នៃរដ្ឋបាលគយ ក្នុងស្ថានភាពជំងឺរាតត្បាតកូវីដ-១៩

**ទំព័រទី៤០**
របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០ ស្តីពីការតាមដាន ការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ២០១៩-២០២៥

**ទំព័រទី៤៣**
ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា


## សុន្ទរកថា


**ទំព័រទី៤៥**
សុន្ទរកថា របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ទំព័រទី៤៩**
សុន្ទរកថា របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


## ទស្សនៈ និងមតិ


**ទំព័រទី៥៣**
ទស្សនៈ និងមតិ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ទំព័រទី៥៣**
ទស្សនៈ និងមតិ របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ទំព័រទី៥៤**
ទស្សនៈ និងមតិ របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**ទំព័រទី៥៤**
មតិរបស់ដៃគូអភិវឌ្ឍន៍ លើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០



# ផ្នែកទី ១

# ព្រឹត្តិការណ៍

# កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០

*នាព្រឹកថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ០៩:០០នាទី នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,* ***ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន*** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដឹកនាំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។*



*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ* ***អូន ព័ន្ធមុនីរ័ត្ន*** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីដេអូ នាព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១។*

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងតាមរយៈប្រព័ន្ធវីឌីអូដោយប្រើប្រាស់ប្រព័ន្ធ Intranet របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្តោតកិច្ចពិភាក្សាលើរបៀបវារៈចំនួន ២ ដូចខាងក្រោម÷

❶. *សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣*

❷. *សេចក្តីព្រាងផែនការសកម្មភាពរួមអន្តរកាល ដំណាក់កាលទី៣ បូក២។*

### ❶.សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣

ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាវិញ្ញាសាថ្មីមួយដែលបានតេស្តសាកល្បងនូវភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា។ កំណើនចំណូលជាងកន្លះទសវត្សរ៍ចុងក្រោយ និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយបានជួយជំរុញឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាមានភាពរឹងមាំ និងស៊ាំទៅនឹងវិបត្តិផ្សេងៗ។ ស្ថិតក្នុងបរិការណ៍នេះ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតែមានវឌ្ឍនភាព និងបន្តចលនាការដោយស្ថិតក្នុងស្ថានការណ៍ដែល



*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងកិច្ចប្រជុំ នាព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១។*

អាចគ្រប់គ្រងបាន និងសម្រេចបានលទ្ធផលគួរជាទីលើកទឹកចិត្ត។

*ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាវិញ្ញាសាថ្មីមួយដែលបានតេស្តសាកល្បងនូវភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា។ កំណើនចំណូលជាងកន្លះទសវត្សរ៍ចុងក្រោយ និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយបានជួយជំរុញឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាមានភាពរឹងមាំ និងស៊ាំទៅនឹងវិបត្តិផ្សេងៗ។*

ជាក់ស្តែង ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ច្បាប់ចំនួន៤ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យប្រើប្រាស់ ក្នុងនោះរួមមាន (១) ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, (២) ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម, (៣) ច្បាប់ស្តីពីមូលបត្ររដ្ឋ និង (៤) ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

លទ្ធផលនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២០ បានបង្ហាញថា៖

**ទី១. ភាពជឿទុកចិត្តនៃថវិកា** គឺរក្សាបាននូវភាពរឹងមាំ ដែលឆ្លុះបញ្ចាំងអំពីភាពធន់នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានកសាងកន្លងមក ខណៈមានផលប៉ះពាល់ដោយជំងឺកូវីដ-១៩, ការដកប្រព័ន្ធអនុគ្រោះពន្ធ EBA និងគ្រោះទឹកជំនន់នៅឆ្នាំ២០២០។ ក្នុងន័យនេះ ការពង្រឹងការគ្រប់គ្រង និងការអនុវត្តផែនការប្រមូលចំណូលត្រូវធ្វើពិពិធកម្មចំណូលថ្មី និងកៀរគរចំណូលឱ្យអស់សក្តានុពល ជាពិសេសវិស័យទូរគមនាគមន៍ និងវិស័យរ៉ែ និងប្រេងកាត។ ចំពោះប្រសិទ្ធភាពចំណាយថវិកានឹងត្រូវពង្រឹងលើបៀវត្ស, ទំនិញ/សេវា និងវិនិយោគតាមរយៈការរៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដូចមានកំណត់ក្នុងផែនការយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគ



*កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២០ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូ។*

សាធារណៈ ២០១៩-២០២៥។

**ទី២. គណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបានពង្រឹងតាមរយៈការពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) នៅគ្រប់ក្រសួង-ស្ថាប័ន, រតនាគាររាជធានី-ខេត្ត ទាំង២៥ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញ-វត្ថុ រាជធានី-ខេត្ត ទាំង២៥ និងការធ្វើស្វ័យ-ប្រវត្តិកម្មចំណាយ ដែលមានហានិភ័យកម្រិតទាប។ ការធ្វើសន្ធានកម្មរវាង FMIS និង ប្រព័ន្ធទិន្នន័យពន្ធដារ, រវាង FMIS និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ព្រមទាំងរវាងប្រព័ន្ធទិន្នន័យពន្ធដារ និងប្រព័ន្ធអាស៊ីគូដា ដែលត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការដោយជោគជ័យ។ បន្ថែមពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅតាមក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដទៃទៀត។

**ទី៣. ការផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយ** ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលខេត្តចំនួន២៤ ដែលរដ្ឋបាលរាជធានីភ្នំពេញនឹងត្រូវដាក់ឱ្យអនុវត្តនៅឆ្នាំ២០២១នេះ។

**ទី៤. ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញ-វត្ថុសាធារណៈ (ថ្មី), កែសម្រួលអនុក្រឹត្យលេខ៨១ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានី-ភ្នំពេញ និងអង្គការសាធារណៈ និងអនុក្រឹត្យលេខ៨២ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ និងលិខិតបទដ្ឋានគតិយុត្ត



*ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២០។*

ពាក់ព័ន្ធដែលជាមូលដ្ឋានចាំបាច់នឹងត្រូវរៀបចំបញ្ចប់នៅក្នុងឆ្នាំ២០២១។

ជារួម ឆ្លងកាត់ដំណាក់កាលលំបាកនៃឆ្នាំ២០២០, ស្ថានភាពហិរញ្ញវត្ថុសាធារណៈកម្ពុជានៅមានលក្ខណៈប្រសើរ ឆ្លុះបញ្ចាំងតាមរយៈការធានាបាននូវចីរភាពនៃការ

## ការខាតសេសសល់នៃដំណាក់កាលទី៣

### ផ្នែកទី ១

- មិនមានពិពិធកម្មចំណូលថវិកាប្រកបដោយចីរភាព
- ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅមិនទាន់អនុម័ត
- យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា ដើម្បីឈានទៅបោះផ្សាយមូលបត្ររដ្ឋ នៅមិនទាន់ត្រូវបានរៀបចំបញ្ចប់
- ការកំណត់និយមន័យចំណាយកកស្ទះ
- ការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័ន បន្តមានភាពមមាញឹកនៅចុងត្រីមាសទី ៤ នៃឆ្នាំ និងពន្យារពេលការអនុវត្តនៅត្រីមាសទី ១ ។

### ផ្នែកទី ២

- ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមិនទាន់បានដាក់ឱ្យអនុវត្តពេញលេញតាមក្រសួង ស្ថាប័ន
- ការរៀបចំរបាយការណ៍អនុវត្តថវិកាតាមចំណាត់ថ្នាក់ថវិកាទាំង ៧ នៅមានកម្រិត (៥ ចំណាត់ថ្នាក់បានអនុវត្តពេញលេញនិង ២ ចំណាត់ថ្នាក់នៅមានកម្រិត)
- FMIS នៅមិនទាន់អាចប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍សម្រេចទូទាត់បាន
- គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅពុំទាន់បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្នែកតាមមាតិកាថវិកា ។

ប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងលទ្ធភាពវិភាជន៍ចំណាយឡើងវិញក្នុងឆ្នាំ ឆ្លើយតបបានទៅនឹងអាទិភាពចលិតដែលកើតមានថ្មីៗ ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានា ក្នុងផ្នែកសេដ្ឋកិច្ច និងសង្គម។ ប្រការនេះបានឆ្លុះបង្ហាញយ៉ាងច្បាស់លាស់ថា កិច្ចខិតខំប្រឹងប្រែងក្នុងការងារកែទម្រង់បានផ្តល់ផលវិជ្ជមានក្នុងការកសាងប្រព័ន្ធហិរញ្ញវត្ថុមួយ ដែលជា “ឧបករណ៍គោលនយោបាយ” បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា។

## ❷.សេចក្តីព្រាងផែនការសកម្មភាពរួម-អន្តរកាល ដំណាក់កាលទី៣ បូក២

ផ្អែកលើការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ រាជរដ្ឋាភិបាលបានសម្រេចបន្តអនុវត្តរយៈពេល ២ ឆ្នាំទៀត (ឆ្នាំ២០២១-២០២២) ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំង៣ ខាងដើម មុននឹងឈានទៅអនុវត្តខឿនទី៤ “**គណនេយ្យភាពសមិទ្ធកម្ម**”។

ដំណាក់កាលអន្តរកាលឆ្ពោះទៅខឿនទី៤ មានគោលដៅសំខាន់ក្នុងការកសាង នូវលក្ខខណ្ឌចាំបាច់នានា ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង “**វប្បធម៌សមិទ្ធកម្ម**” ក្នុងក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ជាលទ្ធផល អង្គប្រជុំបានសម្រេចអនុម័តទៅលើសេចក្តីព្រាងផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២ និងចាប់ផ្តើមដាក់ឱ្យអនុវត្តបន្ទាប់ពីកិច្ចប្រជុំនាថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ នេះតទៅ។

*ដំណាក់កាលអន្តរកាលឆ្ពោះទៅខឿនទី៤ មានគោលដៅសំខាន់ក្នុងការកសាង នូវលក្ខខណ្ឌចាំបាច់នានា ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង "**វប្បធម៌សមិទ្ធកម្ម**" ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។*

ជាចុងក្រោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ណែនាំ ដល់សមាជិកគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមការងារកែទម្រង់នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបន្តកិច្ចសហការល្អ និងយកស្មារតីនៃកិច្ចប្រជុំនាថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ នេះ ដើម្បីបន្តជំរុញការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានវឌ្ឍនភាពតាមការរំពឹងទុក។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះគ្រប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងសម្រេចបានការងារនាពេលកន្លងមក ព្រមទាំងជូនពរគ្រប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ជួបប្រទះតែនឹងពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕■

### ផ្នែកទី ៣

- យន្តការតាមដាន និងការវាយតម្លៃលើការអនុវត្តថវិកាកម្មវិធីនៅមិនទាន់បានពង្រឹង
- អង្គភាពថវិកាថ្នាក់កណ្តាលចំនួន ៣០៨ ក្នុងនោះ មានត្រឹមចំនួន ៦០ ជាអាណាប័កផ្ទេរសិទ្ធិ
- គុណភាពនៃសូចនាករគន្លឹះ ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មិនទាន់ល្អ
- ការផ្សារភ្ជាប់រវាងរចនាសម្ព័ន្ធកម្មវិធី និងស្ថាប័ន នៅមានកម្រិត
- ការធ្វើសមាហរណកម្មថវិកាវិនិយោគទៅក្នុងកម្មវិធី ទើបបានសាកល្បងអនុវត្ត
- ការពន្យារពេលក្នុងការដាក់ឱ្យអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ
- ការកំណត់នូវគណនេយ្យភាពរវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ, រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន នៅមិនទាន់ច្បាស់លាស់នៅឡើយ ។

### ផ្នែកទី ៤

- ការរៀបចំច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យពាក់ព័ន្ធសម្រាប់ការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មមានការពន្យារពេល
- ការរៀបចំក្របខណ្ឌសម្រាប់អនុវត្ត និងត្រួតពិនិត្យថវិកាព័ត៌មានសមិទ្ធកម្មនៅមិនទាន់សម្រេចបានតាមផែនការដែលបានកំណត់
- ការកំណត់នូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្ទៃក្រៅ នៅពុំទាន់រលូន ឆ្ពោះទៅរកការធានានូវគណនេយ្យភាពសមិទ្ធកម្ម
- វគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានរៀបចំឡើង ក៏ប៉ុន្តែការតាមដាន និងវាយតម្លៃពីប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាលនៅជាចំណោទ
- ការកសាងសមត្ថភាពសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ ក៏មិនទាន់ត្រូវបានអនុវត្តតាមការគ្រោង
- ផែនការកសាងសមត្ថភាពត្រូវបានរៀបចំរួច ប៉ុន្តែការអនុវត្តនៅតែបញ្ហាព្រួយបារម្ភ ជាពិសេសការបណ្តុះបណ្តាលកាតព្វកិច្ចតម្រង់ឆ្ពោះទៅកាន់ប្រព័ន្ធថវិកាសមិទ្ធកម្ម ។

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*



# ផ្នែកទី ២

# អត្ថបទ

# ខ្លឹមសារសង្ខេបនៃការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់-កាលទី៣ ឆ្នាំ២០១៦-២០២០

*ការកែទម្រង់ក្នុងដំណាក់កាលទី៣ ផ្តោតជាចម្បងលើការបញ្ចប់ការអនុវត្តថវិកាកម្មវិធី និងការកសាងមូលដ្ឋានចាំបាច់សម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម ទន្ទឹមនឹងការបន្តពង្រឹងខឿនទី១ និងពង្រីកការអនុវត្តខឿនទី២។*

តាមការវាយតម្លៃអំពីការអនុវត្តនៃដំណាក់កាលទី៣ នេះបានបង្ហាញថាខឿនទី១ ស្តីពីការបង្កើនភាពជឿទុកចិត្តនៃថវិការក្សាបាននូវភាពរឹងមាំ, ខឿនទី២ ស្តីពីការពង្រឹង និងពង្រីកគណនេយ្យភាពហិរញ្ញវត្ថុបន្តមានវឌ្ឍនភាពល្អ, ខឿនទី៣ ស្តីពីការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយបានសម្រេចជាសារវន្ត, និងខឿនទី៤ ស្តីពីការត្រៀមខ្លួនឆ្ពោះទៅកាន់គណនេយ្យភាពសមិទ្ធកម្ម នៅមិនទាន់សម្រេចបានតាមការគ្រោងទុកនៅឡើយ។

***ការបន្តរក្សាបាននូវខឿនទី១ ភាពជឿទុកចិត្តនៃថវិកា÷*** ខឿននេះ ស្ថិតនៅផ្នែកទី១ ដែលមានគោលបំណងចំនួន៤ រួមមាន *(១). ការកៀរគរចំណូល, (២). ការគ្រប់គ្រងចំណូល, (៣). ការគ្រប់គ្រងបំណុលសាធារណៈ, និង (៤). ការកែលម្អការអនុវត្តថវិកា។* ជាលទ្ធផល ការពង្រឹង និងគ្រប់គ្រងចំណូលមានស្ថានភាពល្អប្រសើរ និងបង្កើតឱ្យមានអតិរេកថវិកាចរន្ត។ ការអនុវត្តចំណាយ ត្រូវបានបន្តការកែលម្អគួរឱ្យកត់សម្គាល់ និងស្ថិតក្នុងទិសដៅកំណត់ (+/-៥% ធៀបនឹងកម្មវិធីចំណូលចំណាយ)។ ការកៀរគរចំណូលប្រចាំឆ្នាំសម្រេចបានយ៉ាងហោចណាស់ ០,៣% នៃ ផ.ស.ស. និងចំណាយកកស្ទះស្ថិតនៅតិចជាង២% នៃចំណាយសរុប។ រីឯបំណុលសាធារណៈគឺស្ថិតក្នុងស្ថានភាពអាចគ្រប់គ្រងបាន។ សមិទ្ធផល នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីខឿនទី១ រហូតមកដល់ខឿនទី៣ បានផ្តល់ផ្លែផ្កា និងឆ្លុះបញ្ចាំងថាការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានភាពប្រសើរឡើងជាលំដាប់ តួយ៉ាងការគ្រប់គ្រង និងការប្រមូលចំណូលមានស្ថានភាពរឹងមាំ ដែលចំណូលកើនឡើងក្នុងចន្លោះពី១៥% ទៅ២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល៧ ឆ្នាំចុងក្រោយ ហើយចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ ១៥,០៦% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ដល់២៥,១២% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៩ ពោលគឺទំហំកើនឡើង ៣ ដង ឬ ប្រមាណជា ១០,៦ ពិន្ទុភាគរយនៃ ផ.ស.ស.។ ក្នុងផ្នែកភាពជឿទុកចិត្តបាននៃថវិកា, រាជរដ្ឋាភិបាលសម្រេចបានការបើកប្រាក់បៀវត្សពីរដងក្នុងមួយខែ ដោយគ្មានរអាក់រអួល។ លើសពីនេះ ការគ្រប់គ្រងសាច់ប្រាក់ល្អបានបង្កលទ្ធភាពឱ្យរាជរដ្ឋាភិបាលកម្ពុជាអាចឆ្លើយតបនឹងការវិវត្តន៍នៃស្ថានការថ្មីៗចំពោះមុខបានយ៉ាងល្អប្រសើរ។

***ការបន្តពង្រឹង និងពង្រីកខឿនទី២ គឺគណនេយ្យភាពហិរញ្ញវត្ថុ÷*** ខឿននេះស្ថិតនៅផ្នែកទី២ មានគោលបំណង៥ រួមមាន *(១). ចំណាត់ថ្នាក់ថវិកា, (២). ការអនុវត្តប្រព័ន្ធ FMIS, (៣). ស្តង់ដារគណនេយ្យសាធារណៈ, (៤). ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, និង (៥). សន្ទស្សន៍នៃការបើកចំហរព័ត៌មានថវិកា។* ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់

> *ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុថ្មី ដែលកំពុងត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម និងអនុក្រឹត្យពាក់ព័ន្ធគឺជាគតិយុត្តដ៏សំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី។ គិតត្រឹមឆ្នាំ២០១៨ គ្រប់ក្រសួង-ស្ថាប័ន បានអនុវត្តថវិកាកម្មវិធី និងឆ្នាំ២០២០ រដ្ឋបាលខេត្តចំនួន២៣ បានអនុវត្តថវិកាកម្មវិធី*

ថវិកា ប្លង់គណនេយ្យ និងដំណើរការប្រព័ន្ធ FMIS ទាំងដំណាក់កាលទី១ និងដំណាក់-កាលទី២ ដើម្បីជាមូលដ្ឋាននៃការកត់ត្រា និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រកបដោយត្រឹមត្រូវ និងទាន់ពេលវេលា មានវឌ្ឍនភាពល្អប្រសើរ និងស្របតាមស្តង់ដារអន្តរជាតិ។ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋត្រូវបានរៀបចំ, យ៉ាងណាមិញការអនុវត្តប្រព័ន្ធនេះ ត្រូវបន្តជំរុញបន្ថែមលើការដាក់ឱ្យអនុវត្តពេញលេញនៅតាមក្រសួង-ស្ថាប័នស្របគ្នានឹងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងប្រព័ន្ធនេះ។ ចំណាត់ថ្នាក់ថវិកាទាំង៧ ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងប្រព័ន្ធ FMIS ក៏ប៉ុន្តែអនុវត្តបានពេញលេញតែ៥ ចំណាត់ថ្នាក់ថវិកា រីឯចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់ថ្នាក់មុខងារត្រូវបានកំពុងបន្តជំរុញការអនុវត្ត។ ស្តង់ដារគណនេយ្យហិរញ្ញវត្ថុសាធារណៈកម្ពុជាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាមួយនឹងផែនទីបង្ហាញផ្លូវសម្រាប់ឆ្ពោះ




ទៅគណនេយ្យបង្គរ។ ការរៀបចំវេទិកាសាធារណៈស្តីពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌគ្រប់គ្រងថវិកាប្រចាំឆ្នាំ និងការផ្សព្វផ្សាយឯកសារពាក់ព័ន្ធព័ត៌មានថវិកាជូនសាធារណជន មានវឌ្ឍនភាពល្អឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលបានធ្វើឱ្យសន្ទស្សន៍នៃការបើកចំហរថវិការបស់កម្ពុជាមានការកើនឡើងជាលំដាប់នៅក្នុងការអង្កេតលើការបើកចំហរព័ត៌មានថវិកាជាសកលដែលបានរៀបចំឡើងរៀងរាល់២ឆ្នាំម្តង។

***ការបន្តខឿនទី៣ នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ÷*** ខឿននេះ ស្ថិតនៅផ្នែកទី៣ មានគោលបំណងចំនួន៤ រួមមាន(១). ការអនុវត្តថវិកាកម្មវិធី, (២). ការរៀបចំថវិកាឱ្យមានភាពគ្រប់ជ្រុងជ្រោយ, (៣). ការរៀបចំក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម, និង (៤). ការរៀបចំក្របខណ្ឌវិមជ្ឈការហិរញ្ញវត្ថុ។ លិខិតបទដ្ឋានគតិយុត្ត និងយុទ្ធសាស្ត្រគន្លឹះៗ ជាច្រើនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងដំណាក់កាលទី៣ ដើម្បីពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុថ្មី ដែលកំពុងត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នកម្ម និងអនុក្រឹត្យពាក់ព័ន្ធគឺជាគតិយុត្តដ៏សំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី។ គិតត្រឹមឆ្នាំ២០១៨ គ្រប់ក្រសួង-ស្ថាប័ន បានចូលអនុវត្តថវិកាកម្មវិធី និងឆ្នាំ២០២០ រដ្ឋបាលខេត្តចំនួន២៣ បានអនុវត្តថវិកាកម្មវិធី ប៉ុន្តែយន្តការតាមដានវាយតម្លៃលើការអនុវត្តនៅមិនទាន់បានពង្រឹង។ ទន្ទឹមនឹងនេះ, ទោះបីជានៅមានបញ្ហាគុណភាពក្តី ថវិកាកម្មវិធីនឹងក្លាយជាមូលដ្ឋានប្រមូលផ្តុំមុខសញ្ញាថវិកា។ សរុបត្រឹមដំណាក់កាលទី៣ អង្គភាពថវិកាមានចំនួន៩១៤ ក្នុងនោះនៅថ្នាក់កណ្តាលមានចំនួន៣១១ ដោយអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមានចំនួន៦១ និងមិនទាន់ផ្ទេរសិទ្ធិមានចំនួន២៥០ ព្រមទាំងថ្នាក់មូលដ្ឋានមានចំនួន៦០៣ ផ្ទេរសិទ្ធិទាំងអស់។ ក្នុងទិដ្ឋភាពចំណាយ, ទំហំថវិកា ៩ ៤៣៧ ៧២៩ លានរៀលក្នុងឆ្នាំ២០១៣ កើនឡើងដល់ទំហំ ២១ ៧៦៨ ៦១៤ លានរៀលនៅឆ្នាំ២០១៩ (តួលេខមានកំណត់ក្នុងច្បាប់ថវិកា) ឬត្រូវបានកើនឡើងលើស២,២ ដង ហើយត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ ក្នុងនោះចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើនជាង៣,៤ ដង, ក្រសួងសុខាភិបាលត្រូវបានបង្កើន ២,១ ដង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើន២,៦ ដង។ ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាលមានលទ្ធភាពក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិ ព្រមទាំងគិតគូរទៅដល់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់មន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ, និវត្តជន, អ្នកបាត់បង់សម្បទាវិជ្ជាជីវៈ និងអតីតយុទ្ធជន មន្ត្រីជាប់កិច្ចសន្យា សមាជិកក្រុមប្រឹក្សារាជធានីខេត្តក្រុងស្រុកខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ តាមរយៈការដំឡើងបៀវត្សជារៀងរាល់ឆ្នាំ ព្រមទាំងធ្វើឱ្យកម្រិតបៀវត្សមន្ត្រីរាជការទាបបំផុតនៅឆ្នាំ២០១៨ មានចំនួនជាងមួយលានរៀល និងនៅឆ្នាំ២០២៣ មានចំនួនមួយលាន-បួនសែនរៀល ដោយឡែកសម្រាប់បៀវត្សទាបបំផុតរបស់មន្ត្រីរាជការ និងគ្រូបង្រៀនក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល មានចំនួនជាងមួយលានមួយសែនរៀលនៅឆ្នាំ

២០១៨ និងមួយលានប្រាំសែនរៀលនៅឆ្នាំ២០២៣។ នៅក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ អាទិភាពដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាលក្នុងចំណោមអាទិភាពសំខាន់ៗក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម គឺការបន្តផ្តោតការយកចិត្តទុកដាក់ដល់ការលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការគ្រប់ប្រភេទ ឱ្យកាន់តែប្រសើរឡើងជាលំដាប់ថែមទៀត។

ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំតាមគោលបំណងគោលនយោបាយ និងកម្មវិធី ដោយធ្វើការពន្យល់ពីខ្លឹមសារនៃគោលបំណង សនិទានកម្ម ប្រភេទហិរញ្ញប្បទាន សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផលគោលដៅសមិទ្ធកម្ម ក្របខណ្ឌពេលវេលាព្រមទាំងតម្រូវការថវិកា ជាពិសេសត្រូវផ្អែកលើពិតានចំណាយ ដែលមានកំណត់នៅក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌថវិការយៈពេលមធ្យម ក៏ប៉ុន្តែគុណភាពនៃការរៀបចំត្រូវបានបន្តកែលម្អ។ ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ទទួលបានលទ្ធផលល្អប្រសើរ ប៉ុន្តែការអនុវត្តត្រូវបានរៀបចំឡើងមួយឆ្នាំម្តងៗ ជាដំណាក់ៗដោយមិនមានយុទ្ធសាស្ត្រ និងមិនមានការកំណត់ទិសដៅរយៈពេលមធ្យម និងរយៈពេលវែង។ ទោះបីជាយ៉ាងនេះក្តី ការរៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ គឺជាផែនទីចង្អុលផ្លូវនៃការពង្រឹងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។

***ការកំណត់ច្បាស់លាស់អំពីទិសដៅ និងការត្រៀមខ្លួនសម្រាប់ខឿនទី៤ គណនេយ្យភាពសមិទ្ធកម្ម÷*** *ខឿននេះស្ថិតនៅផ្នែកទី៤ មានគោលបំណងចំនួន៤ គឺ(១). ក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម, (២). ក្របខណ្ឌតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម, (៣). ក្របខណ្ឌសវនកម្មពេញលេញ (រួមមាន សមិទ្ធកម្ម ព័ត៌មានវិទ្យា អនុលោមភាព និងហិរញ្ញវត្ថុ) និង (៤). ផែនការយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤។* វឌ្ឍនភាពនៃផ្នែកទី៤ នេះ បង្ហាញនូវភាពមិនទាន់ច្បាស់លាស់ក្នុងរយៈពេលពីរឆ្នាំដំបូង ប៉ុន្តែវឌ្ឍនភាពបានបង្ហាញយ៉ាងច្បាស់លាស់វិញបន្ទាប់ពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ត្រូវបានរៀបចំ និងជ្រើសរើសយកប្រព័ន្ធ "ថវិកាព័ត៌មានសមិទ្ធកម្ម" ជាទិសដៅជាក់លាក់ នៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា។ ការងារពង្រឹងមុខងារសវនកម្ម គោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្មទាំងសវនកម្មផ្ទៃក្រៅ និងសវនកម្មផ្ទៃក្នុង ព្រមទាំងគោលការណ៍ណែនាំសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ចំពោះក្របខណ្ឌព័ត៌មានថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំជាគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។ ដោយឡែកទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម ព្រមទាំងក្របខណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម ត្រូវបានរៀបចំជាសេចក្តីព្រាង។ ផែនការយុទ្ធសាស្ត្រកសាងសមត្ថភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដើម្បីរៀបចំធនធានមនុស្ស និងស្ថាប័ន ក្នុងការគាំទ្រដល់ការប្រែប្រួល នៃការអនុវត្តការងារពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ។

សម្រាប់ការត្រៀមជំហានបន្ទាប់ រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បានបន្តផ្តោតលើគោលដៅអាទិភាព នៃកម្មវិធី



កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤។ បន្ទាប់ពីបានដាក់ឱ្យអនុវត្តនូវ **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥»** និងផែនការសកម្មភាពលម្អិត នៃយុទ្ធសាស្ត្រនេះ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្ត **«យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣» «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ២០១៩-២០២៥» «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម-ជាតិឆ្នាំ២០១៩-២០២៥»** និង **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥»** រួមជាមួយនឹងផែនការសកម្មភាពលម្អិតយុទ្ធសាស្ត្រនីមួយៗ។

***ការថែរក្សានូវចលនា នៃការកែទម្រង់ដើម្បីជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយជោគជ័យ និងចីរភាព÷*** *ការសម្របសម្រួលការងារកែទម្រង់ស្ថិតនៅក្នុងផ្នែកទី៥ មានគោលបំណងចំនួន៥ រួមមាន (១). ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង ឆន្ទៈ ភាពជាម្ចាស់ និងការទទួលខុសត្រូវសមស្របនឹងកម្មវិធីកែទម្រង់ (២). ការបណ្តុះបណ្តាលសមស្របប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព (៣). ការផ្តល់ការលើកទឹកចិត្តសមស្រប និងប្រកបដោយផលិតភាពស័ក្តិសិទ្ធភាព និងប្រសិទ្ធិភាព (៤). គ្រប់ក្រសួង-ស្ថាប័ន មានសមត្ថភាពសមស្របសម្រាប់ចូលរួមការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធិភាព (៥). យន្តការ នីតិវិធី នៃការអនុវត្តការងារកែ-ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង-ស្ថាប័ន ត្រូវបានអនុវត្ត។* ជាលទ្ធផលការវាយតម្លៃផ្នែកទី៥ នេះ ទទួលបានលទ្ធផលល្អ ដោយសារការរៀបចំជាប្រចាំនូវការតាមដានការងារកែទម្រង់ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងមានការចូលរួមពីគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នចំនួន៤២។ ទន្ទឹមនឹងនេះ មូលនិធិសម្រាប់កែទម្រង់ហិរញ្ញវត្ថុត្រូវបានបង្កើតក្នុងឆ្នាំ២០១៨ ដើម្បីធានាថាមានធនធានគ្រប់គ្រាន់សម្រាប់ធ្វើការងារកែទម្រង់ ទន្ទឹមនឹងការត្រួតពិនិត្យយន្តការលើកចិត្តដោយផ្អែកលើសមិទ្ធកម្មការងារ។ អគ្គលេខា-ធិការដ្ឋានគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានសហការ និងសម្របសម្រួលឱ្យកាន់តែជិតស្និតជាមួយនឹងលេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ផ្សេងទៀតរួមមាន ការកែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈ ការកែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌តាមរយៈការរៀបចំកិច្ចប្រជុំពិនិត្យមើលវឌ្ឍនភាពរួមគ្នា និងឈានទៅកំណត់ក្រប-ខណ្ឌនៃការងារកែទម្រង់បីបូកមួយឱ្យមានភាពប្រទាក់ក្រឡាគ្នា។




ទន្ទឹមនឹងវឌ្ឍនភាពសម្រេចបានខាងលើ ការអនុវត្តផែនការសកម្មភាពរួម ដំណាក់-កាលទី៣ នៅមានការងារសេសសល់មួយចំនួន ដែលសម្រេចបានខ្លះ និងមិនពេញលេញ។ ចំពោះវឌ្ឍនភាពសម្រេចបានកន្លងមកក៏នៅមានមូលដ្ឋាន សម្រាប់កែលម្អបន្ថែមទៀតដែរ។ ការងារសេសសល់នៅតាមផ្នែកនីមួយៗ មានដូចខាងក្រោម÷

**ផ្នែកភាពជឿទុកចិត្តនៃថវិកា** នៅមានបញ្ហាមួយចំនួនដែលត្រូវបន្តយកចិត្តទុក-ដាក់ក្នុងនោះ ការប្រមូលចំណូលដែលមិនទាន់មានពិពិធភាព និងចីរភាព ការប្រមូល

ផ្ទុំគណនេយ្យភាពថវិកា និងគណនីទោលរតនាគារជាតិមិនទាន់ពេញលេញ រួមទាំងនិយមន័យ នៃចំណាយកកស្ទះមានរយៈពេលវែង (លើសពី ៦០ ថ្ងៃ)។ ការអនុវត្តនីតិចំណាយ នៅមាននីតិវិធីវែងអន្លាយទាំងនៅក្នុងក្របខណ្ឌក្រសួង-ស្ថាប័ន និងទាំងនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ប្រព័ន្ធលទ្ធកម្មសាធារណៈ និងការគ្រប់គ្រងវិនិយោគសាធារណៈ ទើបត្រូវបានចាប់ផ្តើមតាមរយៈការរៀបចំជាយុទ្ធសាស្ត្រនៃការកែទម្រង់សម្រាប់កិច្ចការទាំងពីរនេះ និងបានបោះជំហានទៅមុខដោយសន្សឹមៗ។

**ផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ** នៅមានការងារដែលមិនទាន់បញ្ចប់បានទាំងស្រុង រួមមាន ការអនុវត្តចំណាត់ថ្នាក់នៃមាតិកាថវិកាមិនទាន់បានពេញលេញទាំងស្រុង ការផលិតរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំក្នុងរយៈពេលលើសពី៩ ខែ ក្រោយបញ្ចប់ការិយបរិច្ឆេទ និងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមិនទាន់អាចដំណើរការបានរលូននៅឡើយ។ ទន្ទឹមនឹងនេះមានការងារផ្សេងៗទៀតដែលអាចធ្វើឱ្យប៉ះពាល់ដល់គណនេយ្យភាពហិរញ្ញវត្ថុជារួមមានដូចជានីតិវិធីនៃការស្នើសុំចំណាយ និងទូទាត់នៅវែង និងមានច្រើនជំហាន ទោះបីជាមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្តី ដំណើរការនៃនីតិវិធីលទ្ធកម្មមានភាពយឺតយ៉ាវ ហើយពុំមានវិធានការសម្រាប់លើកទឹកចិត្តឱ្យមានគណនេយ្យភាពផ្នែកហិរញ្ញវត្ថុ ព្រមទាំងការអនុវត្តនូវមុខងារសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័នមិនទាន់ល្អប្រសើរ។ បន្ថែមពីនេះគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅពុំទាន់បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្អែកតាមមាតិកាថវិកានៅឡើយ។

**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** នៅមានការងារមិនទាន់សម្រេចបានមួយចំនួនដូចជា ការដាក់ក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (MTFF) សម្រាប់ស្នើសុំការអនុម័តក្នុងកិច្ចប្រជុំពេញអង្គនៃទីស្តីការគណៈរដ្ឋមន្ត្រី ការមិនទាន់បានអនុវត្តនូវការត្រួតពិនិត្យនិងតាមដានវាយតម្លៃលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី ការទទួលខុសត្រូវរបស់អង្គភាពថវិកានៅមានកម្រិត និងមិនទាន់មានការកំណត់អំពីហានិភ័យនៃហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ នៅមានការងារមួយចំនួនត្រូវពង្រឹងកែលម្អរួមមាន ការវាយតម្លៃពីអង្គភាពថវិកាតាមក្រសួង-ស្ថាប័ន ស្របតាមគោលការណ៍ណែនាំលក្ខខណ្ឌវិនិច្ឆ័យទាំង៧ គុណភាពនៃកម្មវិធី និងសូចនាករគន្លឹះនៅពុំទាន់ឆ្លើយតបបានពេញលេញនឹងភាពប្រាកដនិយមដើម្បីបម្រើគោលនយោបាយរាជរដ្ឋាភិបាលនៅឡើយ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅមិនទាន់សមស្របទៅនឹងរចនាសម្ព័ន្ធកម្មវិធី ការធ្វើសមាហរណកម្មថវិកាវិនិយោគទៅក្នុងកម្មវិធីមានទំហំតូចនៅឡើយ និងការមិនបានកំណត់គណនេយ្យភាពរវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន នៅក្រោមក្របខណ្ឌថវិកាកម្មវិធី។

**ការត្រៀមខ្លួនឆ្ពោះទៅជំហានបន្ទាប់** នៅមានកិច្ចការមួយចំនួនដែលនៅពុំទាន់សម្រេចបានពេញលេញដូចជា ការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ៨១ និងលេខ៨២ សម្រាប់អនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្ម ការរៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម ការរៀបចំក្របខណ្ឌតាមដាន និងត្រួតពិនិត្យប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មនៅមិនទាន់សម្រេចបានតាមផែនការដែលបានកំណត់ ការកំណត់នូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្ទៃក្រៅនៅពុំទាន់រលូនឆ្ពោះទៅរកការធានានូវគណនេយ្យភាពសមិទ្ធកម្ម ការកសាង

*នៅក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ អាទិភាពដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាល ក្នុងចំណោមអាទិភាពសំខាន់ៗ ក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមគឺ បន្តផ្តោតការយកចិត្តទុកដាក់លើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែប្រសើរឡើងជាលំដាប់បន្ថែមទៀត។*

សមត្ថភាពសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ ក៏មិនទាន់ត្រូវបានអនុវត្តតាមការគ្រោងទុក។ ផែនការកសាងសមត្ថភាពត្រូវបានរៀបចំរួច ប៉ុន្តែការអនុវត្តនៅតែជាបញ្ហាព្រួយបារម្ភជាពិសេស ការបណ្តុះបណ្តាលសមត្ថភាពតម្រង់ឆ្ពោះទៅកាន់ប្រព័ន្ធថវិកាសមិទ្ធកម្ម។ នៅក្នុងផ្នែកនេះដែរ ទោះបីវគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានរៀបចំឡើង ក៏ប៉ុន្តែការតាមដាននិងវាយតម្លៃពីប្រសិទ្ធភាព នៃវគ្គបណ្តុះបណ្តាលនៅជាចំណោទនៅឡើយ។ ទន្ទឹមនឹងនេះដែរ ក្នុងការផ្លាស់ប្តូរការត្រួតពិនិត្យពីធាតុចូល (ថវិកា សម្ភារៈ ឧបករណ៍ និងរបាយការណ៍ហិរញ្ញវត្ថុ) មកជាការតាមដានវាយតម្លៃលើធាតុចេញ (សកម្មភាពគោលដៅនៃសូចនាករលទ្ធផល នៃសកម្មភាព និងរបាយការណ៍លទ្ធផល) នៅមិនទាន់បែងចែកមុខងារឱ្យបានច្បាស់លាស់ក្នុងការបំពេញការងារជាក់ស្តែង រវាងអាជ្ញាធរសវនកម្មជាតិ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុងក្រសួង-ស្ថាប័ន ទោះជាអនុក្រឹត្យលេខ១៦៨ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខណ្ឌ មុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដែលជាការបោះជំហានខ្លីមួយ ក្នុងការរៀបចំក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

*ផែនការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានី-ខេត្ត*

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| កំពង់ស្ពឺ | កំពង់ឆ្នាំង | កណ្ដាល | កំពង់ចាម | រាជធានីភ្នំពេញ |
| កែប | ពោធិ៍សាត់ | បាត់ដំបង | កំពង់ធំ | |
| កោះកុង | តាកែវ | បន្ទាយមានជ័យ | ព្រះវិហារ | |
| ប៉ៃលិន | កំពត | ស្វាយរៀង | ឧត្ដរមានជ័យ | |
| ក្រចេះ | ព្រៃវែង | ត្បូងឃ្មុំ | សៀមរាប | |
| ស្ទឹងត្រែង | រតនគិរី | មណ្ឌលគិរី | ព្រះសីហនុ | |

**សម្រាប់ផ្នែកគាំទ្រ និងសម្របសម្រួល ការងារកែទម្រង់**នៅមានការងារមួយចំនួនដែលត្រូវបន្តផ្ដោតការអនុវត្តរួមមាន ភាពជាអ្នកដឹកនាំ ឆន្ទៈ ការយល់ដឹង និងការចូលរួម របស់ក្រសួង-ស្ថាប័ន កើនឡើងជាលំដាប់ប៉ុន្តែនៅពុំទាន់ឆ្លើយតបពេញលេញក្នុងការជំរុញការងារកែទម្រង់ឱ្យកាន់តែមានសន្ទុះ ជាពិសេសនៅកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់ និងការទទួលខុសត្រូវគ្រប់កម្រិត។ ទន្ទឹមនេះ ការកំណត់សមាសភាពទទួលប្រាក់ឧបត្ថម្ភរបស់ក្រសួង-ស្ថាប័ន សង្កេតឃើញថាមានការផ្លាស់ប្ដូរញឹកញាប់ដែលអាចប៉ះពាល់ដល់វឌ្ឍនភាពនៃការងារកែទម្រង់នៅក្នុងក្រសួង-ស្ថាប័ន។ ក្របខណ្ឌនៃលទ្ធផលកែទម្រង់ស្ថិតនៅជាការកសាងប្រព័ន្ធនៅឡើយមិនទាន់អាចឆ្លុះបញ្ចាំងបានពីបច្ច័យនៃការអនុវត្តហិរញ្ញវត្ថុសាធារណៈនៅឡើយ។ ការអនុវត្តសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន នៅមិនទាន់អាចកំណត់គោលដៅបានច្បាស់លាស់នៅឡើយ។ ម្យ៉ាងទៀត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ផ្សេងៗរបស់រាជរដ្ឋាភិបាលនៅពុំទាន់មានចក្ខុវិស័យ ឬយុទ្ធសាស្ត្រដើម្បីផ្សារភ្ជាប់គ្នានៅឡើយ។ យោងទៅតាមវឌ្ឍនភាពដែលសម្រេចបានខាងលើ និងការងារដែលនៅសេសសល់កន្លងមក, ផ្នែកជឿទុកចិត្តនៃថវិកាមានហានិភ័យទាបដោយសារ ការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូលទោះលើសពីការគ្រោងក្នុងច្បាប់ ប៉ុន្តែបង្កើនប្រាក់សន្សំសម្រាប់ទ្រទ្រង់ចំណាយ។ ចំណែក ការពង្រឹង ការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយមានកំណើនខ្ពស់នៅត្រីមាសទី៤ ប៉ុន្តែមានការអនុវត្តការងារកែទម្រង់មួយចំនួនដើម្បីពន្លឿនការចំណាយ ដូចជាភ្ជាប់ផែនការលទ្ធកម្មជាមួយសំណើផែនការថវិកាប្រចាំឆ្នាំ។ ផ្នែកគណនេយ្យភាពហិរញ្ញវត្ថុនៅមានហានិភ័យមធ្យម ព្រោះថាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បានក្លាយជាឆ្អឹងខ្នងនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ដោយសារតែមានការទទួលយកពីក្រសួង-ស្ថាប័ន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ការកសាងសមត្ថភាពជាបណ្ដើរៗ និងការពង្រីកម៉ូឌុលថ្មីៗបន្ថែម។ ប្រព័ន្ធនេះនឹងត្រូវបន្តអនុវត្តដើម្បីឱ្យក្លាយជាប្រព័ន្ធស្វ័យប្រវត្តិនៃនីតិវិធីអនុវត្ត និងការផលិតជារបាយការណ៍គ្រប់ជ្រុងជ្រោយ។ សម្រាប់ផ្នែកការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ អាចនឹងមិនសម្រេចបានតាមការគ្រោងទុក ប៉ុន្តែការសម្រេចនូវការដាក់ឱ្យអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័នជាមូលដ្ឋានដ៏សំខាន់។ នៅក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ ក្របខ័ណ្ឌនេះអាចផ្ដល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលធ្វើវិចារណកម្មចំណាយបាន និងផ្ដល់ត្រឡប់ទៅវិញបានត្រឹមត្រូវស្របតាមអាទិភាពរបស់រាជរដ្ឋាភិបាល។ ទោះបីជាយ៉ាងនេះក្ដី ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុ និងថវិការយៈពេលមធ្យមមានកម្រិតហានិភ័យខ្ពស់ ក្នុងពេលដែលឥទ្ធិពលខាងក្រៅនាំនាបង្កភាពមិនច្បាស់លាស់ ដល់ផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅឡើយ។ នៅក្នុងផ្នែកត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្មមានកម្រិតហានិភ័យខ្ពស់ ដោយសារការពន្យារពេលនៃការអនុវត្តច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី និងអនុក្រឹត្យលេខ៨១ និងលេខ៨២ ដែលជាការងារគន្លឹះៗនៃការកសាងប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។ ចំណែកផ្នែកគាំទ្រ និងសម្របសម្រួល មានហានិភ័យមធ្យម ក្នុងនោះការកសាងសមត្ថភាពមានកម្រិតហានិភ័យខ្ពស់ ដោយសារគុណភាពនៃការបណ្ដុះបណ្ដាលនៅមិនទាន់ឆ្លើយនឹងនិន្នាការកែទម្រង់នៅឡើយ ហើយជាជំហានបន្ទាប់ការបណ្ដុះបណ្ដាលសម្រាប់ក្រសួង-ស្ថាប័ននឹងត្រូវបានយកចិត្តទុកដាក់បន្ថែមទៀត។ សម្រាប់ការសម្របសម្រួលជាមួយនឹងការដ្ឋានកែទម្រង់ផ្សេងទៀតអាចនឹងមានហានិភ័យមធ្យម លើជំហានបន្ទាប់។

ជារួម បើទោះបីជារាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពច្បាស់លាស់ប្រកបដោយភាពប្រាកដនិយម ដើម្បីគ្រប់គ្រងហានិភ័យតាមផ្នែក និងបន្តបោះជំហានទៅអនុវត្តខឿនទី៤ នៃកម្មវិធីកែទម្រង់ក៏ពិតមែន ការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តរយៈពេល២ឆ្នាំ ទៅពង្រឹងការអនុវត្តយុទ្ធសាស្ត្រ និងផែនការទាំងនោះ ពិសេសក្នុងបរិការណ៍សង្គមសេដ្ឋកិច្ចក្រោមឥទ្ធិពលនៃវិបត្តិកូវីដ-១៩ គឺជាជម្រើសដ៏ត្រឹមត្រូវមួយក្នុងការបំប៉នកោសិកាគ្រប់ផ្នែកនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈផង និងបន្សាំទៅនឹងផលប៉ះពាល់ខាងក្រៅផង៕■

*រៀបចំដោយ៖ ផ្នែកគោលនយោបាយ និងរៀបចំថវិកានៃ អ.គ.ហ.*

# ការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២ ឆ្នាំ២០២១-២០២២ (CAP3+2)

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអនុវត្តបាន ៣ ដំណាក់កាលរួចមកហើយ ដែលក្នុងដំណាក់នីមួយៗមាន "ផែនការសកម្មភាពរួម (Consolidated Action Plan-CAP)" មួយ ជាមគ្គុទ្ទេសសម្រាប់ការអនុវត្តសកម្មភាពកែទម្រង់។ ផែនការសកម្មភាពរួមទាំង៣ ដំណាក់កាលរួមមាន ផែនការសកម្មភាពរួមដំណាក់កាលទី១ (CAP1) ផែនការសកម្មភាពរួម ដំណាក់កាលទី២ (CAP2) និងផែនការសកម្មភាពរួម ដំណាក់កាលទី៣ (CAP3) ដោយផ្តោតសំខាន់លើ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ដែលត្រូវបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការកាលដើមឆ្នាំ២០១៦ និងត្រូវបានបញ្ចប់ក្នុងឆ្នាំ២០២០ កន្លងទៅ។*

ផ្អែកលើការវាយតម្លៃ CAP3 ឆ្នាំ២០១៦ ដល់២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability-PEFA) បានបង្ហាញឱ្យឃើញថាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាត្រូវបានកែលម្អជាបណ្តើរៗ និងនៅមានការងារសេសសល់មួយចំនួន ដែលមានវឌ្ឍនភាព និងទិសដៅច្បាស់លាស់ស្របតាមបរិការណ៍កម្ពុជា និងសមស្របតាមស្តង់ដារ និងជាឧត្តមានុវត្តអន្តរជាតិ ជាពិសេសក្នុងដំណាក់កាលលំបាកនៃវិបត្តិកូវីដ-១៩ ក្នុងឆ្នាំ២០២០, ស្ថានភាពហិរញ្ញវត្ថុសាធារណៈកម្ពុជា នៅមានលក្ខណៈប្រសើរ ឆ្លុះបញ្ចាំងតាមរយៈការធានាបានចីរភាព នៃការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងលទ្ធភាពរិភាជន៍ឡើងវិញនូវចំណាយក្នុងឆ្នាំ ឆ្លើយតបបានទៅនឹង

**រចនាសម្ព័ន្ធ នៃផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២**

| ផែនការសកម្មភាពរួម-ដំណាក់កាលទី៣ (CAP3) | ក្របខណ្ឌផែនការសកម្មភាពរួម-ដំណាក់កាលទី៣ បូក២ (CAP3+2) |
|---|---|
| ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា" | ផ្នែកទី/ ខឿនទី១ "ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា" |
| ផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ" | ផ្នែកទី/ ខឿនទី២ "ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ" |
| ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" | ផ្នែកទី/ ខឿនទី៣ "ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" |
| ផ្នែកទី៤ "ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់" | ផ្នែកទី/ ខឿនទី៤ "ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម" |
| ផ្នែកទី៥ "ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយជោគជ័យ និងចីរភាព" | ផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត" |




អាទិភាពចល័តដែលកើតមានថ្មីៗ ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានា ក្នុងផ្នែកសេដ្ឋកិច្ច និងសង្គម។ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំងបី ខាងដើមមុននឹងឈានទៅដំណាក់កាល/ខឿនទី៤ ចុងក្រោយ និងការងារគន្លឹះៗដែលសេសសល់ផ្សេងៗទៀត ដើម្បីធានាឱ្យមានចីរភាពនៃការងារកែទម្រង់និងការដើរស្របគ្នាជាមួយនឹងកិច្ចការងារកែទម្រង់ផ្សេងៗទៀតមុននឹងឈានបោះជំហានទៅដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" នាបន្ទាប់, រាជរដ្ឋាភិបាលបានសម្រេចបន្តអនុវត្តCAP3 រយៈពេល២ ឆ្នាំបន្ថែមទៀត (២០២១-២០២២) និងត្រូវបានឱ្យឈ្មោះជា "**ផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២(CAP3+2) ឆ្នាំ២០២១-២០២២**" ក្នុងគោលបំណងសំខាន់ឆ្ពោះទៅកសាងនូវលក្ខខណ្ឌចាំបាច់ទាំងឡាយ ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង "វប្បធម៌សមិទ្ធកម្ម" ក្នុងក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ការពន្យារពេល CAP3 ដោយកែសម្រួលអាទិភាពមួយចំនួនឡើងវិញ និងខិតខំសម្រេចការងារដែលនៅសេសសល់ឱ្យបានជាអតិបរមា ដើម្បីធានាឱ្យមានចីរភាពនៃការងារកែទម្រង់ និងការដើរស្របគ្នាជាមួយនឹងកិច្ចការងារកែទម្រង់ផ្សេងៗទៀតរួមទាំងឆ្លើយតបបានទៅនឹងបរិការណ៍ នៃជំងឺកូវីដ-១៩ ការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩ និងការតម្រង់ឆ្ពោះទៅរកគណនេយ្យភាពសមិទ្ធកម្ម។ ការអនុវត្តនូវសកម្មភាពដែលមិនទាន់បានសម្រេចគ្រប់ជ្រុងជ្រោយ គឺជាអន្តរកាលសំខាន់ក្នុងការកសាងគណនេយ្យភាពសមិទ្ធកម្ម ដើម្បីធានាដោយភាពជឿជាក់ថា ខឿនទាំង៣ ខាងដើមមានភាពរឹងមាំគ្រប់គ្រាន់មុននឹងឈានទៅដំណាក់កាលទី៤ គឺ "ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម" ចាប់ពីឆ្នាំ២០២៣ រហូតដល់ឆ្នាំ២០២៧។

ផ្អែកលើបទពិសោធនៃការរៀបចំក្របខណ្ឌ CAP1, CAP2 និង CAP3 កន្លងមក អភិក្រមនៃការរៀបចំ "ផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២ (CAP3+2) ឆ្នាំ២០២១-២០២២" ប្រកាន់ខ្ជាប់ការងារលំដាប់លំដោយ រួមមាន÷

- រៀបចំទស្សនាទានស្តីពីការរៀបចំCAP3+2 ដោយបង្ហាញសនិទានកម្ម និងរចនាសម្ព័ន្ធច្បាស់លាស់
- កំណត់ក្របខណ្ឌលទ្ធផលរយៈពេល២ ឆ្នាំ (២០២១-២០២២) ដោយបញ្ជាក់អំពីសូចនាករសមិទ្ធកម្មគន្លឹះ, លទ្ធផលគោល, វិធីសាស្ត្រវាស់វែង, គោលដៅ និងឯកសារភស្តុតាង
- មូលដ្ឋានច្បាស់លាស់សម្រាប់ផ្សារភ្ជាប់ដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

● តម្រង់ការផ្លាស់ប្តូរពី “ជំហាន” មកជាការពង្រឹង និងកសាង “ខឿន” នីមួយៗ ដែលជាសសរស្តម្ភនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយតម្រឹមទៅនឹង PEFA។

ផែនការសកម្មភាពរួម ដំណាក់កាលទី-៣ បូក២ មិនរក្សាទម្រង់ CAP3 ទៀតទេ គឺរៀបចំកែសម្រួលជាថ្មី ដោយបែងចែកគោលបំណងច្បាស់លាស់តាមផ្នែក/ខឿននីមួយៗ ដោយបញ្ជាក់អំពីសូចនាករសមិទ្ធកម្មគន្លឹះ លទ្ធផលគោលវិធីសាស្ត្រវាស់វែង គោលដៅ និងឯកសារភស្តុតាង និងមានការកែសម្រួលឡើងវិញនូវកម្រិតផ្នែក ការកែសម្រួលនៅកម្រិតគោលបំណង ការរៀបចំនូវសូចនាករគន្លឹះដែលមានសង្គតិភាពរវាងកម្រិតគោលបំណង និងកម្រិតចង្កោមសកម្មភាព ព្រមទាំងការរៀបចំនូវក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

រចនាសម្ព័ន្ធ CAP3+2 មានចំនួន៥ ផ្នែក ១៩ គោលបំណង ព្រមទាំង៤៤ សូចនាករសមិទ្ធកម្មគន្លឹះកម្រិតគោលបំណង (ស.គ) និង៥៩ ចង្កោមសកម្មភាព ដែលមាន១១៣ សូចនាករសមិទ្ធកម្មគន្លឹះ កម្រិតចង្កោមសកម្មភាព (ស.ច)។ សូចនាករគន្លឹះត្រូវបានរៀបចំជារង្វាស់ នៃការសម្រេចគោលបំណងដែលបានដាក់ចេញ។ នេះគឺជាលក្ខណៈដោយឡែក សម្រាប់ការរៀបចំ CAP3+2។ ការកំណត់សូចនាករគន្លឹះនេះត្រូវបានធ្វើឡើងក្នុងប្រភេទចំនួនបីរួមមាន (១) ការបង្កើតនូវក្របខណ្ឌច្បាប់ យន្តការ និងក្របខណ្ឌផ្សេងៗ បម្រើឱ្យការងារកែទម្រង់, (២) ការកែលម្អប្រសិទ្ធភាពលើមូលដ្ឋានដែលមានស្រាប់ ដោយផ្អែកភាពទាន់ពេលវេលា ការពង្រីកការអនុវត្ត និងការកែលម្អគុណភាព, (៣) ការធានាបានចីរភាពនៃការកែទម្រង់ តាមរយៈការបន្តអនុវត្តល្អ ដែលសម្រេចបានកន្លងមក។




ការវាស់វែងលើគោលបំណងនីមួយៗ ត្រូវមានភាពច្បាស់លាស់ ដោយរក្សាមិនឱ្យមានសូចនាករច្រើនលើសពី៣ ឡើយ។ លើសពីនេះ សូចនាករនីមួយៗ មានការបញ្ជាក់ច្បាស់លាស់ពីបន្ទាត់មូលដ្ឋាន វិធីសាស្ត្រវាស់វែង គោលដៅ ព្រមទាំងឯកសារសម្រាប់ការផ្ទៀងផ្ទាត់។

ក្នុងរូបភាពខាងក្រោមនឹងបង្ហាញអំពីខ្លឹមសារ នៃរចនាសម្ព័ន្ធ CAP3+2 រួមមានផ្នែក/ខឿន ទាំង៥, គោលបំណងទាំង១៩ និងចំនួនសូចនាករគន្លឹះរបស់គោលបំណង (សគ.)។ ផ្នែក/ខឿននីមួយៗត្រូវបានបង្ហាញក្នុង “**រង្វង់**” ដែលមានចំនួនគោលបំណងជាលេខនៅជាប់រង្វង់។ គោលបំណងជាខ្លឹមសារមាននៅក្នុង “**ប្រអប់**” ដែលមានចំនួនសូចនាករសមិទ្ធកម្មគន្លឹះ (សគ.) ជាលេខនៅជាប់ប្រអប់នីមួយៗ។ ឧទាហរណ៍ ក្នុងរង្វង់ផ្នែក/ខឿនទី១ “**ភាពជឿទុកចិត្តបាននៃថវិកា**” មានគោលបំណងចំនួន៣ ដែលគោលបំណង “បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល” មានចំនួន២ **សគ.**, គោលបំណង




"ពង្រឹងការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ" មានចំនួន ១ សគ. និងគោលបំណង "កែលម្អដំណើការនៃការអនុវត្តថវិកា" មានចំនួន ៣ សគ.។

ជារួម ក្របខណ្ឌផែនការកម្មភាពរួមដំណាក់កាលទី៣ បូក២ នៅតែរក្សារចនាសម្ព័ន្ធជា៥ផ្នែក និងផ្តល់អាទិភាព។ ផ្នែកទី១ "ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា" ដោយផ្តោតលើការអនុវត្តគោលនយោបាយ និងការគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនពន្ធ និងការអនុវត្តផែនការចំណាយថវិកា។ ផ្នែកទី២ "**ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ**" ដោយពង្រឹង និងពង្រីកការប្រើប្រាស់ FMIS។ ផ្នែកទី៣ "**ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ផ្តោតលើថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា, ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកា, ការកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នសាមី និងស្ថាប័ននីតិបញ្ញត្តិ, ការរៀបចំ

*រាជរដ្ឋាភិបាលបានសម្រេចបន្តអនុវត្ត CAP3 រយៈពេល២ ឆ្នាំបន្ថែមទៀត (២០២១-២០២២) និងត្រូវបានឱ្យឈ្មោះថា "ផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២(CAP3+2) ឆ្នាំ២០២១-២០២២" ក្នុងគោលបំណងសំខាន់ឆ្ពោះទៅកសាងនូវលក្ខខណ្ឌចាំបាច់ទាំងឡាយ ដើម្បីឈានឆ្ពោះទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង "វប្បធមិសមិទ្ធកម្ម" ក្នុងក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូល។*

ឱ្យមានក្របខណ្ឌចំណាយសាធារណៈរយៈពេលមធ្យម, ការបង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ, ព្រមទាំងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។ ផ្នែកទី៤ "**ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម**" ផ្តោតសំខាន់លើក្របខណ្ឌថវិកាសមិទ្ធកម្ម ការកំណត់បន្ទាត់គណនេយ្យភាព ថវិកាសមិទ្ធកម្ម ការដាក់ឱ្យអនុវត្តនូវក្របខណ្ឌសវនកម្មសមិទ្ធកម្ម និងផែនការអភិវឌ្ឍន៍សមត្ថភាព។ ផ្នែកទី៥ "**ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត**" ផ្តោតលើការលើកកម្ពស់ភាពជាអ្នកដឹកនាំក្នុងការងារកែទម្រង់ ការកសាងសមត្ថភាព និងការផ្តល់ការលើកទឹកចិត្តដល់ការងារកែទម្រង់ និងការពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តដំណាក់កាលទី៣។ "ផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២" នឹងប្រែក្លាយទៅជា "ផែនការសមិទ្ធកម្ម២ ឆ្នាំ" សម្រាប់ឆ្ពោះទៅដំណាក់កាលទី៤ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា៕■

*រៀបចំដោយ÷ ផ្នែកគោលនយោបាយ និងរៀបចំថវិកានៃ អ.គ.ហ.*

# កិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ.) និងសាលាលីក្វាន់យូ

*ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ការកសាង និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស ជាកត្តាចាំបាច់មួយក្នុងការចូលរួមចំណែកជំរុញ និងពន្លឿនការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចនូវចក្ខុវិស័យដែលបានគ្រោងទុក។ ក្នុងគោលដៅចូលរួមលើកកម្ពស់ និងពង្រឹងសមត្ថភាពមន្ត្រីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, អគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ(អ. គ. ហ.) ក្នុងនាមជាសេនាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈបានផ្តល់កិច្ចសម្របសម្រួលផ្សេងៗ និងបង្កើតនូវកាលានុវត្តភាពក្នុងកិច្ចសហប្រតិបត្តិការនានាជាមួយស្ថាប័នអប់រំជាតិ និងអន្តរជាតិ។*

ជាក់ស្តែង នៅឆ្នាំ២០២០ កន្លងទៅ, **អ.គ.ហ.** បានចុះអនុស្សរណៈយោគយល់ជាមួយនឹងសាលាលីក្វាន់យូ ក្នុងគោលដៅផ្តល់ការបណ្តុះបណ្តាល និងសេវាអប់រំដែលមានស្តង់ដារប្រកបដោយគុណភាព ជូនមន្ត្រីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

អនុស្សរណៈយោគយល់រវាង **អ.គ.ហ.** និងសាលាលីក្វាន់យូបានចុះកិច្ចព្រមព្រៀងជាផ្លូវការនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ក្រោយពីបានចរចាលើការកំណត់លក្ខខណ្ឌអស់រយៈពេលជាច្រើនខែរួចមក។ ការរៀបចំកិច្ចព្រមព្រៀងនេះនឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់មន្ត្រីកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាតាមរយៈ (១). ការផ្លាស់ប្តូរបទពិសោធល្អៗនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលសិង្ហបុរី (២). ការផ្តល់សេវាអប់រំដែលមានគុណភាព និងស្តង់ដារជូនមន្ត្រីកែទម្រង់ (៣). ពង្រឹងការចំណាយថវិកាលើការបណ្តុះបណ្តាលឱ្យចំគោលដៅ និង (៤). ជាឧបករណ៍លើកទឹកចិត្តមន្ត្រីកែទម្រង់ដែលមានសមត្ថភាពគ្រប់គ្រាន់ឱ្យអភិវឌ្ឍ


LKY Lee Kuan Yew School of Public Policy
National University of Singapore

Dated 29/01/2020

Between

NATIONAL UNIVERSITY OF SINGAPORE
acting through its LEE KUAN YEW SCHOOL OF PUBLIC POLICY

And

GENERAL SECRETARIAT OF PUBLIC FINANCIAL MANAGEMENT REFORM
STEERING COMMITTEE (GSC) OF ROYAL GOVERNMENT OF CAMBODIA

MEMORANDUM OF UNDERSTANDING

ខ្លួនកាន់តែខ្លាំង។ តាមរយៈអនុស្សរណៈយោគយល់នេះ, **អ.គ.ហ.** និងសាលាលីក្វាន់យូ បានសហការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវគ្គបណ្តុះបណ្តាលជាក់លាក់ (Customized course) នានា, ផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក៏ដូចជាផ្តល់ការសម្របសម្រួលរៀបចំកម្មវិធីទស្សនកិច្ចសិក្សានៅប្រទេសសិង្ហបុរីស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។




*វគ្គបណ្តុះបណ្តាលស្តីពី "ទស្សនាទានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" តាមប្រព័ន្ធវីដេអូ រយៈពេលពីរថ្ងៃកន្លះ ចាប់ពីថ្ងៃទី១០ ដល់ទី១២ ខែវិច្ឆិកា ឆ្នាំ២០២០។*

ជាការអនុវត្ត, នៅឆ្នាំ២០២០ **អ.គ.ហ.** និងសាលាលីក្វាន់យូបានសាកល្បងរៀបចំវគ្គបណ្តុះបណ្តាលក្នុងស្រុកចំនួនមួយស្តីពី **"ទស្សនាទានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"** ដែលមានរយៈពេលពីរថ្ងៃកន្លះ ចាប់ពីថ្ងៃទី១០ ដល់ទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ សម្រាប់មន្ត្រីកែទម្រង់ចំនួន២៥នាក់ដែលមកពីក្រសួង-ស្ថាប័នចំនួន២៥។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំតាមរយៈប្រព័ន្ធអនឡាញ និងបានប្រព្រឹត្តទៅដោយរលូន។ វគ្គបណ្តុះ-បណ្តាលនេះត្រូវបានចូលរួមយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវពីសិក្ខា-កាម ស្របជាមួយនឹងការវាយតម្លៃខ្ពស់លើសមត្ថភាព បទពិសោធ និងវិធីសាស្ត្របង្រៀនរបស់សាស្ត្រាចារ្យសាលាលីក្វាន់យូ។ កិច្ចសហការលើកដំបូងនេះ បានបង្ហាញពីគុណភាពនៃការបណ្តុះបណ្តាលរបស់សាលាលីក្វាន់យូជូនដល់សិក្ខាកាមកម្ពុជា និងរបៀបរបបការងារហ្មត់ចត់ប្រកបដោយវិន័យក្រោមកិច្ចសហការរវាង **អ.គ.ហ.** និងសាលាលីក្វាន់យូ។

*តាមរយៈអនុស្សារណៈយោគយល់នេះ, អ.គ.ហ. និងសាលាលីក្វាន់យូ បានសហការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវគ្គបណ្តុះបណ្តាលជាក់លាក់ (customized course) នានា, ផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក៏ដូចជាផ្តល់ការសម្រប-សម្រួលរៀបចំកម្មវិធីទស្សនកិច្ចសិក្សានៅប្រទេសសិង្ហបុរី*

នៅឆ្នាំ២០២០ ដដែល, **អ.គ.ហ.** និងសាលាលីក្វាន់យូ បានបន្តកិច្ចសហការរៀបចំ "កម្មវិធីអាហារូបករណ៍កម្មវិធីកែ-ទម្រង់ហិរញ្ញវត្ថុសាធារណៈ" ក្រោមជំនួយឧបត្ថម្ភពី **អ.គ.ហ.** និងសាលាលីក្វាន់យូ សម្រាប់មុខវិជ្ជាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួនពីរគឺ÷

1. *គោលនយោបាយសាធារណៈ (Master in Public Policy-MPP) រយៈពេល ០២ ឆ្នាំ*
2. *រដ្ឋបាលសាធារណៈ (Mas ter in Public Adminis tration-MPA) រយៈពេល ០២ ឆ្នាំ*

ក្នុងនាមស្ថាប័នដៃគូសហការ, **អ.គ.ហ.** ត្រូវបានផ្តល់សិទ្ធិ ឱ្យជ្រើសរើសបេក្ខជនជាប់វគ្គជម្រុះដំបូង (shortlist candidates) និងបញ្ជូនឈ្មោះបេក្ខជនទាំងនោះជូនសាលាលីក្វាន់យូ ដើម្បីជ្រើសរើសចុងក្រោយ។ អាហារូបករណ៍កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីដែលបានរៀបចំឡើងស្របតាមកិច្ចព្រមព្រៀងរវាង **អ.គ.ហ.** និងសាសាលាលីក្វាន់យូ ដើម្បីផ្តល់អត្ថប្រយោជន៍ដល់បេក្ខជនដែលត្រូវបានជ្រើសរើសដោយ **អ.គ.ហ.**។ ក្នុងន័យនេះ បេក្ខជនដែល **អ.គ.ហ.** បានជ្រើស-រើសនឹងទទួលបានការណែនាំសម្របសម្រួល ព្រមទាំងផ្តល់បុរេវិនិច្ឆ័យ(pre assessment) ពីក្រុមការងារសាលាលីក្វាន់យូ លើការសរសេរលិខិត និងការរៀបចំសំណុំឯកសារផ្សេងៗក្នុងការដាក់ពាក្យចូលរៀន (admis-sion application)។ បេក្ខជនដែលជាប់ជាស្ថាពរនឹងទទួលការឧបត្ថម្ភអាហារូប-ករណ៍ពី **អ.គ.ហ.** និងសាលាលីក្វាន់យូ។

តាមរយៈបទពិសោធសាកល្បងក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយសាលាលីក្វាន់យូ នៅឆ្នាំ២០២០ កន្លងមកនេះបានបង្ហាញថាសាលាលីក្វាន់យូជាដៃគូសហការដ៏ល្អបំផុត ក្នុងការចែក-រំលែកបទពិសោធ ចំណេះដឹង និងការបំពាក់បំប៉នការបណ្តុះបណ្តាលមួយដែលមានស្តង់ដារអន្តរជាតិ និងគុណភាពខ្ពស់ជូនធនធានមនុស្សកម្ពុជា ដើម្បីចូលរួមអភិវឌ្ឍ និងជំរុញកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល៕■

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍នៃ អ.គ.ហ.*

# បរិបទការងារថ្មីក្នុងអំឡុងពេលនៃវិបត្តិជំងឺរាតត្បាតផ្លូវដង្ហើម (កូវីដ-១៩)

*ចាប់តាំងពីពិភពលោកជួបប្រទះនូវសង្គ្រាមផ្លូវដង្ហើមដែលហៅថាកូវីដ-១៩នៅចុងឆ្នាំ២០១៩ មកជីវភាពរស់នៅរបស់មនុស្សជាតិចាប់ផ្តើមមានការផ្លាស់ប្តូរទៅរកទម្រង់ថ្មីមួយទៀត ដែលប្រែក្លាយពីការធ្លាប់ជួបប្រាស្រ័យទាក់ទងជិតស្និទ្ធផ្ទាល់ មកជាការទំនាក់ទំនងក្នុងគម្លាតមួយ ពីការធ្វើដំណើរហោះហើរដោយសេរីមកជាការស្នាក់នៅគេហដ្ឋានក្នុងរយៈពេលឈប់សម្រាកដ៏យូរ ពីការធ្វើដំណើរទៅផ្សារដើម្បីទិញម្ហូបអាហារ ឬទៅភោជនីយដ្ឋានជាប្រចាំថ្ងៃមកជាការរៀបចំការរក្សាចំណីអាហារឱ្យបានយូរ និងការធ្វើម្ហូបអាហារនៅផ្ទះច្រើនជាងសព្វមួយដងជាដើម។*

យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ បង្ហាញថាសហគ្រាសជាច្រើនលើសកលលោកបាន និងកំពុងទទួលរងការគំរាមកំហែង ក្នុងនោះដែរកម្លាំងពលកម្មប្រមាណ **៣.៣ប៊ីលាន** កំពុងប្រឈមមុខយ៉ាងខ្លាំងសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។

ក្នុងអំឡុងពេលនៃវិបត្តិនេះ មនុស្សត្រូវសម្របខ្លួនជាមួយបរិបទថ្មីមួយទៀតដែលមិនធ្លាប់ជួបប្រទះ និងស្វះស្វែងរកមធ្យោបាយចិញ្ចឹមជីវិតថ្មីក្នុងអំឡុងពេលដែលប្រទេសជាច្រើនបានដាក់វិធានការបិទខ្ទប់ប្រទេសដើម្បីបង្ការ និងកាត់បន្ថយការរីករាតត្បាតដ៏កាចសាហាវនេះ។ សម្រាប់អ្នកដែលប្រកបមុខរបរ ឬមានតួនាទីការងារក្នុងការិយាល័យ ត្រូវបានផ្លាស់ប្តូរពីការទៅធ្វើការជាប្រចាំនៅការិយាល័យ ទៅជាការធ្វើការងារពីចម្ងាយតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ការប្រាស្រ័យទាក់ទងគ្នាដូចជាកម្មវិធី Microsft TEAM, ZOOM, Webex, Line, Google Meet ជាដើម។ យោងតាមការស្រាវជ្រាវរបស់ Future Forum Research បានបង្ហាញថា ក្នុងចំណោមអ្នកធ្វើការដែលមានចំណេះដឹងខ្ពស់ប្រមាណ៤៧០០នាក់ ភាគច្រើនក្នុងចំណោមពួកគេ គឺមិនចង់ផ្លាស់ប្តូរទៅរករបៀបធ្វើការចាស់បន្ទាប់ពីស្ថានភាពវិលមកប្រក្រតី។ មានតែ១២% ប៉ុណ្ណោះដែលចង់ទៅធ្វើការពេញម៉ោងនៅការិយា-



*សកម្មភាពបំពេញការងារ និងប្រាស្រ័យទាក់ទងគ្នាពីចម្ងាយតាមរយៈប្រព័ន្ធវីដេអូ ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩*




*ទម្លាប់ក្នុងការរស់នៅ និងប្រាស្រ័យទាក់ទងគ្នា ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩*

ល័យ ហើយ ៧២% ទៀតគឺចង់បានរបៀបធ្វើការបានកូនកាត់គឺការិយាល័យខ្លះ និងការធ្វើការងារពីចម្ងាយខ្លះ។ ប៉ុន្តែ បញ្ហាប្រឈមខ្លាំងកើតមានចំពោះអ្នកដែលមិនអាចធ្វើការពីចម្ងាយបានដោយសារតែកង្វះចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍ជំនួយផ្សេងៗទៀត។

របៀបរបបធ្វើការតាមទម្រង់ថ្មីគឺការធ្វើការពីចម្ងាយក្នុងអំឡុងពេលនៃវិបត្តិជំងឺរាតត្បាតនេះ បានបង្កជាសំណួរជាច្រើនសម្រាប់ពេលអនាគតបន្ទាប់ពីជំងឺនេះត្រូវបានទប់ស្កាត់បានទាំងស្រុង។ ចំណុចទាំងនោះជាអាទិ៍រួមមានកំណើន ឬតំហយនៃផលិតភាពការងារ ការទំនាក់ទំនងរវាងប្រធានស្ថាប័ន និងបុគ្គលិក ការវាយតម្លៃលើសមិទ្ធកម្មការងាររបស់បុគ្គលិក ឬការជ្រើសរើសបុគ្គលិកថ្មី ការអនុម័តផ្លូវការលើឯកសារចាំបាច់ជាក្រដាសស្នាមត្រូវបានផ្លាស់ប្តូរ ឬយ៉ាងណា ការបន្តផ្តល់ ឬបញ្ឈប់ការរៀបចំការិយាល័យទំនើបសម្រាប់មន្ត្រី

*សម្រាប់អ្នកដែលប្រកបមុខរបរ ឬមានតួនាទីការងារក្នុងការិយាល័យ ត្រូវបានផ្លាស់ប្តូរពីការទៅធ្វើការជាប្រចាំនៅការិយាល័យ ទៅជាការធ្វើការងារពីចម្ងាយតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ការប្រាស្រ័យទាក់ទងគ្នាដូចជាកម្មវិធី Microsoft Team, Zoom, Webex, Line, Google Meet ជាដើម។*

ជាន់ខ្ពស់ ការពង្រីក ឬបង្រួមទំហំកន្លែងធ្វើការ ការបង្កើន ឬបន្ថយចំណតយានយន្ត ការបង្កើនចំណាយលើការវិនិយោគបច្ចេកវិទ្យាថ្មីៗ ការដឹកជញ្ជូន ជាដើម ។ល។ កាលានុវត្តភាព និងបញ្ហាប្រឈមដែលជះឥទ្ធិពលពីជំងឺរាតត្បាតនេះលើរបៀបរបបរស់នៅ ឬការប្រកបការងារថ្មី គឺត្រូវគិតគូរឱ្យបានម៉ត់ចត់ ដើម្បីរក្សាលំនឹងជីវភាព និងអាជីវកម្មរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចផងដែរ៕■

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍នៃ អ.គ.ហ.*




*កម្មវិធីដែលពេញនិយម ប្រើសម្រាប់ទំនាក់ទំនង (កិច្ចប្រជុំ ឬការសិក្សា) តាមប្រព័ន្ធវីដេអូ*

# គតិពិចារណាលើសុខដុមនីយកម្មនៃមុខងារសវនកម្មនិងអធិការកិច្ច ៖ បទពិសោធប្រទេសកូរ៉េ

*ការអនុវត្តសវនកម្មនិងអធិការកិច្ចនៅសាធារណរដ្ឋកូរ៉េ មានលក្ខណៈពិសេសពីបណ្តាប្រទេសផ្សេងទៀត ដ៏គួរឱ្យចាប់អារម្មណ៍។*

មុខងារសវនកម្មនិងអធិការកិច្ច គឺជាមុខងារពីរផ្សេងពីគ្នាតែមុខងារទាំងពីរនេះ តែងតែនៅស្និទ្ធជាមួយគ្នានិងបំពេញឱ្យគ្នាទៅវិញទៅមក បានន័យថា មុខងារទាំងពីរត្រូវបានដាក់ឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធអង្គភាពគ្រប់គ្រងតែមួយ ទាំងនៅក្នុងក្របខណ្ឌស្ថាប័នសវនកម្មកំពូល និងក្នុងក្របខណ្ឌសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន។

## ១.កម្រិតក្រសួង-ស្ថាប័ន

### ១.១.ក្របខណ្ឌច្បាប់និងការរៀបចំស្ថាប័ន

រដ្ឋាភិបាលកូរ៉េបានដាក់ចេញនូវបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនដែលគ្របដណ្តប់លើការអនុវត្តសវនកម្មផ្ទៃក្នុង ជាពិសេស គឺ ច្បាប់ស្តីពីសវនកម្មវិស័យសាធារណៈ ឆ្នាំ២០១០ (Act on Public Sector Audit) និងបទដ្ឋានគតិយុត្តសម្រាប់គាំទ្រការអនុវត្តច្បាប់នេះផងដែរ គឺក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសវនកម្មវិស័យសាធារណៈ (Enforcement Decree of the Act on Public Sector Audit) ដែលត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់។

ច្បាប់ដូចបានលើកឡើងខាងលើ បានកំណត់យ៉ាងលម្អិតនូវកិច្ចដំណើរការនៃការអនុវត្តសវនកម្មផ្ទៃក្នុង (នៅប្រទេសកូរ៉េហៅជាភាសាអង់គ្លេសថា self audit) ដែលមានសំខាន់ៗដូចជាការកំណត់និយមន័យនៃសវនកម្មផ្ទៃក្នុង,វិសាលភាពនៃការអនុវត្ត, កិច្ចប្រតិបត្តិការសវនកម្ម, ការធានាឯករាជ្យភាពនៃការបំពេញមុខងាររបស់សវនកម្មផ្ទៃក្នុង, ការតែងតាំងសវនករ, អាណត្តិរបស់សវនករ, គុណវុឌ្ឍិរបស់ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង, មុខងារនិងភារកិច្ច,វិមិតភាព, ការរៀបចំផែនការសវនកម្ម, ប្រភេទសវនកម្ម និងវិធាន នីតិវិធីស្តង់ដារសវនកម្មជាដើម។

ក្រសួង- ស្ថាប័នចំណុះរដ្ឋាភិបាលកូរ៉េ ស្ទើរតែទាំងអស់ មានជាឯកសណ្ឋានក្នុងអង្គការលេខនៃរចនាសម្ព័ន្ធស្ថាប័នរបស់ខ្លួន នូវអង្គភាពមួយដែលហៅថា “**អគ្គាធិការដ្ឋាន**” (Inspector General) ដែលមានបេសកកម្មអនុវត្តមុខងារសវនកម្មផង និងអធិការកិច្ចផង។

### ១.២.ការបែងចែកមុខងារសវនកម្មផ្ទៃក្នុង និង អធិការកិច្ច

ថ្វីត្បិតមុខងារសវនកម្មនិងអធិការកិច្ចនៅតាមក្រសួង-ស្ថាប័នស្ថិតនៅក្នុងអង្គភាពតែមួយ តែការបែងចែកសមត្ថកិច្ច និងវិសាលភាពនៃមុខងារទាំង២ នេះ ជាចំណុចដ៏មានសារៈសំខាន់ដែលត្រូវតែកំណត់ឱ្យបានច្បាស់លាស់។ បើពិនិត្យទៅលើលិខិតបទដ្ឋានពាក់ព័ន្ធទាំងអស់និងអង្គការលេខរបស់ក្រសួងចំណុះឱ្យរដ្ឋាភិបាលកូរ៉េ ឃើញថាការបែងចែកនេះ ទំនងជាឆន្ទានុសិទ្ធិរបស់រដ្ឋមន្ត្រីក្រសួង និងប្រធានស្ថាប័ននីមួយៗ ដែលជាអ្នកត្រូវសម្រេច។




ជាឧទាហរណ៍ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពអគ្គាធិការដ្ឋានស្ថិតនៅក្រោមភារកិច្ចគ្រប់គ្រងរបស់រដ្ឋមន្ត្រីផ្ទាល់តែម្តង។ ទន្ទឹមនេះ ក្រសួងផ្សេងខ្លះទៀតបានរៀបចំអគ្គាធិការដ្ឋាន ឱ្យស្ថិតក្រោមភារកិច្ចទទួលខុសត្រូវរបស់អនុរដ្ឋមន្ត្រីក្រសួង ដូចជាករណីក្រសួងមហាផ្ទៃ និងសុវត្ថិភាពជាដើម។

លើសពីនេះ ករណីក្រសួងយុត្តិធម៌របស់រដ្ឋាភិបាលកូរ៉េ បានរៀបចំរចនាសម្ព័ន្ធនៃអគ្គាធិការដ្ឋាន (Inspector General) របស់




ខ្លួន ជាការិយាល័យចំនួន២ សំខាន់ៗគឺ÷

**ទី១. ការិយាល័យអធិការកិច្ច និងករណីពិសេស (Office of Inspection & Special Review)÷** ការិយាល័យនេះ ត្រូវទទួលខុសត្រូវលើការធ្វើអធិការកិច្ចការស៊ើបអង្កេត និងទទួលបន្ទុកលើពាក្យបណ្តឹង និងកំហុស ព្រមទាំងធ្វើអធិការកិច្ចផ្ទៃក្នុងលើក្រសួងយុត្តិធម៌ និងមហាអយ្យការ (Prosecutors office) ផងដែរ។

**ទី២. ការិយាល័យសវនកម្មនិងអធិការកិច្ច (Audit and Inspection Office)÷** ទទួលខុសត្រូវធ្វើអធិការកិច្ចលើអង្គភាពផ្សេងទៀត ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌ ក្រៅពីអង្គភាពដែលស្ថិតក្នុងសមត្ថកិច្ចនៃការិយាល័យខាងលើ។

## ២.ស្ថាប័នសវនកម្មកំពូល

**គណៈសវនកម្មនិងអធិការកិច្ច** (Board of Audit and Inspection) នៃសាធារណរដ្ឋកូរ៉េ គឺជាស្ថាប័នសវនកម្មកំពូល (Supreme Audit Institution) ដែលត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ដើម្បីបំពេញបេសកកម្មត្រួតពិនិត្យគណនីសាធារណៈនៃចំណូលចំណាយរបស់រដ្ឋ, ធ្វើសវនកម្មលើគណនីរបស់ក្រសួងស្ថាប័នរដ្ឋ និងធ្វើអធិការកិច្ចលើការបំពេញមុខងាររបស់ក្រសួងស្ថាប័ននិងមន្ត្រីរាជការបុគ្គលិករបស់ស្ថាប័នទាំងនោះ។

### ២.១.សមាសភាពនិងរចនាសម្ព័ន្ធ

ស្ថាប័នសវនកម្មកំពូលនេះ ត្រូវបានបង្កើតឡើងនៅក្រោមប្រធានាធិបតី ព្រោះប្រធានស្ថាប័ននេះ (Chairman) ដែលហៅថាអគ្គសវនករ ត្រូវបានតែងតាំងដោយប្រធានាធិបតី ដោយមានការយល់ព្រមពីសភា រីឯអង្គសវនកររង (Comissionner) ត្រូវតែងតាំងដោយប្រធានាធិបតីដូចគ្នាតាមសំណើរបស់អគ្គសវនករ។ ទោះយ៉ាងណា ស្ថាប័ននេះបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ ទៅតាមវិធីសាស្ត្រដែលខ្លួនកំណត់ ដោយមិនធ្វើតាមបង្គាប់បញ្ជារបស់ស្ថាប័ន ឬអាជ្ញាធរណាមួយឡើយ។ ស្ថាប័នសវនកម្មកំពូលរបស់កូរ៉េដឹកនាំដោយប្រធានរបស់ខ្លួន និងមានរចនាសម្ព័ន្ធគន្លឹះៗចំនួន២ គឺ÷

➢ **ក្រុមប្រឹក្សាសវនករ** (Council of Commissioners) ដែលមានអគ្គសវនករ ជាប្រធាន និងស្នងការទាំងអស់របស់ស្ថាប័ន។ ក្រុមប្រឹក្សានេះ ជាអង្គដែលត្រូវសម្រេចនូវគោលនយោបាយ ផែនការសកម្មភាពគន្លឹះ និងផែនការថវិកា ក៏ដូចជាការបិទបញ្ជីថវិការបស់ស្ថាប័ន ជាដើម។

➢ **អគ្គលេខាធិការដ្ឋាន** (Secretariat General) ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងចំនួន៤ រូប។ អគ្គលេខាធិការរងនីមួយៗ ទទួលបន្ទុកនូវនាយកដ្ឋានផ្សេងៗគ្នា ដែលមានសរុបចំនួន ២០ នាយកដ្ឋាន ដែលចែកចេញជា ៧០ ការិយាល័យក្រោមឱវាទ។

### ២.២.ភាពខុសគ្នានៃមុខងារសវនកម្ម និងមុខងារអធិការកិច្ចនៃស្ថាប័នសវនកម្មកំពូល

ច្បាប់ស្តីពីគណៈសវនកម្មនិងអធិការកិច្ច (Board of Audit and Inspection Act) បានកំណត់នូវវិធាន និងនីតិវិធីលម្អិតពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅ ដូចជាលក្ខន្តិកៈ សមាសភាព រចនាសម្ព័ន្ធ និង

ជាពិសេសមុខងារ និងភារកិច្ចរបស់ស្ថាប័ននេះ។ ដូចឈ្មោះរបស់ស្ថាប័ននេះបានបង្ហាញស្រាប់ គណៈសវនកម្មនិងអធិការកិច្ចមានតួនាទីគន្លឹះចំនួន២ គឺ *ទី១. ធ្វើសវនកម្ម* និង*ទី២. ធ្វើអធិការកិច្ច* ដែលមុខងារទាំង២នេះ ខុសពីគ្នា តែបំពេញឱ្យគ្នា។

*ចំពោះករណីកូរ៉េសវនកម្ម និងអធិការកិច្ច គឺជាមុខងារពីរផ្សេងគ្នា តែមុខងារទាំងពីរនេះ តែងតែនៅស្និទ្ធជាមួយគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក ដោយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធអង្គភាពគ្រប់គ្រងតែមួយ ទាំងនៅក្នុងក្របខណ្ឌស្ថាប័នសវនកម្មកំពូល និងក្នុងក្របខណ្ឌសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន។*

ច្បាប់ខាងលើ បានបែងចែកយ៉ាងច្បាស់លាស់ និងលម្អិតនូវបណ្តាករណីដែលត្រូវធ្វើសវនកម្មជាកាតព្វកិច្ច ករណីត្រូវធ្វើសវនកម្មតាមឆន្ទានុសិទ្ធិ និងករណីដែលត្រូវស្ថិតក្រោមវិសាលភាពនៃការបំពេញមុខងារអធិការកិច្ច។ ករណីត្រូវធ្វើសវនកម្មជាកាតព្វកិច្ចមានដូចជា គណនីរដ្ឋ, គណនីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពស្វយ័តថ្នាក់ក្រោមជាតិ, គណនីធនាគារកណ្តាល, គណនីអង្គភាព-ស្ថាប័នទាំងឡាយ ដែលត្រូវបានកំណត់ដោយច្បាប់ថាត្រូវដាក់ឱ្យធ្វើសវនកម្ម ជាដើម។ លើសពីនេះ ស្ថាប័នសវនកម្មកំពូល អាចធ្វើសវនកម្មដោយឆន្ទានុសិទ្ធិបាន បើសិនជាយល់ថាចាំបាច់ ឬបើសិនជាមានសំណើរបស់នាយករដ្ឋមន្ត្រី ហើយករណីទាំងនោះត្រូវបានកំណត់នៅក្នុងមាត្រា២៣ នៃច្បាប់ខាងលើ។

ដោយឡែក ករណីដែលត្រូវដាក់ឱ្យធ្វើអធិការកិច្ចត្រូវបានកំណត់នៅក្នុងមាត្រា ២៤ នៃច្បាប់ដដែល មានដូចជា កិច្ចការរបស់ស្ថាប័នរដ្ឋបាលរបស់រដ្ឋ ដែលមានក្រសួងស្ថាប័នរបស់រដ្ឋាភិបាល និងការបំពេញភារកិច្ចរបស់មន្ត្រីនៃស្ថាប័នទាំងនោះ, កិច្ចការរបស់រដ្ឋបាលខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពស្វយ័តថ្នាក់ក្រោមជាតិ ព្រមទាំងការបំពេញភារកិច្ចរបស់មន្ត្រីស្ថាប័នទាំងនោះជាដើម។

គួរកត់សម្គាល់ជាពិសេសថា ច្បាប់នេះបានបញ្ជាក់នូវកម្មវត្ថុគន្លឹះនៃការធ្វើសវនកម្ម និងអធិការកិច្ចយ៉ាងជាក់លាក់ បានសេចក្តីថាសវនកម្ម ត្រូវធ្វើទៅលើគណនី (Accounts) បានសេចក្តីថា**សវនកម្មគណនី** (Audit of Accounts) រីឯអធិការកិច្ចត្រូវធ្វើទៅលើការបំពេញភារកិច្ច (Duties) បានសេចក្តីថា**អធិការកិច្ចមុខងារភារកិច្ច** (Inspection of duties)។ ប្រការនេះអាចឱ្យយល់បានថា កម្មវត្ថុនៃការបែងចែកសមត្ថកិច្ចរវាងមុខងារសវនកម្ម និងអធិការកិច្ច គឺវិស័យ ដើម្បីកុំឱ្យមានការអនុវត្តត្រួតជាន់គ្នា។ បើផ្អែកលើអង្គការលេខនៃស្ថាប័នសវនកម្មកំពូលដូចមានខាងលើ នាយកដ្ឋាន ឬការិយាល័យពាក់ព័ន្ធនឹងមុខងារសវនកម្ម ត្រូវធ្វើសវនកម្មទៅលើចំណូល-ចំណាយនៃថវិកា ទៅតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន រីឯនាយកដ្ឋាន ឬការិយាល័យអធិការកិច្ច ត្រូវធ្វើអធិការកិច្ចទៅលើការបំពេញមុខងារនៃគ្រប់ស្ថាប័នទាំងអស់។

***កំណត់សម្គាល់ទី១៖*** *ចំពោះករណីកូរ៉េសវនកម្ម និងអធិការកិច្ច គឺជាមុខងារពីរផ្សេងពីគ្នា តែមុខងារទាំងពីរនេះ តែងតែនៅស្និទ្ធជាមួយគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក ដោយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធអង្គភាពគ្រប់គ្រងតែមួយ ទាំងនៅក្នុងក្របខណ្ឌស្ថាប័នសវនកម្មកំពូល និងក្នុងក្របខ័ណ្ឌសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន។*

## ៣.ទំនាក់ទំនងរវាងអង្គភាពសវនកម្មផ្ទៃក្នុង និងស្ថាប័នសវនកម្មកំពូល

### ៣.១.ស្ថាប័នសវនកម្មកំពូល ៖ តួអង្គនិម្មាបនករនៃប្រព័ន្ធសវនកម្មជាតិ






ចំពោះមុខងាររបស់គណៈសវនកម្ម និងអធិការកិច្ច ក្នុងទំនាក់ទំនងជាមួយនឹងសវនកម្មផ្ទៃក្នុង, ស្ថាប័ននេះ ដើរតួនាទីជាអ្នករៀបចំស្តង់ដារសវនកម្ម និងក្រមប្រតិបត្តិការសវនកម្មសម្រាប់សវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័នទាំងអស់។ ទន្ទឹមនេះ ស្ថាប័នសវនកម្មកំពូល ផ្តល់ការគាំទ្រដល់សវនកម្មផ្ទៃក្នុង ដែលអាចជាការផ្តល់យោបល់លើផែនការសវនកម្មឬវិធីសាស្ត្រសវនកម្មផងដែរ។ ប្រធានក្រសួង-ស្ថាប័នអាចនឹងស្នើសុំការគាំទ្រពីស្ថាប័នសវនកម្មកំពូល ដើម្បីជួយគាំទ្រមន្ត្រីសវនកររបស់ក្រសួងនៃរដ្ឋាភិបាល ដែលអាចធ្វើឡើងក្រោមទម្រង់ជាការផ្តល់ការបណ្តុះបណ្តាលផងដែរ។

### ៣.២. ក្រុមប្រឹក្សាសម្របសម្រួលសកម្មភាពសវនកម្ម

ច្បាប់ស្តីអំពីសវនកម្មផ្ទៃក្នុងវិស័យសាធារណៈ បានកំណត់ និងបែងចែកផងដែរនូវទំនាក់ទំនងរវាងសវនកម្មផ្ទៃក្នុងជាមួយនឹងស្ថាប័នសវនកម្មកំពូល ដើម្បីចៀសវាងនូវការបំពេញមុខងារត្រួតគ្នា។ ក្នុងន័យនេះ ច្បាប់បានតម្រូវឱ្យបង្កើតនូវយន្តការមួយ ដែលហៅថា “ក្រុមប្រឹក្សាសម្របសម្រួលសកម្មភាពសវនកម្ម” (Audit Activity Coordination Council) ដើម្បីពិគ្រោះយោបល់និងសម្របសម្រួលប្រព័ន្ធសវនកម្មទាំងមូលរបស់ជាតិទាំងសវនកម្មកំពូល និងសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន។ ក្រុមប្រឹក្សានេះ មានសមាសភាពត្រឹម២០ រូប ដោយមានអគ្គលេខាធិការនៃស្ថាប័នសវនកម្មកំពូលជាប្រធាន និងមានសមាជិកមួយចំនួនជាតំណាងក្រសួង-ស្ថាប័ន ដូចជាក្រសួងមហាផ្ទៃ ក្រសួងគ្រប់គ្រងបុគ្គលិក ក្រសួងហិរញ្ញវត្ថុ ជាដើម។ ក្រុមប្រឹក្សានេះ មានតួនាទីពិគ្រោះ និងសម្របសម្រួលលើបញ្ហាមួយចំនួន ដូចជាកិច្ចសហប្រតិបត្តិការរវាងសវនកម្មផ្ទៃក្នុងទាំងអស់, ផែនការពង្រឹងសកម្មភាពសវនកម្ម, ការលុបបំបាត់ការធ្វើសវនកម្មជាន់គ្នា, ស្តង់ដារសវនកម្ម និងបញ្ហាសំខាន់ៗផ្សេងទៀត។

### ៣.៣. ការហាមឃាត់លើការធ្វើសវនកម្មជាន់គ្នា

ចំណុចដ៏សំខាន់មួយទៀតពាក់ព័ន្ធវិធានគឺការហាមឃាត់ការធ្វើសវនកម្មជាន់គ្នា ច្បាប់ដែលបានកំណត់ថា បើសិនករណីណាមួយត្រូវបានធ្វើសវនកម្មដោយស្ថាប័នសវនកម្មកំពូលហើយ សវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័នមិនអាចធ្វើសវនកម្មលើករណីដដែលនោះទេ លើកលែងតែករណីពិសេសមួយចំនួនដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ដូចជាករណីថ្មីទើបរកឃើញ និងករណីសំខាន់មួយចំនួនតែប៉ុណ្ណោះ។

***កំណត់សម្គាល់ទី២៖*** *ស្ថាប័នសវនកម្មកំពូលកូរ៉េ មានចរិតលក្ខណៈមិនដូចស្ថាប័នដូចគ្នានៅក្នុងប្រទេសផ្សេងៗ នៅត្រង់ថាស្ថាប័ននេះ មានអាណត្តិកិច្ចធ្វើអធិការកិច្ចលើសមិទ្ធកម្ម (ការបំពេញមុខងារ និងភារកិច្ច) របស់ស្ថាប័នរដ្ឋ និងមន្ត្រីរាជការទាំងឡាយនៃស្ថាប័នទាំងនោះ។*

ច្បាប់ដែលបានតម្រូវឱ្យស្ថាប័នសវនកម្មកំពូល និងសវនកម្មផ្ទៃក្នុងតាមក្រសួង-ស្ថាប័ន ពិភាក្សាគ្នាលើការរៀបចំផែនការសវនកម្ម ដើម្បីចៀសវាងការធ្វើសវនកម្មជាន់គ្នា សំដៅធានាប្រសិទ្ធភាពនៃសវនកម្មទាំងស្រុង។ ការរៀបចំនូវប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងសវនកម្មក៏ត្រូវបានលើកឡើងផងដែរ ថាជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយបំពេញបន្ថែម ដើម្បីការធ្វើសុខដុមនីយកម្មនៃការបំពេញមុខងារសវនកម្មរវាងស្ថាប័នសវនកម្មទាំងអស់៕■

*រៀបចំដោយ៖ ផ្នែកការងារកែទម្រង់ទាំង៣ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃ អ.គ.ហ.*

# ទិដ្ឋភាពនៃតួនាទី ភារកិច្ច និងយន្តការស្ថាប័ននៃមុខងារសវនកម្ម និងអធិការកិច្ចក្នុងវិស័យសាធារណៈនៅកម្ពុជា

*ក្នុងរដ្ឋបាលសាធារណៈកម្ពុជា មុខងារត្រួតពិនិត្យមានអធិការកិច្ច និងសវនកម្មផ្ទៃក្នុង។ ដូច្នេះ ការបែងចែក ឬការធ្វើសុខដុមនីយកម្មសំដៅទៅការធានាបាននូវស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃអភិបាលកិច្ចសាធារណៈតាមរយៈការប្រើប្រាស់ឧករណ៍ត្រួតពិនិត្យ នៅជាបញ្ហាប្រឈមនៅឡើយ។*

ក្នុងន័យនេះ ក្រុមការងារអន្តរក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ ដើម្បីកំណត់ក្របខណ្ឌនៃការធ្វើសុខដុមនីយកម្មមុខងារត្រួតពិនិត្យខាងលើ ដែលមានសមាសភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច ក្រសួងមុខងារសាធារណៈ និងអាជ្ញាធរសវនកម្មជាតិ។ ជាក់ស្តែង នៃកិច្ចការនេះមានពីរទិដ្ឋភាពគឺការធ្វើសុខដុមនីយកម្មរវាងមុខងារនៃស្ថាប័ន និងការធ្វើសុខដុមនីយកម្មបទដ្ឋានគតិយុត្តដែលមានស្រាប់។ ក្នុងន័យនេះ អត្ថបទនេះមានគោលបំណងស្វែងយល់ពីមុខងារ សារតារ យន្តការស្ថាប័ន បទដ្ឋានគតិយុត្ត និងការសម្រេចថ្មីរបស់រាជរដ្ឋាភិបាលលើក្របខណ្ឌ មុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ផ្អែកតាមអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០។

## ក.តួនាទី ភារកិច្ច និងយន្តការស្ថាប័ននៃមុខងារសវនកម្ម

មុខងារសវនកម្មក្នុងរដ្ឋបាលសាធារណៈកម្ពុជាមាន២ ប្រភេទ គឺសវនកម្មផ្ទៃក្រៅ និងសវនកម្មផ្ទៃក្នុង។ ផ្អែកតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ-២០០០ មុខងារទាំងពីរនេះត្រូវបានបង្កើតឡើង ហើយច្បាប់នេះក៏បានបង្កើត អាជ្ញាធរសវនកម្មជាតិ បំពេញមុខងារសវនកម្មផ្ទៃក្រៅ និងអង្គភាពសវនកម្មផ្ទៃក្នុងបំពេញមុខងារសវនកម្មផ្ទៃក្នុង។

“សវនកម្មផ្ទៃក្រៅ គឺជាការពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីកាគណនេយ្យ ប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រង ដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជ-រដ្ឋាភិបាល ដើម្បីធានាថា**១.** បណ្តាសកម្មភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ តាមរយៈសេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍, **២.** បណ្តាសកម្មភាពទាំងនេះ ត្រូវបានអនុវត្តដោយអនុលោមតាមគោលការណ៍ គណនេយ្យទូទៅ និង **៣.**-ការត្រួតពិនិត្យនីតិវិធី និងការអនុវត្ត ដោយអនុលោមតាមច្បាប់ បទបញ្ជា កិច្ចព្រម-ព្រៀងប្រព័ន្ធគ្រប់គ្រង កិច្ចសន្យា កម្មវិធី និងលក្ខណៈវិនិច្ឆ័យផ្សេងទៀត ដែលទាក់-ទងដល់ចំណូលចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រាជរដ្ឋាភិបាល”[១]។ មុខងារនេះ គឺជាអាណត្តិកិច្ចនៃអាជ្ញាធរ-សវនកម្មជាតិ ដែលជាស្ថាប័នសវនកម្មកំពូល មានឯករាជ្យភាពគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចប្រតិបត្តិការរបស់ខ្លួនក្នុងការធ្វើសវនកម្មគ្រប់ក្រសួង- ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានរដ្ឋបាលសាធារណៈ និងសហគ្រាសសាធារណៈ ហើយអាជ្ញាធរ

*សវនកម្មផ្ទៃក្នុងមានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ និងគ្មានការរារាំង ការហាមឃាត់ លើការចូលរួមត្រួតពិនិត្យនូវគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រា រាល់ទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព។*

សវនកម្មជាតិ មានគណនេយ្យភាពផ្ទាល់ទៅកាន់ស្ថាប័ននីតិបញ្ញត្តិ។ ជារៀងរាល់ឆ្នាំ អាជ្ញាធរសវនកម្មជាតិ ត្រូវរៀបចំរបាយ-ការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងផ្ញើជូនទៅស្ថាប័ននីតិបញ្ញត្តិ ជាទៀងទាត់ ដើម្បីជាមូលដ្ឋានក្នុងការត្រួតពិនិត្យពិនិស្ច័យសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។ ដើម្បីបំពេញមុខងារ អាជ្ញាធរសវនកម្មជាតិបានបង្កើតនូវគោលការណ៍ណែនាំ ដូចជាសវនកម្មផ្អែកលើកិច្ចប្រតិបត្តិការ សវនកម្មផ្អែកលើអនុលោមភាព សវនកម្មហិរញ្ញវត្ថុ និងនីតិវិធីប្រភេទសវនកម្ម ដូចជាសវនកម្មគយនិងរដ្ឋាករ ។ល។

មុខងារ និងអង្គភាពសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើងយោងតាមច្បាប់ស្តីពី សវន-កម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០, អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាម

---

*[១] មាត្រាទី៤ នៃច្បាប់ស្តីពី សវនកម្មនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ២០០០*

បណ្តា ក្រសួង-ស្ថាប័ន និងសហគ្រាស-សាធារណៈ និងសារាចររាជរដ្ឋាភិបាល លេខ១២ សរណន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពី ការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ។ តួនាទីនៃសវនកម្មផ្ទៃក្នុង គឺត្រូវបានវាយតម្លៃដោយឯករាជ្យ នូវភាពសមស្រប គ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងនោះ ព្រមទាំងផ្តល់នូវការធានាលើភាពគ្រប់គ្រាន់របស់ប្រព័ន្ធត្រួតពិនិត្យដែលកំពុងមាន និងកំពុងដំណើរការទៅតាមគោលបំណង។ សវនកម្មផ្ទៃក្នុង មានសិទ្ធិពេញលេញ សេរីភាពគ្រប់-គ្រាន់ និងគ្មានការរារាំង ការហាមឃាត់លើការចូលរួមត្រួតពិនិត្យនូវគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រា រាល់ទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព[២]។ មុខងារនេះមានលក្ខណៈវិមជ្ឈការ ពោលគឺក្រសួង-ស្ថាប័ននីមួយៗ មានអង្គភាពសវនកម្មផ្ទៃក្នុង ហើយអនុវត្តលើសវនដ្ឋាន ដែលជាអង្គភាពក្រោមឱវាទក្រសួង-ស្ថាប័នខ្លួន។ ជារចនាសម្ព័ន្ធ, មុខងារសវនកម្មផ្ទៃក្នុង នៅតាមក្រសួង-ស្ថាប័ន ត្រូវបង្កើតឡើងតាមរយៈអនុក្រឹត្យជានាយកដ្ឋាន និងស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធានស្ថាប័ន។ ជាទូទៅ តួនាទី និងភារកិច្ចរបស់ អគ្គនាយកដ្ឋាន ឬនាយក-ដ្ឋានសវនកម្មផ្ទៃក្នុង នៅក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ ដោយផ្អែកលើ អនុក្រឹត្យលេខ ៤០ អនក្រ.បក និងបែងចែកជារចនាសម្ព័ន្ធចំណុះ ទៅតាមផែនសវនដ្ឋានដែលជារចនាសម្ព័ន្ធអង្គភាពចំណុះថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៃក្រសួង-ស្ថាប័ន ពោលគឺ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បែងចែក


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង
នៅតាមបណ្តា ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

77

សម្រេច

ជំពូក ទី១
បទប្បញ្ញត្តិទូទៅ

ជំពូក ទី២

78

២ មាត្រាទី២ នៃ អនុក្រឹត្យ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តា ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ។

ទៅជាការិយាល័យសវនកម្ម មួយចំនួន ដែលទទួលបន្ទុកលើ អគ្គនាយកដ្ឋានកម្រិតថ្នាក់ជាតិ និងមន្ទីរ រាជធានី-ខេត្ត រៀងៗខ្លួន។ ក្នុងទិដ្ឋភាពនៃយន្តការស្ថាប័ន អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីជាអង្គភាពសវនកម្មផ្ទៃក្នុងនៃស្ថាប័នខ្លួនផង និងជាតួអង្គដឹកនាំអភិវឌ្ឍមុខងារផង។ ជាក់ស្តែង គោលការណ៍ណែនាំស្តីពីសវនកម្មសមិទ្ធកម្ម និងគោលការណ៍ណែនាំស្តីពីសវនកម្មលើប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ ហើយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង កសហវ. ក៏បានរៀបចំការបណ្តុះបណ្តាលទៅដល់អង្គភាពសវនកម្មផ្ទៃក្នុង នៅតាមក្រសួង-ស្ថាប័នផងដែរ។ ជាយន្តការសម្របសម្រួលនៃមុខងារទាំងពីរនេះ អង្គភាពសវនកម្មផ្ទៃក្នុង មានកាតព្វកិច្ចក្នុងការបញ្ជូនផែនការសវនកម្មប្រចាំឆ្នាំ និងរបាយការណ៍សវនកម្មផ្ទៃក្នុងទៅអាជ្ញាធរសវនកម្មជាតិ។ រីឯក្នុងទិដ្ឋភាពបច្ចេកទេស ស្ថាប័នឬអង្គភាពទាំងពីរ(អាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង) ហាក់ដូចជាអនុវត្តដាច់ឆ្ងាយពីគ្នា ពោលពុំទាន់មានយន្តការសម្របសម្រួលជាក់លាក់ក្នុងការស្វែងយល់ពីគ្នាទៅវិញទៅមក និងការរៀបចំគោលការណ៍សវនកម្ម ដែលរួមមួយនៅឡើយទេ។ បច្ចុប្បន្ននេះ អង្គភាពសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន ទទួលបានការបណ្តុះបណ្តាល២ ផ្សេងគ្នា ជុំវិញគោលការណ៍ណែនាំសវនកម្មសមិទ្ធកម្ម ឬគោលការណ៍ណែនាំសវនកម្មកិច្ចប្រតិបត្តិការ។




### ខ.តួនាទី ភារកិច្ច និងយន្តការស្ថាប័ន នៃមុខងារអធិការកិច្ច

មុខងាររបស់អធិការកិច្ចក្នុងរចនាសម្ព័ន្ធ ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា អាចសន្ទតក្នុងការបែងចែកជា២ កម្រិត÷ (១) អធិការកិច្ចរាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន (២) អធិការកិច្ចតាមវិស័យ ដែលមាននៅតាមក្រសួង-ស្ថាប័នជាទូទៅ។

មុខងារអធិការកិច្ចហិរញ្ញវត្ថុ ស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលវិសាលភាពនៃការអនុវត្តដល់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ[៣]។ អគ្គាធិការដ្ឋានជាសេនាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មការធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយប្រើអភិក្រម

[៣] មាត្រាទី ៧២ និង ៨៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨

[៤] ប្រកាសលេខ ១៥៥៦ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



“អធិការកិច្ចផ្អែកលើអនុលោមភាពហានិភ័យ ករណីសង្ស័យ ឬបណ្តឹងបរិហារជាក់ស្តែង[៤]”។

អគ្គាធិការដ្ឋានក្រសួងមុខងារសាធារណៈ បំពេញមុខងារអធិការកិច្ចមុខងារសាធារណៈ ដែលជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាលលើអធិការកិច្ចមុខងារសាធារណៈ ស្របតាមប្រកាសលេខ ១១០៥ មស ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋានមុខងារសាធារណៈ។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ត្រូវបានបង្កើតដោយច្បាប់ក្នុងឆ្នាំ១៩៩៩ កំណត់ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំ និងគ្រប់គ្រង រាល់កិច្ចការសម្របសម្រួល ធ្វើទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងធ្វើការងារអធិការកិច្ច លើគ្រប់វិស័យ ក្នុងព្រះរាជាណាចក្រកម្ពុជាសំដៅបង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា។ មុខសញ្ញាការអនុវត្តអធិការកិច្ច រួមមាន ÷ (១) ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ការគ្រប់គ្រងប្រើប្រាស់ជំនួយ និងទ្រព្យសម្បត្តិរដ្ឋ (២) នីតិវិធី បច្ចេកទេស និងការអនុវត្តកិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រងកិច្ចសន្យា កម្មវិធី ពាក់ព័ន្ធនឹងចំណូលចំណាយ និងការប្រើប្រាស់ថវិការដ្ឋ (៣) ធ្វើអធិការកិច្ចឡើងវិញ ករណីមានការតវ៉ា[៥]។

ក្រៅពីមុខងារអធិការកិច្ចខាងលើ គឺជាអធិការកិច្ចតាមវិស័យ ដែលមានក្រសួង-ស្ថាប័នជាតួអង្គបំពេញមុខងារនោះ។ ផ្អែកលើក្របខណ្ឌគតិយុត្តនៃការរៀបចំ និងការប្រព្រឹត្តនៃក្រសួង-ស្ថាប័នជារួម អធិការដ្ឋាន ឬអគ្គាធិការដ្ឋាន ទទួលបន្ទុកលើកិច្ចការងារអធិការកិច្ចរដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក និងលើវិស័យ។ ជានិច្ចកាល អធិការដ្ឋាន ឬអគ្គាធិការដ្ឋាន បានកំណត់នូវអភិក្រមក្នុងការអនុវត្តថា “ធ្វើអធិការកិច្ចជាប្រចាំលើអង្គភាពក្រោមឱវាទ”។ ដោយឡែកសម្រាប់ស្ថាប័នខ្លះ អធិការកិច្ចវិស័យពុំមែនជាអាណត្តិកិច្ច របស់អគ្គាធិការដ្ឋាន ឬអធិការដ្ឋានទេ ប៉ុន្តែជាមុខងារដែលត្រូវ

*អធិការកិច្ចហិរញ្ញវត្ថុ ត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការបច្ចេកទេស របស់រាជរដ្ឋាភិបាលលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ នៅក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នីតិបុគ្គលសាធារណៈ និងឯកជន ដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ស្របតាមច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ*

បំពេញដោយអគ្គនាយកដ្ឋានជំនាញទៅវិញ ជាឧទាហរណ៍ជាក់ស្តែង គឺករណីអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងអគ្គាធិការដ្ឋាននៃក្រសួងពាណិជ្ជកម្ម[៦]។

លើសពីនេះ កិច្ចការអធិការកិច្ចលើវិស័យខ្លះ ត្រូវបានរៀបចំជា ក្រុមការងារបច្ចេកទេសអន្តរក្រសួង លើកិច្ចការដែលពាក់ព័ន្ធជាអន្តរវិស័យ ដូចជាក្រុមការងារអធិការកិច្ចអន្តរក្រសួងក្នុងវិស័យឧស្សាហកម្មទេសចរណ៍ ដែលត្រូវបង្កើតឡើង តាមប្រកាសអន្តរក្រសួងលេខ ០៧២/២០ ក.ប/ប្រ.ក.ខ.ល នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍ និងក្រុមការងារអធិការកិច្ចអន្តរក្រសួងក្នុងវិស័យកម្មន្តសាល ដែលត្រូវបង្កើតឡើង តាមរយៈប្រកាសអន្តរក្រសួងលេខ០៧៣/២០ ក.ប/ប្រ.ក.ខ.ល នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងបរិស្ថាន។ ក្រុមការងារនេះ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងចុះធ្វើអធិការកិច្ចរួមគ្នាក្នុងពេលតែមួយលើ សហគ្រាស គ្រឹះស្ថាន-

[៥] ជំពូកទី៦ នៃអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

[៦] អនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

សាធារណៈ និងឯកជន ពាក់ព័ន្ធ។

### គ.សុខដុមនីយកម្មមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច

អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច មានគោលបំណងបញ្ចៀសការអនុវត្តស្ទួនគ្នា នៃមុខងារសវនកម្មផ្ទៃក្នុងរបស់បណ្តាក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ អធិការកិច្ចរបស់ក្រសួង-ស្ថាប័ន អធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អធិការកិច្ចមុខងារសាធារណៈរបស់ក្រសួងមុខងារសាធារណៈ អធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ក្នុងន័យនេះ វាក្យស័ព្ទបច្ចេកទេសថ្មីក្នុងការកំណត់មុខងារអធិការកិច្ចមាន÷ អធិការកិច្ចរដ្ឋាភិបាល (ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច) អធិការកិច្ចជំនាញសេនាធិការបច្ចេកទេសរបស់រដ្ឋាភិបាល (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ) និងអធិការកិច្ចតាមវិស័យ (ក្រសួង-ស្ថាប័នផ្សេងទៀត)។

អធិការកិច្ចហិរញ្ញវត្ថុ ត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋនៅក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាល-រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នីតិបុគ្គលសាធារណៈ និងឯកជន ដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈស្របតាមច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ រីឯ អធិការកិច្ចមុខងារសាធារណៈត្រូវអនុវត្តដោយក្រសួងមុខងារសាធារណៈ ដែលជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាលលើការងារមុខងារសាធារណៈ។

ចំពោះអធិការកិច្ចនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កំណត់ជាអធិការកិច្ចរាជរដ្ឋាភិបាល និងមានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់វិស័យ ដោយផ្អែកលើអភិក្រមដូចជា ÷

- តាមបណ្តឹងតវ៉ា និងបណ្តឹងបរិហារពីនីតិបុគ្គល រូបវន្តបុគ្គល និងគ្រប់មជ្ឈដ្ឋាន
- តាមបណ្តឹងរបស់ស្ថាប័នរងអធិការកិច្ចលើលទ្ធផលអធិការកិច្ច របស់ក្រសួង-ស្ថាប័ន
- ផ្អែកលើហានិភ័យ បណ្តឹងតវ៉ា ឬភាពចាំបាច់ក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន ឬរបាយ-ការណ៍ពាក់ព័ន្ធ
- តាមសំណើរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលសហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដានរាល់នូវវិធានការដែលអធិការ-កិច្ចបានដាក់ចេញដល់ស្ថាប័នរងអធិការ-កិច្ច និង
- តាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

ការចុះធ្វើអធិការកិច្ចរបស់ក្រសួងទំនាក់-ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការ-កិច្ច ត្រូវផ្តល់ដំណឹងជូនអធិការកិច្ចរបស់ក្រសួង-ស្ថាប័ន ដើម្បីសហការលើកលែងតែ÷ (១) តាមបណ្តឹងរបស់ស្ថាប័នរងអធិការកិច្ចលើលទ្ធផលអធិការកិច្ច របស់ក្រសួង-ស្ថាប័ន (២) តាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

រាល់កិច្ចអនុវត្តអធិការកិច្ច ត្រូវរៀបចំជារបាយការណ៍លទ្ធផលជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការ-កិច្ច ក្នុងរយៈពេលបីខែ។ ជារបបរាយការណ៍ប្រចាំឆ្នាំ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន មានកាតព្វកិច្ចក្នុងការរាយការណ៍លើលទ្ធផលអធិការកិច្ចប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការ-កិច្ច។

ជាជំហានបន្ទាប់ របៀបរបបបំពេញការងាររវាងសវនកម្មផ្ទៃក្នុង អគ្គាធិការដ្ឋាន ឬអធិការដ្ឋាននៃក្រសួង-ស្ថាប័នដទៃ ត្រូវត្រួតពិនិត្យឡើងវិញ និងបែងចែកភារកិច្ចដើម្បីចៀសវាងការស្ទួនគ្នាលើការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន។ ប៉ុន្តែសំណួរនៅត្រង់ថា អគ្គាធិការដ្ឋាន ឬអធិ-ការដ្ឋាននៃក្រសួង-ស្ថាប័ន នឹងនៅបន្តធ្វើអធិការកិច្ចលើការងារហិរញ្ញវត្ថុ រដ្ឋបាល និងបុគ្គលិកលើអង្គភាពក្រោមឱវាទ ស្របតាមបទដ្ឋានគតិយុត្តរបស់ខ្លួន ដែលមានស្រាប់បាន ដែរឬទេ?

ជារួម ជំហានដំបូងនៃការធ្វើសុខដុម-នីយកម្មនេះ បានសម្រេចពាក់ព័ន្ធនឹងមុខងារអធិការកិច្ចលើទិដ្ឋភាព២ យ៉ាងគឺ កម្រិតអធិការកិច្ច (រដ្ឋាភិបាល សេនាធិការបច្ចេកទេស និងវិស័យ) យន្តការរាយការណ៍ និងអភិក្រមនៃការអនុវត្ត ដែលគួររំលេចថា ការធ្វើអធិការកិច្ចនឹងពុំត្រូវបានអនុវត្តជាប្រចាំទៀតឡើយ តែត្រូវផ្តោតលើហានិ-ភ័យ និងបណ្តឹងជាក់ស្តែង។ យ៉ាងណាមិញ មុខងារអធិការកិច្ចនៅខ្វះខាតក្របខណ្ឌរួមដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពក្នុងការអនុវត្ត ដែលខុសឆ្ងាយពីមុខងារសវនកម្មពោលមុខងារសវនកម្មមានច្បាប់ អនុក្រឹត្យនិងគោលការណ៍ណែនាំផ្សេងៗ គាំទ្រគ្រប់ទិដ្ឋភាព នៃការរៀបចំស្ថាប័ន យន្តការសម្របសម្រួល ការកសាង សមត្ថ-ភាព និងនីតិវិធីបច្ចេកទេសនានា។

ជាវឌ្ឍនភាព និងទិសដៅ ក្រសួងទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច បាននិងកំពុងដឹកនាំរៀបចំ និងគ្រោងបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចនាពេលខាងមុខ៕■

*រៀបចំដោយ÷ ផ្នែកការងារកែទម្រង់ទាំង៣ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃ អ.គ.ហ.*

# បទពិសោធស្តីពីការអនុវត្តទំនាក់ទំនង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ប្រសិទ្ធភាពនៃទំនាក់ទំនងគឺជាមូលដ្ឋានដ៏ចាំបាច់ក្នុងការបង្កើនកិច្ចសហការអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាល។ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ជាសេនាធិការជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(គ.ហ.ស.) ហើយមានភារកិច្ចសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង-ស្ថាប័ន ដើម្បីបញ្ជ្រាបការយល់ដឹងពីទិសដៅកែទម្រង់ និងដោះស្រាយបញ្ហាប្រឈមរបស់អង្គភាពពាក់ព័ន្ធលើការរៀបចំ និងអនុវត្តផែនការសកម្មភាពកែទម្រង់របស់អង្គភាពសាមី ។*

ស្របពេលដែលផែនការសកម្មភាពរួមពាបូក២ ត្រូវបានអនុម័ត, កិច្ចសម្របសម្រួលទំនាក់ទំនងរវាង **អ.គ.ហ.** ជាមួយអង្គភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាំបាច់ត្រូវមានការតម្រឹមឱ្យមានសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នាទៅនឹងបម្រែបម្រួលនៃអាទិភាព។ ក្នុងឆ្នាំ២០២១ នេះ, **អ.គ.ហ.** បានរៀបចំធ្វើអង្កេតស្ទង់មតិពីទស្សនៈ និងក្តីបារម្ភនានាពាក់ព័ន្ធនឹងទំនាក់ទំនង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការអង្កេតនេះមានចូលរួមផ្តល់ទិន្នន័យ និងមតិយោបល់ពីអង្គភាពអនុវត្តកម្មវិធីកែទម្រង់ទាំងអស់លើមុខសញ្ញាវិភាគសំខាន់ៗ (ឧទាហរណ៍÷ មធ្យោបាយទំនាក់ទំនង, ភាពញឹកញាប់នៃទំនាក់ទំនង, ខ្លឹមសារទំនាក់ទំនងជាដើម) ដើម្បីកត់សម្គាល់ពីបែបបទនៃទំនាក់ទំនងក្នុងការយល់ដឹងពីគោលបំណង និងទិសដៅនៃសកម្មភាពកែទម្រង់ ព្រមទាំងផ្តល់ជាគំនិតផ្តួចផ្តើម និងការចូលរួមអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្រោមកិច្ចសហការរវាង **អ.គ.ហ.** និងធនាគារពិភពលោក, សេចក្តីព្រាងរបាយការណ៍វិភាគទិន្នន័យអង្កេតស្តីពីទំនាក់ទំនង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំដោយជំនាញការអន្តរជាតិ ក្នុងគោលបំណងសម្រិតសម្រាំងមតិយោបល់ និងអនុសាសន៍ល្អៗ សម្រាប់ពង្រឹងទំនាក់ទំនងលើកិច្ចសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**<u>ការឆ្លើយតបនិងទស្សនៈអង្គភាពអនុវត្តកម្មវិធីកែទម្រង់÷ មធ្យោបាយទំនាក់ទំនង</u>**







វិភាគដោយជំនាញការអន្តរជាតិរបស់ធនាគារពិភពលោក

ការវិភាគផ្តោតលើទិដ្ឋភាពគន្លឹះចំនួន ២ រួមមាន÷

**ទី១.ទំនាក់ទំនងរវាង អ.គ.ហ. និង អង្គភាពអនុវត្តកម្មវិធីកែទម្រង់**

● ការវិភាគទិន្នន័យអង្កេតបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់ ដោយមានអង្គភាពអនុវត្តកម្មវិធីកែទម្រង់ចំនួន៤៤ ផ្តល់ការឆ្លើយតបនឹងកម្រងសំណួរ ហើយផ្អែកតាមដំណើរការ និងនីតិវិធីដែលមានការពាក់ព័ន្ធខ្លាំងនឹងអង្គភាពនីមួយៗ ។

● ការឆ្លើយតបរបស់អង្គភាពភាគច្រើនបានបង្ហាញថា សមាសភាពជាសមាជិកនៃក្រុមការងារកែទម្រង់មានការយល់ដឹងពីសមាសធាតុនៃកម្មវិធីកែទម្រង់ ប៉ុន្តែការយល់ដឹងនេះ ហាក់ពុំមានសង្គតិភាព ឬនិន្នាការរួមលើទិសដៅ នៃការជំរុញការនៅតាមអង្គភាពនីមួយៗហាក់ដូចជាប្រព្រឹត្តទៅតាមអភិក្រម២ ផ្សេងគ្នាគឺ (១) ប្រធានក្រុមការងារកែទម្រង់ដឹកនាំកិច្ចប្រជុំពិភាក្សា និងរៀបចំផែនការរួមគ្នា (៥២%) និង (២) ប្រធានក្រុមកែទម្រង់ចាត់មន្ត្រីបង្គោលរៀបចំ ហើយពិនិត្យសម្រេច (៤៣%)។ ហេតុនេះ, ដើម្បីបង្កើនទម្ងន់សម្រាប់ទាញការសន្និដ្ឋានពីរបៀបរៀបនៃការចំផែនការ

**ការឆ្លើយតបនិងទស្សនៈអង្គភាពអនុវត្តកម្មវិធីកែទម្រង់÷ ការចូលរួមកំណត់អាទិភាពនិងរៀបចំផែនការសកម្មភាពកែទម្រង់**







វិភាគដោយជំនាញការអន្តរជាតិរបស់ធនាគារពិភពលោក

ការណែនាំឱ្យមានការពិភាក្សាផ្ទៃក្នុងលើការឆ្លើយតប, អង្គភាពចំនួន៣៨ ផ្ញើការឆ្លើយតបមក **អ.គ.ហ.** ដោយជនបង្គោលមានតួនាទីយ៉ាងទាបត្រឹមកម្រិតអនុប្រធាននាយកដ្ឋាន ឬប្រហាក់ប្រហែល។

● ក្នុងចំណោមអង្គភាពផ្ញើការឆ្លើយតបសរុប, អង្គភាពភាគច្រើនប្រើប្រាស់លិខិតផ្លូវការ, ប្រព័ន្ធទំនាក់ទំនងតាមទូរសព្ទ និងកិច្ចប្រជុំ សម្រាប់ជាមធ្យោបាយទំនាក់ទំនងក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈហើយតាមរយៈមធ្យោបាយនេះ, អង្គភាពបានទទួលនូវព័ត៌មានពីកម្មវិធីកែទម្រង់យ៉ាងតិចមួយដងក្នុងមួយសប្តាហ៍។ ទន្ទឹមនឹងការសម្តែងក្តីសោមនស្សចំពោះមធ្យោបាយ និងកិច្ចដំណើរការទំនាក់ទំនងបច្ចុប្បន្ន, អង្គភាពក៏បង្ហាញទស្សនៈចង់ឱ្យមានការបន្ថែមខ្លឹមសារលើព័ត៌មានពិសេសលើកិច្ចការកែទម្រង់, ជំនាញថ្មីៗ, កែទម្រង់ទេ។ កត្តានេះតោងទាមឱ្យមានការគិតគូរស្វែងយល់ ហើយសម្រួចកម្មវិធីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីកែទម្រង់បន្ថែម។

● របាយការណ៍វិភាគបានព្យាយាមស្វែងយល់ពីការចូលរួមអនុវត្តកម្មវិធីកែទម្រង់ ដោយពិនិត្យពីការកំណត់ និងការតាមដានវឌ្ឍនភាពសូចនាករសមិទ្ធកម្ម នៃផែនការសកម្មភាពកែទម្រង់របស់អង្គភាពអនុវត្ត។ លទ្ធផលនៃការវិភាគទិន្នន័យបង្ហាញអភិក្រមតុល្យភាព (balanced approach) ពោលគឺទន្ទឹមនឹងការបញ្ចូលអាទិភាព ដែលជាសេចក្តីសម្រេចរបស់ **គ.ហ.ស.** ក្នុងផែនការសកម្មភាព, អង្គភាពនីមួយៗ ក៏មានការផ្តួចផ្តើមផ្ទាល់ខ្លួនក្នុងការកំណត់អាទិភាពកែទម្រង់ផងដែរ។

**ទី២.ការចូលរួមអនុវត្តកម្មវិធីកែទម្រង់**

● ការរៀបចំផែនការសកម្មភាពកែទម្រង់សកម្មភាពកែទម្រង់តាមអង្គភាពនីមួយៗ, គឺតោងទាមឱ្យមានការសិក្សាស្វែងយល់បន្ថែម។

● អង្គភាពផ្តល់ការឆ្លើយតបភាគច្រើនបញ្ជាក់ពីយន្តការតាមដានវឌ្ឍនភាពនៃផែនការសកម្មភាពកែទម្រង់ ដោយមានរបបប្រជុំប្រចាំខែ (៣៧%) និងប្រជុំប្រចាំ

**ការឆ្លើយតបនិងទស្សនៈអង្គភាពអ**



*ក្រៅពីការចូលរួមដឹកនាំការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាពកែទម្រង់ ពីប្រធានក្រុមការងារកែទម្រង់តាមអង្គភាព ទិន្នន័យក៏បានបង្ហាញថា ប្រធានក្រុមការងារទាំងនោះក៏បានចូលរួមសកម្មភាពផ្សេងទៀតនៃកម្មវិធីកែទម្រង់ ដូចជាសកម្មភាពអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិភាក្សាពីនីតិវិធីការងារ ពិភាក្សាពីការរៀបចំគោលនយោបាយ និងសិក្ខាសាលាផ្សព្វផ្សាយ*

ត្រីមាស (៥៩%) ព្រមទាំងការចូលរួមពិនិត្យ និងពិភាក្សាវឌ្ឍនភាពពីសមាសភាពភាគច្រើន (សមាជិកប្រមាណ៧៦% ចូលរួមប្រជុំ) និងមានរៀបចំជារបាយការណ៍ប្រជុំ (៧២%) ផងដែរ។

● ក្រៅពីការចូលរួមដឹកនាំការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាពកែទម្រង់ ពីប្រធានក្រុមការងារកែទម្រង់តាមអង្គភាព, ទិន្នន័យក៏បង្ហាញថា ប្រធានក្រុមការងារទាំងនោះក៏បានចូលរួមសកម្មភាពផ្សេងទៀតនៃកម្មវិធីកែទម្រង់ ដូចជាសកម្មភាពអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ពិភាក្សាពីនីតិវិធីការងារ, ពិភាក្សាពីការរៀបចំគោលនយោបាយ និងសិក្ខាសាលាផ្សព្វផ្សាយ ។ល។ ទិន្នន័យអង្កេតនេះរំលេចពីទស្សនៈវិជ្ជមាន និងចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំ និងសមាសភាពក្រុមការងារកែទម្រង់តាមអង្គភាព ក្នុងការចូលរួមពិភាក្សារៀបចំគោលនយោបាយ និងនីតិវិធីការងារការកែទម្រង់ ដែលមានការពាក់ព័ន្ធនឹងអង្គភាពសាមី។

លើមូលដ្ឋាននៃលទ្ធផលវិភាគខាងលើ, **អ.គ.ហ.** ដឹកនាំពិភាក្សាអនុសាសន៍របស់ជំនាញការអន្តរជាតិ ហើយផ្អែកតាមស្មារតីនៃកិច្ចពិភាក្សា, **អ.គ.ហ.** ពិនិត្យឃើញចំណុច គួរតែកែលម្អការអនុវត្តទំនាក់ទំនងលើចំណុចមួយចំនួន រួមមាន (១) ការផ្សព្វផ្សាយនូវខ្លឹមសារសំខាន់ៗ និងជាគន្លឹះនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) ការប្រើប្រាស់មធ្យោបាយទំនាក់ទំនងឱ្យមានប្រសិទ្ធភាព (ឬលក្ខណៈ optimization), (៣) អនុវត្តទំនាក់ទំនងក្នុងកម្រិតមួយ ដែលនឹងឆ្លើយតបទៅនឹងក្តីរំពឹងរបស់អង្គភាពក្រោមឱវាទ កសហវ. និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង ស្ថាប័ន, និង (៤) ផ្សព្វផ្សាយខ្លឹមសារ ព័ត៌មាន ដែលពាក់ព័ន្ធនឹងបរិបទនៃអង្គភាពក្រោមឱវាទ កសហវ. និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង-ស្ថាប័ន នីមួយៗ។ ជាមួយគ្នានេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏គួរតែពង្រឹងការចូលរួមអនុវត្តការងារកែទម្រង់ ដោយផ្តោតលើ (១). ផ្តល់ការលើកទឹកចិត្តឱ្យមានការចូលរួមក្នុងកម្រិតផ្សេងៗគ្នានៃសមាជិកក្នុងក្រុមការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន, និង (២). បង្កើនប្រសិទ្ធភាពនៃការចូលរួម (optimize the involvement) របស់ថ្នាក់ដឹកនាំនៅតាមអង្គភាពក្រោមឱវាទ កសហវ. និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង-ស្ថាប័ន ដើម្បីជំរុញការគាំទ្រអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមអង្គភាពសាមី។

ជារួម, កិច្ចសហការរវាង **អ.គ.ហ.** និងធនាគារពិភពលោកលើការធ្វើអង្កេតស្តីពីទំនាក់ទំនង និងការចូលរួមអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានផលិតនូវរបាយការណ៍វិភាគមួយ ដែលនាំមកនូវការពិភាក្សា និងសម្រិតសម្រាំងអនុសាសន៍របស់ជំនាញការអន្តរជាតិ ដើម្បីរៀបចំសេចក្តីព្រាងផែនការសកម្មភាពសម្រាប់បញ្ចូលទៅក្នុងឯកសារទស្សនាទានស្តីពីការពង្រឹងទំនាក់ទំនង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ឯកសារទស្សនាទាននេះនឹងបំផុសឱ្យមានការគិតគូររៀបចំជាផែនការយុទ្ធសាស្ត្រជាក់លាក់ សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលបច្ចុប្បន្ន និងបន្ទាប់៕■

*រៀបចំដោយ៖ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃនៃ អ.គ.ហ.*

**<u>នុវត្តកម្មវិធីកែទម្រង់៖ យន្តការតាមដានវឌ្ឍនភាពនិងបង្កើនការចូលរួមអនុវត្តការងារកែទម្រង់</u>**







វិភាគដោយជំនាញការអន្តរជាតិរបស់ធនាគារពិភពលោក

# ការដាក់ឱ្យអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទាំងស្រុង ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័ន

*គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២១ នេះ ក្រសួង- ស្ថាប័នចំនួន២៧ បានអនុវត្តនីតិវិធីថ្មីលើការបើកផ្តល់បៀវត្ស និង ចំណាយបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ និង ក្រសួងចំនួន៨ អនុវត្តនីតិវិធីថ្មីលើការទូទាត់ត្រង់។*

*ក្រសួងចំនួន៨ ដែលបានអនុវត្តនីតិវិធីថ្មីលើការទូទាត់ត្រង់ដែលមានហានិភ័យទាប*

*ប្រភព÷ លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS*

ស្របតាមផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ២០២០ - ២០២៥ នៅក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងFMIS បានសម្របសម្រួលដាក់ឱ្យអនុវត្តដោយជោគជ័យនូវនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និង ចំណាយបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់និងចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប តាមប្រព័ន្ធ FMIS ទាំងស្រុង ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នចំនួន៧ (ព្រមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្តាល) រួមមាន÷ ១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ៣. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ៤. ក្រសួងមុខងារសាធារណៈ, ៥. ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍, ៦. ក្រសួងសុខាភិបាល, និង៧. ក្រសួងអប់រំ យុវជន និងកីឡា បានរួចរាល់ជាស្ថាពរនៅក្នុងឆ្នាំ២០២០។

នីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និង ចំណាយបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ គ្របដណ្តប់លើមុខសញ្ញាចំណាយចំនួន ១៣ ដូចជា÷

*១. ប្រាក់បំណាច់រដ្ឋមន្ត្រី រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ*
*២. លាភការទីប្រឹក្សា*
*៣. លាភការជំនួយការ*
*៤. បៀវត្សមូលដ្ឋាន*
*៥. ប្រាក់បំណាច់មុខងារ*
*៦. បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា*
*៧. អ្នកសម្រាលកូន*
*៨. ឧបត្ថម្ភនិវត្តជន*
*៩. ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ*



*១០. កូនមានអាយុចាប់ពី២០ឆ្នាំចុះ*
*១១. ប្រាក់បំណាច់អ្នកក្នុងបន្ទុក*
*១២. ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ*
*១៣. បន្ទុកបុគ្គលិកផ្សេងៗទៀត។*

ចំណែកនីតិវិធីថ្មីសម្រាប់ចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបគ្របដណ្តប់ទៅលើមុខសញ្ញាចំណាយចំនួន៩ រួមមានចំណាយលើ÷

*១. ថ្លៃប្រើប្រាស់អគ្គិសនី*
*២. ថ្លៃប្រើប្រាស់ទឹកស្អាត*
*៣. ថ្លៃប្រមូលសំរាម និងកាកសំណល់រឹង-រាវ ដែលមានកិច្ចសន្យា ឬកិច្ចព្រមព្រៀង*
*៤. ប្រាក់កម្រៃភ្នាក់ងារបរទេសជាប់កិច្ចសន្យា ដែលមានគោលការណ៍ពីរាជរដ្ឋាភិបាល*
*៥. ថ្លៃជាវសៀវភៅរាជកិច្ច ដែលផ្គត់ផ្គង់ដោយទីស្តីការគណៈរដ្ឋមន្ត្រី*
*៦. សោហ៊ុយប្រៃសណីយ៍ ដែលផ្តល់សេវាដោយប្រៃសណីយ៍កម្ពុជា*
*៧. សោហ៊ុយទូរគមនាគមន៍ ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា*
*៨. ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស ដែលមានគោលរបបកំណត់*
*៩. លតាប័ត្រសម្រាប់បង់ពន្ធយានយន្តប្រចាំឆ្នាំ (មធ្យោបាយដឹកជញ្ជូន)។*

អង្គភាពដែលចូលរួមអនុវត្តនីតិវិធីថ្មីខាងលើ រួមមានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលនៃក្រសួង-ស្ថាប័ននីមួយៗ ដែលបានទទួលការប្រគល់សិទ្ធិពីអាណាប័កដើមខ្សែលើមុខសញ្ញាចំណាយខាងលើ រួមទាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង-ស្ថាប័ននិងអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ នេះ លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានបន្តអនុវត្តនូវនីតិវិធីថ្មីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ តាមប្រព័ន្ធ FMIS ទាំងស្រុង ទៅកាន់ក្រសួង-ស្ថាប័នចំនួន១៩ បន្ថែមទៀត រួមមាន÷ (១) ក្រសួងព្រះបរមរាជវាំង, (២) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, (៣) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, (៤) ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, (៥) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, (៦) ក្រសួងរ៉ែ និងថាមពល, (៧) ក្រសួងផែនការ, (៨) ក្រសួងពាណិជ្ជកម្ម, (៩) ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ, (១០) ក្រសួងបរិស្ថាន, (១១) ក្រសួងអភិវឌ្ឍន៍ជនបទ, (១២) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, (១៣) ក្រសួងធម្មការ និងសាសនា, (១៤) ក្រសួងកិច្ចការនារី, (១៥) ក្រសួងសាធារណការ និងដឹកជញ្ជូន, (១៦) ក្រសួងទេសចរណ៍, (១៧) ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់, (១៨) ក្រសួងធនធានទឹក និងឧតុនិយម និង (១៩) ក្រសួងព័ត៌មាន។ ជាមួយគ្នានោះផងដែរ បន្ទាប់ពីការអនុវត្តនូវនីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ បានជោគជ័យជាស្ថាពរ លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS នឹងបន្តដាក់ឱ្យអនុវត្តនូវនីតិវិធីចំណាយទូទាត់ត្រង់ ដែលមានហានិភ័យទាបទៅកាន់ក្រសួង-ស្ថាប័ន ខាងលើ និងក្រសួង-

ណាយបន្ទុកបុគ្គលិក
ាស់ គ្របដណ្តប់
១៣

នុរដ្ឋលេខាធិការ

ភការជំនួយការ

ក់បំណាច់មុខងារ

ត្ថម្ភនិវត្តជន

**នីតិវិធីថ្មីសម្រាប់ចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប គ្របដណ្តប់ទៅលើមុខសញ្ញាចំណាយចំនួន ៩**

១. ថ្លៃប្រើប្រាស់អគ្គិសនី
២. ថ្លៃប្រើប្រាស់ទឹកស្អាត
៣. ថ្លៃប្រមូលសំរាម និងកាកសំណល់រឹងរាវ ដែលមានកិច្ចសន្យា ឬ កិច្ចព្រមព្រៀង
៤. ប្រាក់កម្រៃភ្នាក់ងារបរទេសជាប់កិច្ចសន្យា ដែលមានគោលការណ៍ពីរាជរដ្ឋាភិបាល
៥. ថ្លៃជាវសៀវភៅរាជកិច្ច ដែលផ្គត់ផ្គង់ដោយទីស្តីការគណៈរដ្ឋមន្ត្រី
៦. សោហ៊ុយប្រៃសណីយ៍ ដែលផ្តល់សេវាដោយប្រៃសណីយ៍កម្ពុជា
៧. សោហ៊ុយទូរគមនាគមន៍ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា
៨. ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និង ស្រាវជ្រាវក្នុងប្រទេសដែលមានគោលរបបកំណត់
៩. លតាប័ត្រសម្រាប់បង់ពន្ធយានយន្តប្រចាំឆ្នាំ (មធ្យោបាយដឹកជញ្ជូន) ។

ស្ថាប័នផ្សេងៗទៀតជាបន្តបន្ទាប់។

នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុងបានផ្តល់នូវអត្ថប្រយោជន៍ដល់មន្ត្រីគ្រប់គ្រង និងអនុវត្តថវិកានិងហិរញ្ញវត្ថុ ដូចជា÷

**១. ឯកសារ÷** មិនមានការរៀបចំ និងបញ្ជូនសំណុំឯកសារអាណត្តិបើកប្រាក់ជាក្រដាសពីដំណាក់កាលមួយទៅដំណាក់កាលមួយនៅតាមអង្គភាពដែលចូលរួមអនុវត្តនីតិវិធីថ្មីខាងលើទៀតនោះទេ គឺអនុវត្តតាមប្រព័ន្ធ FMIS ទាំងស្រុង។ ឯកសារទាំងនោះរួមមាន **សន្លឹកអាណត្តិបើកប្រាក់, លិខិតសំណើសុំថវិកា, សលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ, ដីកាបញ្ចេញអាណត្តិបើកប្រាក់, ដីកាបញ្ជូន និងដីកាអមលិខិតយុត្តិការ។** លិខិតយុត្តិការចំណាយមួយចំនួន ត្រូវបានស្កេនបញ្ចូលក្នុងប្រព័ន្ធ FMIS និងរក្សាទុកច្បាប់ដើមនៅអង្គភាពសាមី ដើម្បីជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្ម ដែលមានដូចជា÷ ឯកសារពាក់ព័ន្ធនឹងការបើកផ្តល់បៀវត្សពីក្រសួងមុខងារសាធារណៈ, ឯកសារស្នើសុំរបស់សាមីខ្លួន, លិខិតផ្តល់បុរេប្រទាន, វិក្កយបត្រ ឬតារាងសម្រង់លម្អិតវិក្កយបត្រ, ប្រកាស ឬសេចក្តីសម្រេចទទួលស្គាល់ភ្នាក់ងារបរទេសជាប់កិច្ចសន្យា, កិច្ចសន្យាការងារ, បញ្ជីឈ្មោះភ្នាក់ងារបរទេសជាប់កិច្ចសន្យាដោយមានបញ្ជាក់ពីប្រធានអង្គភាព, តារាងសម្រង់ឈ្មោះសិស្សនិស្សិត ដែលទទួលប្រាក់អាហារូបករណ៍, ប្រកាស ឬសេចក្តីសម្រេចផ្តល់អាហារូបករណ៍ដល់សិស្សនិស្សិត, ច្បាប់ថតចម្លងលតាប័ត្រ, និងតារាងសម្រង់លម្អិតប្រាក់ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការដោយមានបញ្ជាក់ពីប្រធានអង្គភាព ជាដើម។

**២. ជំហាននៃការអនុវត្ត÷** ជំហាននៃការអនុវត្តនីតិវិធីថ្មីមានលក្ខណៈសាមញ្ញ, ខ្លី,




*ជំហាននៃការអនុវត្តនីតិវិធីថ្មីមានលក្ខណៈសាមញ្ញ ខ្លី លឿន និងមានព័ត៌មានគ្រប់គ្រាន់ក្នុងការតាមដានស្ថានភាពប្រតិបត្តិការចំណាយថវិកា ដោយពេលវេលានៃការរៀបចំ និងអនុម័តលើប្រតិបត្តិចំណាយថវិកាត្រូវបានកត់ត្រាក្នុងប្រព័ន្ធ FMIS*

លឿន និងមានព័ត៌មានគ្រប់គ្រាន់ក្នុងការតាមដានអំពីស្ថានភាពប្រតិបត្តិការចំណាយថវិកា ដោយពេលវេលានៃការរៀបចំ និងការអនុម័តលើប្រតិបត្តិការចំណាយថវិកាត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធ FMIS។

**៣. មន្ត្រីចូលរួមអនុវត្តនីតិវិធីថ្មី÷** តួអង្គចូលរួមនៅក្នុងនីតិវិធីថ្មីមានចំនួនតិចជាងមុន។

ជារួម មានអត្ថប្រយោជន៍ជាច្រើនដែលទទួលបានពីការអនុវត្តនីតិវិធីថ្មីនេះរួមមានការកាត់បន្ថយចំណាយរដ្ឋបាល (ប្រើប្រាស់ក្រដាសតិច, ទឹកថ្នាំម៉ាស៊ីនបោះពុម្ពតិច, សម្ភារការិយាល័យតិច ជាដើម), ចំណេញពេលវេលា (មិនមានរត់ឯកសារខាងក្រៅ), បង្កើនប្រសិទ្ធភាព និងផលិតភាពការងារ (ប្រើប្រាស់ធនធានមនុស្សតិច និងកាត់បន្ថយនូវកំហុសឆ្គង) និងបង្កើននូវតម្លាភាព និង គណនេយ្យភាពនៃការអនុវត្តថវិកា (អាចតាមដានបានទាំងស្រុងអំពីស្ថានភាពនៃការអនុវត្តថវិកា និងអ្នកទទួលខុសត្រូវ) នៅក្នុងប្រព័ន្ធ FMIS តែមួយ៕■

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

# ការទូទាត់តាមអេឡិចត្រូនិក (EFT) ពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទៅកាន់ប្រព័ន្ធធនាគាររបស់ធនាគារកាណាឌីយ៉ា

*ការទូទាត់តាមប្រព័ន្ធ FMIS អ្នកប្រើប្រាស់អាចជ្រើសរើសមធ្យោបាយនៃទូទាត់ចំនួន៣ ប្រភេទ រួមមាន ទូទាត់តាមលិខិតបញ្ជាផ្ទេរសាច់ប្រាក់, ទូទាត់តាមមូលប្បទានបត្រចេញពីប្រព័ន្ធ FMIS និងទូទាត់តាមអេឡិចត្រូនិក (Electronic Fund Transfer) ហៅកាត់ថា EFT ។*

មធ្យោបាយទូទាត់តាម EFT ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការចាប់តាំងពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ នៅរតនាគារថ្នាក់កណ្ដាល សម្រាប់ការទូទាត់ប្រតិបត្តិការចំណាយ និងការបង្វែរសាច់ប្រាក់ពីប្រព័ន្ធ FMIS ទៅកាន់ប្រព័ន្ធធនាគាររបស់ធនាគារជាតិនៃកម្ពុជា។ ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច (EFT) ដែលជាមុខងារមួយនៅក្នុងប្រព័ន្ធ FMIS ប្រើប្រាស់សម្រាប់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិចជូនក្រុមហ៊ុនផ្គត់ផ្គង់ និងក្រសួង-ស្ថាប័ន ដោយមិនតម្រូវឱ្យមានការបោះផ្សាយមូលប្បទានបត្រដោយអគ្គនាយកដ្ឋានរតនាគារជាតិឡើយ។




កាលពីដើមឆ្នាំ២០២១ ថ្មីៗនេះ លេខាធិការដ្ឋាន ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានបញ្ចប់ការរៀបចំ ការអភិវឌ្ឍ និងបានដាក់ឱ្យអនុវត្តជាផ្លូវការដោយជោគជ័យសម្រាប់ការទូទាត់ និងការបង្វែរសាច់ប្រាក់តាមអេឡិចត្រូនិច (EFT) ពីប្រព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទៅកាន់ប្រព័ន្ធធនាគារ របស់ធនាគារកាណាឌីយ៉ា (Canadia Bank) បន្ថែមថ្មីមួយទៀត ស្របតាមផែនការដែលបានដាក់ចេញសម្រាប់ផ្តល់នូវជម្រើសប្រើប្រាស់ក្នុងការទូទាត់ជូនក្រុមហ៊ុនផ្គត់ផ្គង់ ឬក្រសួង-ស្ថាប័នទាំងនៅរតនាគារថ្នាក់កណ្ដាល និងរតនាគារនៅថ្នាក់មូលដ្ឋាន។

អត្ថប្រយោជន៍នៃការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច (EFT) គឺសន្សំសំចៃពេលវេលា និងកាត់បន្ថយចំណាយលើការប្រើប្រាស់ក្រដាសស្នាមដោយសារអ្នកប្រើប្រាស់ប្រព័ន្ធ FMIS អាចធ្វើការទូទាត់ និងផ្ទេរសាច់ប្រាក់ទៅកាន់គណនីធនាគារ របស់អ្នកទទួលផលបានឆាប់រហ័សតាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ជាមួយគ្នានេះរាល់ប្រតិបត្តិការដែលទូទាត់តាម EFT ពុំចាំបាច់តម្រូវឱ្យរង់ចាំការជម្រះសាច់ប្រាក់ទៀតនោះទេ មានន័យថា ប្រព័ន្ធ FMIS និងប្រព័ន្ធធនាគារនឹងធ្វើការទូទាត់កាត់កងសមតុល្យគណនីធនាគារស្របគ្នាក្នុងថ្ងៃតែមួយ ដែលអាចផ្តល់នូវមូលដ្ឋានដ៏សំខាន់ និងទាន់ពេលក្នុងការផលិតរបាយការណ៍លំហូរសាច់ប្រាក់ចេញពីប្រព័ន្ធ FMIS និងរបាយការណ៍តាមដានសាច់ប្រាក់ផ្សេងៗ សម្រាប់ថ្នាក់ដឹកនាំក្នុងការសម្រេចចិត្តជាយុទ្ធសាស្ត្រ។ ម្យ៉ាងទៀត ការទូទាត់តាម EFT អាចកាត់បន្ថយនូវការជួបគ្នារវាងអ្នកទទួលផល និងអ្នកបើកផ្តល់ ដែលចូលរួមចំណែកក្នុងការពង្រឹងតម្លាភាព និងប្រសិទ្ធភាពសេវាសាធារណៈ ដោយគោលដៅចុងក្រោយនោះ គឺដើម្បីឱ្យការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋបានទាន់ពេលវេលា និងតាមតម្រូវការ៕■

*ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច (EFT) ដែលជាមុខងារមួយនៅក្នុងប្រព័ន្ធ FMIS ប្រើប្រាស់សម្រាប់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិចជូនក្រុមហ៊ុនផ្គត់ផ្គង់ និងក្រសួង-ស្ថាប័ន ដោយមិនតម្រូវឱ្យមានការបោះផ្សាយមូលប្បទានបត្រដោយអគ្គនាយកដ្ឋានរតនាគារជាតិឡើយ។*

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

# ការប្រមូលចំណូលពន្ធដារ ភាពលទ្ធភាព និងបញ្ហាប្រឈម ក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩

*ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើវិស័យសេដ្ឋកិច្ច ជាពិសេសការប្រមូលចំណូលពន្ធនៅស្ទើរតែគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។ ប្រទេសកម្ពុជា ក៏បានទទួលរងផលប៉ះពាល់លើផ្នែកសេដ្ឋកិច្ចផងដែរដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសការធ្លាក់ចុះនូវសកម្មភាពសេដ្ឋកិច្ច និងចំណូលពន្ធតាមវិស័យសំខាន់ៗមួយចំនួនរួមមាន÷ ទេសចរណ៍ អាកាសចរណ៍ ឧស្សាហកម្ម វាយនភណ្ឌ និងវិស័យនានាផ្សេងទៀតផងដែរ។*

ការព្យាករណ៍ចំណូលពន្ធក្នុងអំឡុងពេលនៃការរីករាលដាល នៃជំងឺកូវីដ-១៩ គឺជាកិច្ចការដ៏លំបាកមួយ ហើយការគ្រប់គ្រងការប្រមូលចំណូលពន្ធ ទាមទារឱ្យមានការដាក់ចេញនូវយន្តការគ្រប់គ្រងច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់ ក្នុងគោលដៅធានាបាននូវលទ្ធផលប្រមូលចំណូលល្អប្រសើរ និងសម្រេចបានតាមផែនការដែលច្បាប់បានកំណត់។ ជាការពិតណាស់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កឱ្យមាននូវផលប៉ះពាល់យ៉ាងខ្លាំងដល់ការប្រមូលចំណូលពន្ធ ដែលកត្តានេះអាចបណ្តាលមកពីការថមថយសកម្មភាពសេដ្ឋកិច្ចក៏ដូចជាការដាក់ចេញនូវវិធានការគោលនយោបាយសារពើពន្ធ ដោយរាជរដ្ឋាភិបាលក្នុងគោលដៅរួមចំណែកកាត់បន្ថយផលប៉ះពាល់ដល់អ្នកជាប់ពន្ធផងដែរ។ ក្នុងន័យនេះអគ្គនាយកដ្ឋានពន្ធដារបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រ និងអនុវត្តនូវវិធានការសំខាន់ៗដើម្បីកាត់បន្ថយផលប៉ះពាល់ និងជំរុញកំណើនសេដ្ឋកិច្ច ក្នុងអំឡុងពេល និងក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ដែលវិធានការទាំងនេះត្រូវបានដាក់ចេញ ដោយឈរលើគោលការណ៍សំខាន់ៗរួមមាន ការទប់ស្កាត់ និងឆ្លើយតបទៅនឹងវិបត្តិជំងឺកូវីដ-១៩ ព្រមទាំងការខិតខំប្រឹងប្រែងរក្សាលំនឹងសង្គម និងអាជីវកម្ម ក៏ដូចជាការការពារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។វិធានការសំខាន់ៗទាំងនោះរួមមាន÷

- ការលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ និងពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំ២០២០ ចំពោះភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ នៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ក្រុងបាវិត និងក្រុងប៉ោយប៉ែត ដែលជាប្រភេទអាជីវកម្ម និងតំបន់ទទួលរងផលប៉ះពាល់ខ្លាំង
- លើកលែងការបង់ពន្ធអប្បបរមា (Minimum Tax) សម្រាប់ក្រុមហ៊ុនអាកាសចរណ៍ចុះបញ្ជីនៅកម្ពុជា
- លើកលែងការបង់ពន្ធប៉ាតង់ ពន្ធតែមប្រិ៍សារពើពន្ធ (ពន្ធលើស្លាកយីហោ) ព្រមទាំងពន្ធារពេលធ្វើសវនកម្មពេញលេញសម្រាប់ឆ្នាំ២០២០ ចំពោះភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ដទៃទៀត
- លើកលែងពន្ធលើការបង់ប្រាក់អតីតភាពការងារសម្រាប់មុន និងអំឡុងឆ្នាំ២០១៩ ចំពោះនិយោជិតខ្មែរ ដែលធ្វើការងារក្នុងវិស័យវាយនភណ្ឌកាត់ដេរ ស្បែកជើង ព្រមទាំងវិស័យផ្សេងទៀត (សម្រាប់ឆ្នាំ ២០២០ ការលើកលែងពន្ធអាចអនុវត្តសម្រាប់តែអ្នក ដែលទទួលបានប្រាក់អតីតភាពការងារតិចជាង៤ ០០០ ០០០ រៀល)
- លើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលមានតម្លៃស្មើ ឬទាបជាង ៧០ ០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក
- បន្ធូរបន្ថយការអនុវត្តពន្ធកាត់ទុក(Withholding Tax) លើការប្រាក់ចំពោះប្រាក់កម្ចីក្នុងស្រុក និងក្រៅស្រុករបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការបន្ធូរបន្ថយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ-២០២០ សម្រាប់សហគ្រាសដែលស្ថិតក្នុងវិស័យវាយនភណ្ឌ ដែលទទួលរងផលប៉ះពាល់។

ទោះបីជាស្ថានភាពសេដ្ឋកិច្ចសាកលក៏ដូចជាសេដ្ឋកិច្ចកម្ពុជាមិនទាន់មានភាពប្រាកដប្រជា ជាពិសេសមានការទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃ



ជំងឺកូវីដ-១៩ ក៏ដោយ ក៏អគ្គនាយកដ្ឋានពន្ធដារ តាមរយៈការអនុវត្តគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាព និងចំគោលដៅ ដោយមានការដឹកនាំចង្អុលបង្ហាញប្រកបដោយភាពឈ្លាសវៃ របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ បានខិតខំក្នុងការប្រមូលពន្ធក្នុងឆ្នាំ២០២០ សម្រេចបានប្រមាណ **១១ ៧០០.៥២** ប៊ីលានរៀល (ប្រមាណ **២ ៨៨៩.០២** លានដុល្លារអាមេរិក) ស្មើនឹង **១០១.៣៦%** នៃផែនការប្រចាំឆ្នាំ បើធៀបនឹងចំណូលពន្ធអាករប្រមូលបានក្នុងឆ្នាំ២០១៩ ឃើញថាមានការកើនឡើងចំនួន៤២៣.២០ ប៊ីលានរៀល (ប្រមាណជា១០៤,៤៩ លានដុល្លារអាមេរិក) ស្មើនឹង៣.៧៣%។ ក៏ប៉ុន្តែ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់ និងធ្វើឱ្យវិស័យមួយចំនួនស្ទើរតែមិនមានសកម្មភាពក្នុងរយៈពេលយូរ ហើយវិស័យមួយចំនួនទៀតមានការថមថយនូវសកម្មភាព ដែលកត្តាទាំងនេះនឹងជះឥទ្ធិពលអវិជ្ជមានលើប្រាក់ចំណូលរបស់សហគ្រាសក្នុងឆ្នាំ២០២០ ដែលនឹងត្រូវ



*ដើម្បីធានាបាននិរន្តរភាពការប្រមូលចំណូលពន្ធ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងលទ្ធផលល្អប្រសើរជាពិសេសគឺ ឆ្លើយតបកាលានុវត្តភាពថ្មីៗនានា និងការកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការកែទម្រង់សំខាន់ៗ ឆ្លើយតបនឹងការវិវឌ្ឍនៃស្ថានការណ៍ ជាពិសេសជាមួយនឹងនិន្នាការ ឆ្ពោះទៅរកការប្រើប្រាស់ប្រព័ន្ធឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩*

ប្រកាស និងបង់ប្រាក់ពន្ធក្នុងឆ្នាំ២០២១ ហើយក៏អាចនឹងមានឥទ្ធិពល សម្រាប់ឆ្នាំបន្តបន្ទាប់ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ អគ្គនាយកដ្ឋានពន្ធដារ នៅតែជឿជាក់ និងមានភាពសុទិដ្ឋិនិយមថាការប្រមូលចំណូលក្នុងឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់អាចនឹងសម្រេចបានតាមផែនការ ដែលច្បាប់បានកំណត់។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមថាផលប៉ះពាល់នៃជំងឺកូវីដ-១៩ អាចនឹងប្រែក្លាយជាកាលានុវត្តភាពថ្មីសម្រាប់សហគ្រាសក្នុងការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន ដោយគិតគូរទៅលើកត្តាអាទិភាព និងកត្តាលទ្ធភាព ហើយក៏ជាឱកាសសម្រាប់បង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងការនាំចេញផលិតផលដែលមានតម្លៃបន្ថែមកាន់តែខ្ពស់ និងជម្រើសទីផ្សារកាន់តែទូលាយ ដែលការណ៍នេះនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ចំណូលពន្ធជូនជាតិ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានពន្ធដារបានគិតគូរ និងត្រៀមខ្លួនរួចជាស្រេចឆ្លើយតបនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើការប្រមូលចំណូលពន្ធ ក៏ដូចជាការវិវឌ្ឍថ្មីៗ ដែលអាចកើតមានឡើង ក្នុងគោលដៅធានាឱ្យបាននូវនិរន្តរភាពនៃការប្រមូលចំណូលពន្ធដោយក្នុងនោះ÷

- បានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធកម្មវិធីនានាដើម្បីសម្រួល និងពង្រឹងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ ក្នុងនោះមានដូចជា÷ ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងការដាក់លិខិតប្រកាសពន្ធប្រចាំខែ (E-Filing) និងប្រចាំឆ្នាំ (TOI E-Filing) ប្រព័ន្ធទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment) និងប្រព័ន្ធទទួលលិខិតប្រកាសពន្ធតាមសេវាកម្មអនឡាញ (E-Uploader) កម្មវិធីប្រកាសពន្ធអាជីវកម្ម សម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Pre-Filing App) កម្មវិធីទូរសព្ទដៃអ្នកជាប់ពន្ធ (លើមុខងារបង់ពន្ធលើអចលនទ្រព្យ) ប្រព័ន្ធគ្រប់គ្រងពន្ធប្រថាប់ត្រា លើការផ្ទេរកម្មសិទ្ធិយានជំនិះតាមអនឡាញ ព្រមទាំងកម្មវិធីបញ្ជូនឯកសារអេឡិចត្រូនិក (e-Document Submission System) ដែលប្រព័ន្ធកម្មវិធីទាំងនេះនឹងជួយសម្រួល ដល់អ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ និងជាយន្តការដ៏ត្រឹមត្រូវ និងសមស្របក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩នេះ
- ការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងបំណុលពន្ធដែលនឹងកត់ត្រា និងរក្សាប្រវត្តិបំណុលពន្ធច្បាស់លាស់ មានការវិភាគនូវហានិភ័យបំណុលពន្ធត្រឹមត្រូវ ព្រមទាំងផ្តល់លទ្ធភាពខ្ពស់ដល់រដ្ឋបាលសារពើពន្ធក្នុងការគ្រប់គ្រងប្រមូលបំណុលពន្ធ
- បន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធក្នុងគោលដៅបង្កភាពងាយស្រួលសម្រាប់អ្នកជាប់ពន្ធ និងមន្ត្រី ព្រមទាំងពង្រឹងអនុលោមភាពសារពើពន្ធ ដើម្បីជំរុញប្រសិទ្ធភាព និងភាពប្រទាក់ក្រឡាក្នុងការបំពេញបេសកកម្មគ្រប់គ្រងប្រមូលចំណូលពន្ធ
- អនុវត្តនូវយន្តការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform) និងពង្រឹងយន្តការចុះបញ្ជីពន្ធដារតាមរយៈប្រកាសស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
- ពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធដោយបានរៀបចំក្រុមការងារសេវាគាំទ្រ

(e-Tax Service) និងមជ្ឈមណ្ឌល Call Center 1277 ក៏ដូចជាមានការរៀបចំប្តូរវេនមន្ត្រីបំពេញការងារ និងមានការចាត់ចែងមន្ត្រីបំពេញការងារពីផ្ទះដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងរាលដាល

- ការសិក្សាលើលទ្ធភាពនៃការប្រមូលចំណូលដែលមានសក្តានុពលផ្សេងទៀត ដោយធានាបាននូវអនុលោមភាពសារពើពន្ធ និងការប្រមូលចំណូល ឱ្យបានគ្រប់ជ្រុងជ្រោយ រួមមានប្រភពចំណូលពីវិស័យពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) វិស័យប្រេងកាត ដែលជាសក្តានុពលថ្មី វិស័យធនធានរ៉ែ និងវិស័យដែលមានសក្តានុពលមួយចំនួនទៀត
- ការធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិស្តីពីសារពើពន្ធ ឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ធានាភាពច្បាស់លាស់ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព នីត្យានុកូលភាព និងសង្គតិភាព នៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ
- ពង្រឹង និងយកចិត្តទុកដាក់លើការធ្វើសវនកម្មដែលជាជញ្ជីងវាស់នូវអនុលោមភាពរបស់សហគ្រាស និងចៀសវាងការបង្កការលំបាកដល់អ្នកជាប់ពន្ធ
- បន្តលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ តាមរយៈការរៀបចំសិក្ខាសាលាតាមអនឡាញ ការដំណើរការកម្មវិធីរៀនអំពីពន្ធដារតាមប្រព័ន្ធអនឡាញ (GDT E-Learning) និងការណែនាំអំពីការអនុវត្តបទប្បញ្ញត្តិថ្មីពាក់ព័ន្ធនឹងពន្ធដារ ជូនដល់មន្ត្រីអនុវត្តផ្ទាល់ អ្នកជាប់ពន្ធ និងសាធារណជនទូទៅ ក៏ដូចជាបន្តកិច្ចសហការ និងពិគ្រោះយោបល់ ជាមួយវិស័យពាក់ព័ន្ធ ដើម្បីទទួលយកធាតុចូលក្នុងការសិក្សារៀបចំ និងកែលម្អ បទប្បញ្ញត្តិពាក់ព័ន្ធចាំបាច់នានា
- បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) និងយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ (RMSII) ព្រមទាំងផែនការយុទ្ធសាស្ត្រ និងផែនការប្រត្តិបត្តិ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ




- បន្តពង្រឹងការអនុវត្តកម្មវិធីកែទម្រង់ធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារ និងអនុវត្តផែនការយុទ្ធសាស្ត្រធនធានមនុស្ស២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ។

ជារួម ការរីករាលដាលនៃជំងឺកូវីដ-១៩ គឺពិតជាបានបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការងារប្រមូលចំណូលពន្ធហើយបញ្ហាទាំងនេះតម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលសារពើពន្ធ ដាក់ចេញនូវវិធានការជាក់លាក់ និងទាន់ពេលវេលា។ ការដាក់ចេញវិធានការទាំងនោះនឹងផ្តល់ផលប្រយោជន៍ ដល់សេដ្ឋកិច្ចក្នុងអំឡុងពេលមានវិបត្តិកូវីដ-១៩ និងក្រោយពេលវិបត្តិ ជាពិសេសបង្កបរិយាកាសធុរកិច្ច និងជួយសម្រួលដល់បណ្តាអាជីវកម្ម ក៏ដូចជាវិស័យនានាដែលរងផលប៉ះពាល់ និងកាត់បន្ថយភាពលំបាកនៃលំហូរសាច់ប្រាក់ និងបន្ទុករបស់សហគ្រាស និងគ្រួសារផងដែរ។ ពិតណាស់ការដាក់ចេញនូវវិធានការពន្ធទាំងនេះគឺជាកិច្ចការចាំបាច់ និងអាទិភាព ប៉ុន្តែក៏ជាកត្តាសំខាន់មួយដែលនាំ ឱ្យចំណូលពន្ធដារមានការថមថយផងដែរ។ ដើម្បីធានាបាននិរន្តរភាពការប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់ និងលទ្ធផលល្អប្រសើរ ជាពិសេសគឺឆ្លើយតបនូវកាលានុវត្តថ្មីៗនានា និងការកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវវិធានការកែទម្រង់សំខាន់ៗ ឆ្លើយតបនឹងការវិវឌ្ឍនៃស្ថានការណ៍ ជាពិសេសជាមួយនឹងនិន្នាការឆ្ពោះទៅរកការប្រើប្រាស់ប្រព័ន្ធឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន ក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារ ក៏បានចូលរួម និងណែនាំឱ្យមន្ត្រី ដែលបំពេញការងារត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល និងវិធានការ “**៣ កុំ ៣ ការពារ**” របស់រាជរដ្ឋាភិបាលផងដែរ ដើម្បីកាត់ផ្តាច់ការរីករាលដាលនៃជំងឺកូវីដ-១៩ ឱ្យបាន៕■

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធនៃ អ.គ.ហ. និងក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានពន្ធដារ*

# ការប្រមូលចំណូលគយ កាលានុវត្តភាព និងបញ្ហាប្រឈម នៃរដ្ឋបាលគយ ក្នុងស្ថានភាពជំងឺរាតត្បាតកូវីដ-១៩

*ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច និងពាណិជ្ជកម្មជាសកល ដូចជាដំណើរការអាជីវកម្មផ្សេងៗត្រូវបានផ្អាកដោយការបិទខ្ទប់ភូមិសាស្ត្រ ដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ហើយខ្សែច្រវាក់នៃ ការផ្គត់ផ្គង់ទំនិញជួបប្រទះនូវការរាំងស្ទះដោយសារការរឹតត្បិត ឬបិទច្រកព្រំដែន និងភាពរអាក់រអួលនៃសេវាភ័ស្តុភារកម្មអន្តរជាតិ។*

ផលប៉ះពាល់នេះ បានជះឥទ្ធិពលលើការប្រមូលពន្ធ និងអាករគយគួរឱ្យកត់សម្គាល់ ជាក់ស្តែងក្នុងឆ្នាំ២០២០កន្លងទៅ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា(អគរ) ប្រមូលចំណូលបានចំនួន **៩,៧៦៣.១៩** ប៊ីលានរៀល ឬស្មើនឹង **២,៤១០.៦៦** លានដុល្លារអាមេរិក ត្រូវជាប្រមាណ **៨៣.២០%** នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។ បើប្រៀបធៀបនឹងឆ្នាំ២០១៩ ចំណូលនេះថយចុះប្រមាណ២៤.៨១%។ ដោយឡែកក្នុងត្រីមាសទី១ ឆ្នាំ២០២១ ចំណូលប្រមូលបានមានចំនួន **២,៣៩៧.៧៣** ប៊ីលានរៀល ឬស្មើនឹង **៥៩២.០៣** លានដុល្លារអាមេរិក ត្រូវជាប្រមាណ **២៥.០៥%** នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ហើយបើប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០ ថយចុះប្រមាណ ១៨.២២%។

បើប្រៀបធៀបចំណូលតាមក្រុមមុខទំនិញសំខាន់ៗជាមួយនឹងឆ្នាំ២០១៩ ឃើញថាក្នុងឆ្នាំ២០២០ ចំណូលមុខទំនិញ ក្រុមទី១ (ទំនិញចម្រុះ) មានចំនួន ២,៩៨៩.២៨ ប៊ីលានរៀល ថយចុះ ៦.៨០%, ចំណូលមុខទំនិញក្រុមទី២ (យានយន្ត និងគ្រឿងចក្រ) មានចំនួន ៤,០០៦.៤៦ ប៊ីលានរៀល ថយចុះ ៤១.៥៩%, ចំណូលមុខទំនិញក្រុមទី៣ (ផលិតផលតេលសិលា) មានចំនួន ២,២៣៤.១០ ប៊ីលានរៀល កើនឡើង ២.៧០%, ចំណូលមុខទំនិញក្រុមទី៤ (គ្រឿងសំណង់) មានចំនួន ៤៣៦.៥៧ ប៊ីលានរៀល ថយចុះ ២៨.៧៩%, និងកម្រៃ ព្រមទាំងចំណូលផ្សេងៗ មានចំនួន ១៣២.០១ប៊ីលានរៀល ថយចុះ ២០.៤៦%។ ដោយឡែក ក្នុងត្រីមាសទី១ ឆ្នាំ២០២១ ចំណូលមុខទំនិញក្រុមទី១ (ទំនិញចម្រុះ) មានចំនួន ៦៨២.៣០ ប៊ីលានរៀល ថយចុះប្រមាណ ១៨.៨១%, ចំណូលមុខទំនិញក្រុមទី២ (យានយន្ត និងគ្រឿងចក្រ) មានចំនួន ១,០៨៣.៣៣ ប៊ីលានរៀល ថយចុះប្រមាណ ២២.២៤%, ចំណូលមុខទំនិញក្រុមទី៣ (ផលិតផលតេលសិលា) មានចំនួន ៥៦៨.២៦ ប៊ីលានរៀល កើនឡើងប្រមាណ ០.៦៥%, ចំណូលមុខទំនិញក្រុមទី៤(គ្រឿងសំណង់) មានចំនួន១១៤.៨៩ ប៊ីលានរៀល កើនឡើងប្រមាណ ១៤.៩៦% ព្រមទាំងកម្រៃ និងចំណូលផ្សេងៗ មានចំនួន ៤១.០៣ ប៊ីលានរៀល កើនឡើងប្រមាណ ៤.៨៦% ដោយប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

**ក្រាហ្វិកប្រៀបធៀបចំណូលតាមក្រុមទំនិញ ឆ្នាំ២០១៩ និងឆ្នាំ២០២០**




*ប្រភព÷អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

ផ្អែកទៅតាមស្ថានភាពនយោបាយ និងសេដ្ឋកិច្ច ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ គួបផ្សំជាមួយនឹងបទពិសោធការងារកន្លងមក ទោះបីមានបញ្ហាប្រឈមនានា ជាពិសេសការរីករាលដាលនៃជំងឺកូវីដ-១៩ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានកត់សម្គាល់ និងប្រមើលឃើញនូវកាលានុវត្តភាពមួយចំនួនដូចខាងក្រោម÷

- សន្តិភាពនឹងបន្តដើរតួនាទីគ្រឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច
- មូលដ្ឋានគ្រឹះដ៏រឹងមាំ និងកំណើនប្រកប

*គោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម ព្រមទាំងការអភិវឌ្ឍឧស្សាហកម្ម បានជំរុញពិពិធកម្មខឿនផលិតកម្មក្នុងស្រុក ជាពិសេសការបង្វែរពីការផលិតផលិតផលសម្លៀកបំពាក់ ទៅជាសម្ភារបរិក្ខាសុខាភិបាល និងកម្មន្តសាលក្រៅពីកាត់ដេរផ្សេងទៀត ក៏ដូចជាផលិតផលកសិកម្មនានាសម្រាប់នាំចេញ*

ដោយចីរភាព នៃសេដ្ឋកិច្ចកម្ពុជាក្នុងទសវត្សចុងក្រោយនេះ

- ការដាក់ចេញនូវវិធានការប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- ភាពរអាក់រអួលនៃខ្សែច្រវ៉ាក់ផលិតកម្មនៃបណ្ដាប្រទេសនាំចេញផលិតផល ដូចកម្ពុជា ដោយសារការរីករាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យការបញ្ជាទិញផលិតផលកម្ពុជាកើនឡើង
- គោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម ព្រមទាំងការអភិវឌ្ឍឧស្សាហកម្ម បានជំរុញពិពិធកម្មខឿនផលិតកម្មក្នុងស្រុក ជាពិសេសការបង្វែរពីការផលិតផលិតផលសំលៀកបំពាក់ទៅជាសម្ភារបរិក្ខារសុខាភិបាល និងកម្មន្តសាលក្រៅពីកាត់ដេរផ្សេងទៀត ក៏ដូចជាផលិតផលកសិកម្មនានាសម្រាប់នាំចេញ
- ការបន្សាំខ្លួនទៅនឹងបរិស្ថានរស់នៅ និងការងារតាមគន្លងថ្មីរបស់មន្ត្រីគយ បណ្ដាស្ថាប័នមានសមត្ថកិច្ចតាមព្រំដែន និងសាធារណជន តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងហានិភ័យ និងការកាត់បន្ថយការិយាធិបតេយ្យ បានជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ដែលអនុលោមតាមការអនុវត្តល្អ ជាអន្តរជាតិ។

**ក្រាហ្វិកប្រៀបធៀបចំណូលតាមក្រុមទំនិញ ក្នុងត្រីមាសទី១ ឆ្នាំ២០២១ និងឆ្នាំ២០២០**




*ប្រភព÷អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

ទន្ទឹមនឹងកាលានុវត្តភាពខាងលើនេះ **អគរ** ក៏បាននិងកំពុងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនក្នុងការប្រមូលចំណូល ក៏ដូចជាការបំពេញការងារ ជាប្រចាំផ្សេងទៀត ដោយមូលហេតុដូចខាងក្រោម÷

- ការរីករាលដាល និងការអូសបន្លាយនៃជំងឺកូវីដ-១៩ បានបង្កឱ្យមាន÷
  - ភាពរអាក់រអួល នៃវំហូរពាណិជ្ជកម្មអន្តរជាតិ និងការដឹកជញ្ជូន (ការបិទព្រំដែន កង្វះកម្លាំងពលកម្ម ការលុបចោលជើងដឹកជញ្ជូន ...)
  - ធ្លាក់ចុះនៃវិស័យទេសចរណ៍, អចលនទ្រព្យ សេវាកម្ម និងសំណង់ សកម្មភាពអាជីវកម្ម និងពាណិជ្ជកម្មនានា បានបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់គ្រប់សកម្មភាពសេដ្ឋកិច្ច និងសង្គម ដូចជាការងារ ប្រាក់ចំណូល ការរាំងស្ទះផលិតកម្ម ការនាំចេញនាំចូល ការដឹកជញ្ជូន ការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់ក្នុងស្រុក ធ្វើឱ្យមុខទំនិញដែលជាប្រភពចំណូលសំខាន់រួមមាន យានយន្ត និងប្រេងឥន្ធនៈធ្លាក់ចុះ និងមាននិន្នាការថយចុះគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្រសំខាន់ៗមួយចំនួន ដោយសារការផ្ទុះរីករាលដាលខ្លាំងនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍នារយៈពេលចុងក្រោយនេះ
  - ការធ្លាក់ចុះនូវតម្រូវការជាសកលបានធ្វើឱ្យទីផ្សារនាំចេញរបស់កម្ពុជារួមតូច
- ការបន្តប្រកាន់យកគោលនយោបាយគាំពារនិយម និងសង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាចសេដ្ឋកិច្ច
- ការឆ្លៀតឱកាសប្រព្រឹត្តអំពើរត់គេចពន្ធ និងបទល្មើសឆ្លងដែននានា ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងជួបវិបត្តិដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩
- ការសម្របខ្លួនមិនទាន់បានពេញលេញទៅនឹងស្ថានភាពផ្លាស់ប្ដូរយ៉ាងរហ័ស នៃបរិស្ថានរស់នៅ និងការបំពេញការងារក្នុងបរិបទថ្មីនេះ
- ការយឺតយ៉ាវក្នុងការអនុវត្តគម្រោងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងការងារគយរបស់ដៃគូអភិវឌ្ឍន៍នានា៕■

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធនៃ អ.គ.ហ. និងក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០ ស្ដីពីការតាមដានការអនុវត្តយុទ្ធសាស្ត្រ ស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥

*ជាសាវតារ យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ២០១៩-២០២៥ ត្រូវបានប្រមុខរាជរដ្ឋាភិបាល អនុម័តកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ និងប្រកាសដាក់ឱ្យអនុវត្ត នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ បន្ទាប់មក ផែនការសកម្មភាពលម្អិត សម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ក៏ត្រូវបានរៀបចំ និងទទួលបានការឯកភាពក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ផងដែរ។*

ផែនការសកម្មភាពលម្អិតនេះ បានដាក់ចេញនូវការងារកែទម្រង់គន្លឹះចំនួន ១៤ សូចនាករសមិទ្ធកម្មគន្លឹះចំនួន៣៨ ចង្កោមសកម្មភាពចំនួន៣៨ និងសកម្មភាពចំនួន៧៩ ដែលត្រូវអនុវត្តដោយអគ្គនាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៥។ សម្រាប់ឆ្នាំ២០១៩ និង២០២០ នេះ អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បានគ្រោងអនុវត្តចង្កោមសកម្មភាពចំនួន២១ និងសកម្មភាពចំនួន៥១។

ដើម្បីសម្រេចបាននូវគោលដៅ ដែលបានដាក់ចេញ យន្តការសម្របសម្រួល តាមដាន និងវាយតម្លៃ ត្រូវបានកំណត់ជាបីកម្រិត÷ ១). យន្តការសម្របសម្រួលកម្រិតបច្ចេកទេស ទទួលខុសត្រូវដោយអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ កសហវ. ២). យន្តការសម្របសម្រួលកម្រិតប្រតិបត្តិការ ទទួលខុសត្រូវដោយរដ្ឋលេខាធិការទទួលបន្ទុកនៃ កសហវ. និង ៣). យន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃទទួលខុសត្រូវដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

*សម្រាប់ឆ្នាំ២០១៩ និង២០២០នេះ អង្គភាពពាក់ព័ន្ធ ក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន ពាក់ព័ន្ធបានគ្រោងអនុវត្តចង្កោមសកម្មភាពចំនួន២១ និងសកម្មភាពចំនួន៥១*



ផ្អែកតាមយន្តការទាំងនេះ ក្រុមការងារ ក្រុមការងារបច្ចេកទេសតាមដានការអនុវត្ត PIMSRS (ហៅកាត់ថា ក្រុមការងារ PIM) បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០ ក្នុងគោលបំណងបង្ហាញអំពី÷ ១). វឌ្ឍនភាព នៃការអនុវត្តការងាររហូតមកដល់ឆ្នាំ២០២០, ២). បញ្ហាប្រឈម និង ៣). សំណើសុំការពិភាក្សា និងការអនុម័ត។ ជារួម ខាងក្រោមនេះ គឺជាតារាងសង្ខេបស្ដីពីការអនុវត្តការងារកែទម្រង់គន្លឹះទាំង១៤ គិតត្រឹមឆ្នាំ២០២០÷ *(តារាងខាងក្រោម)*

បន្ទាប់ពីអនុវត្តការងារកែទម្រង់ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រ និងតាមក្របខណ្ឌពេលវេលាជាក់លាក់ដែលបានកំណត់នៅក្នុងផែនការសកម្មភាពលម្អិត បញ្ហាប្រឈមមួយចំនួន ត្រូវបានកំណត់ដូចខាងក្រោម÷

- ភាពស្មុគស្មាញ និងទំហំនៃការងារតាក់តែងក្របខណ្ឌគតិយុត្ត(ឧទាហរណ៍ ច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន) បានធ្វើឱ្យការងារទាំងអស់នេះ មិនអាចសម្រេចបានទៅតាមក្របខណ្ឌពេលវេលា ដែលបានកំណត់ និងបានប៉ះពាល់ដល់ការងារផ្សេងទៀត មិនអាចអនុវត្តសម្រេចទៅបានតាមផែនការ។
- ការរីករាលដាលជំងឺកូវីដ-១៩ ក៏បាន-និងកំពុងធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការអនុវត្តសកម្មភាពដែលបានដាក់ចេញផងដែរ ដូចជាការពន្យារពេល នៃការរៀបចំសិក្ខាសាលា និងពិគ្រោះយោបល់ជាសាធារណៈជាដើម។
- ភាពយឺតយ៉ាវក្នុងការជ្រើសរើសទីប្រឹក្សាក្នុងស្រុក និងអន្តរជាតិ ដើម្បីជួយលើការរៀបចំលើគោលការណ៍ណែនាំមួយចំនួនតម្រូវឱ្យអង្គភាពទទួលខុសត្រូវ ចាំបាច់

| ល.រ | ការងារកែទម្រង់គន្លឹះៗ | ចំនួនសកម្មភាពសរុបគ្រោងអនុវត្តក្នុងឆ្នាំ ២០២០ | ចំនួនសកម្មភាពសម្រេចបាន | | ចំនួនសកម្មភាពសម្រេចមិនបាន | |
|---|---|---|---|---|---|---|
| | | | Done | On track | Off track | Not yet started |
| ១. | សិក្សា និងពិនិត្យឡើងវិញលើក្របខណ្ឌគតិយុត្ត | 9 | 3 | 1 | 1 | 4 |
| ២. | រៀបចំ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ | 4 | 4 | - | - | - |
| ៣. | ពង្រឹងការអនុវត្ត «គោលការណ៍ស្ដីពីការកំណត់អត្តសញ្ញាណកម្ម និងអាទិភាវូបនីយកម្មគម្រោង» | 4 | - | 1 | - | 3 |
| ៤. | រៀបចំ និងដាក់ឱ្យអនុវត្ត «គោលការណ៍ណែនាំស្ដីពីការរៀបចំសំណើគម្រោង» ឬ «គោលការណ៍ណែនាំរួមលម្អិតស្ដីពីវដ្ដនៃគម្រោងវិនិយោគសាធារណៈ» | 2 | - | 1 | - | 1 |
| ៥. | ការរៀបចំកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ | 1 | 1 | - | - | - |
| ៦. | ពង្រឹង និងកែសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដើម្បីធ្វើសមាហរណកម្មថវិកានីយកម្មពីគ្រប់ប្រភព និងពីគ្រប់មុខសញ្ញាចំណាយ | 9 | 4 | 4 | 1 | - |
| ៧. | បង្កើតយន្តការបុរេថវិកានីយកម្មការវិនិយោគសាធារណៈ សម្រាប់បំពេញមុខងារទ្វារបាលកិច្ចនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | - | - | - | - | - |
| ៨. | រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈតាមប្រភពហិរញ្ញប្បទាន | 9 | 6 | 1 | - | 2 |
| ៩. | រៀបចំក្របខណ្ឌគតិយុត្តដូចមានចែងក្នុង “ឯកសារគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០” | 8 | - | - | 1 | 7 |
| ១០. | រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ | - | - | - | - | - |
| ១១. | រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ | 1 | 1 | - | - | - |
| ១២. | រៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង | 2 | 1 | 1 | - | - |
| ១៣. | រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស | 1 | 0 | 1 | - | - |
| ១៤. | ត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា | 1 | 1 | - | - | - |
| សរុប | | 51 | 21 | 10 | 3 | 17 |

**សម្គាល់÷** Done = សម្រេចបានតាមការគ្រោងទុក, On track = បាននិងកំពុងអនុវត្តតាមផែនការ, Off track = បាននិងកំពុងអនុវត្តប៉ុន្តែយឺតជាងផែនការ, Not yet stated = មិនទាន់បានចាប់ផ្ដើមអនុវត្តទៅតាមផែនការ

ត្រូវគិតគូរលើការរៀបចំក្របខណ្ឌពេលវេលាអនុវត្តការងារឡើងវិញ។

- ❖ ការធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយវិនិយោគមិនទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយ សម្រាប់ក្រសួង-ស្ថាប័នអាទិភាពដែលទទួលបានថវិកាចំណាយវិនិយោគសាធារណៈ។
- ❖ ចង្កោមសកម្មភាពមួយចំនួន ដែលបានកំណត់នៅក្នុងផែនការសកម្មភាពលម្អិតនេះ នៅមិនទាន់បានកំណត់សកម្មភាពលម្អិតសម្រាប់អនុវត្តនៅឡើយ ជាហេតុធ្វើឱ្យការងារទាំងនោះមិនស្ថិតនៅក្នុងដំណាក់កាលកំពុងអនុវត្ត និងមិនអាចកំណត់ពេលវេលាសម្រេចបាន ឬតាម-ដានការអនុវត្តការងារទាំងនោះឱ្យបានជាក់លាក់។

ផ្អែកតាមរបាយការណ៍វាយតម្លៃនេះ ក្រុមការងារPIM ស្នើសុំធ្វើការពិភាក្សា និងការសម្រេចទៅលើចំណុចដូចខាងក្រោម *(តារាងខាងស្ដាំ)*÷

ជារួម ការអនុវត្តសកម្មភាពចំនួន៥១ ដែលបានដាក់ចេញនៅក្នុងផែនការសកម្ម-ភាពលម្អិត សម្រាប់ឆ្នាំ២០២០ បានបង្ហាញថាមានសមកម្មភាព៣១ (៦១%) ត្រូវបានអនុវត្តបញ្ចប់ និងកំពុងអនុវត្តតាមផែនការដែលបានដាក់ចេញ និងសកម្មភាពចំនួន ២០(៣៩%) បាននិងកំពុងអនុវត្តប៉ុន្តែនៅយឺតជាងផែនការ និងមិនទាន់បានចាប់ផ្ដើមអនុវត្តនៅឡើយ។ លទ្ធផលនេះបង្ហាញថា ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈលំបាក

| ល.រ | សំណើសុំពិភាក្សា | សំណើដំណោះស្រាយ | អង្គភាពទទួលខុសត្រូវ | ការសម្រេចរបស់អង្គប្រជុំ |
|---|---|---|---|---|
| ១. | ការងាររៀបចំ និងដាក់ឱ្យអនុវត្ត «គោលការណ៍ណែនាំរួមលម្អិតស្តីពីវដ្តនៃគម្រោងវិនិយោគសាធារណៈ» | ស្នើសុំពន្យារក្របខណ្ឌពេលវេលាអនុវត្តដោយផ្អែកតាមផែនការការងាររបស់ជំនាញការ ADB ។ | ក្រុមការងារ PIM | បញ្ចប់នៅ Q4 2021 |
| ២. | ការងាររៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និង រៀបចំគម្រោង | ស្នើសុំពន្យារក្របខណ្ឌពេលវេលាអនុវត្តដោយផ្អែកតាមផែនការការងាររបស់ជំនាញការ ADB ។ | ក្រុមការងារ PIM | បញ្ចប់នៅ Q4 2021 |
| ៣. | ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការ វិនិយោគសាធារណៈសម្រាប់វិស័យICT | ដោយសារមានតម្រូវការបន្ទាន់, ស្នើសុំបញ្ចូលការងារនេះ នៅក្នុងផែនការសកម្មភាពលម្អិត។ | ក្រុមការងារ PIM | ក្រុមការងារ PIM ទទួលបន្ទុក និងបញ្ចប់នៅ Q4 2021 |
| ៤. | ការរៀបចំលក្ខខណ្ឌវិនិច្ឆ័យ សម្រាប់កំណត់ទំហំនិងភាពស្មុគស្មាញនៃគម្រោង | ស្នើសុំអគ្គនាយកដ្ឋានពាក់ព័ន្ធបញ្ចូលការងារនេះ នៅក្នុងផែនការសកម្មភាពលម្អិត។ | អ. ថ.<br>អ. ហ. ក. | បញ្ចប់នៅ Q4 2021 |
| ៥. | ចង្កោមសកម្មភាពមួយចំនួននៅមិនទាន់មានការរៀបចំសកម្មភាពលម្អិតបន្ថែម | សម្រាប់ចង្កោមសកម្មភាព ១.២, ១.៣, ៣.១, ៣.២, ៣.៣, ៤.៧ និង ១៣.១ ស្នើសុំអង្គភាពពាក់ព័ន្ធបង្កើតសកម្មភាពលម្អិត ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត។ | អ. ល. សា<br>ក្រសួង-ស្ថាប័ន<br>ក្រ. ផែនការ<br>អ. ទ. ថ, វ. ស. ហ. | បញ្ចប់នៅ Q3 2021 |
| ៦. | ការធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយវិនិយោគ មិនទាន់បានពេញលេញ និងត្រឹមត្រូវទៅតាមគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី | ត្រូវបន្តពង្រឹងការធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយវិនិយោគពីគ្រប់ប្រភពហិរញ្ញប្បទានទាំងក្នុងការរៀបចំ BSP និងថវិកាប្រចាំឆ្នាំ | អ. ថ. | អ. ថ. ត្រូវបន្តពង្រឹងការធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយវិនិយោគ |
| ៧. | ការចែករំលែកឯកសារពាក់ព័ន្ធនៅក្នុងក្រុមការងារអនុវត្ត PIMSRS នៅមានកម្រិត | ស្នើសុំអគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ចែករំលែកឯកសារពាក់ព័ន្ធជាមួយក្រុមការងារអនុវត្ត PIMSRS ដើម្បីធានាបាននូវភាពប្រទាក់ក្រឡា និងការយល់ដូចគ្នា | គ្រប់អង្គភាព | គ្រប់អង្គភាពពាក់ព័ន្ធត្រូវចែករំលែកព័ត៌មានជាមួយក្រុមការងារ |
| ៨. | ការពង្រឹងយន្តការសម្របសម្រួលតាមដាន និងវាយតម្លៃ | ស្នើសុំរៀបចំកិច្ចប្រជុំ ៦ខែម្តង ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពលម្អិត | ក្រុមការងារ PIM | ក្រុមការងារ PIM ត្រូវរៀបចំបូកសរុបវឌ្ឍនភាពប្រចាំត្រីមាស និង រៀបចំកិច្ចកិច្ចប្រជុំ ៦ខែម្តង |

ដោយសារតែការរីករាលដាលជម្ងឺកូវីត-១៩ ក៏ដោយ ក៏អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បាននិងកំពុងខិតខំអនុវត្តការងារតាមសមត្ថកិច្ចរៀងៗខ្លួន។

ទោះបីជាយ៉ាងនេះក្តី ការរៀបចំបង្កើតក្របខណ្ឌគតិយុត្ត យន្តការ និងនីតិវិធីរួមតែមួយសម្រាប់គ្រប់គ្រងការវិនិយោគសា-ធារណៈតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដោយត្រូវប្រកាន់យកការអនុវត្តអភិក្រមការងារ៤ប្រការរបស់ក្រសួងសេដ្ឋ-កិច្ចនិងហិរញ្ញវត្ថុ÷ ១).អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ ២).អនុវត្តការងារជាក្រុម ៣). អនុវត្តការងារ ដោយប្រកាន់ខ្ជាប់ស្មារតីថវិកា និង ៤).មិនត្រូវមើលរំលងកំហុសខ្លួន។ ទន្ទឹមនេះ ការចូលរួមប្រកបដោយបុរេសកម្ម និងសកម្ម របស់គ្រប់ភាគីពាក់ព័ន្ធគឺជាកត្តាមិនអាចខ្វះបាន ដើម្បីធានាបាននូវភាពជោគជ័យបន្តទៀតនៅក្នុងការងារ ដោយប្រកាន់ភ្ជាប់នូវគោលការណ៍ និងស្មារតីភ្ញាក់រលឹក ធ្វើការកែទម្រង់ជាប្រចាំតាមអភិក្រម៥ យ៉ាងរបស់ **សម្តេចតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺ «**ងូតទឹក ឆ្លុះកញ្ចក់ ដុសក្អែល ព្យាបាល និងវះកាត់** »៕■

*រៀបចំដោយ÷ ផ្នែកអនុវត្តថវិកានៃ អ. គ. ហ.*

# ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា

*ក្នុងការគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជាបច្ចុប្បន្ន រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន០៥ ដូចខាងក្រោម÷*

*១). ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន*

*២). ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់*

*៣). ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម*

*៤). ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត*

*៥). ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលត្រូវមានស្តង់ដារ និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។*

តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះខាងលើ និងវិធានការជាយុទ្ធសាស្ត្រទាំងឡាយ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា នៅតែត្រូវបានវាយតម្លៃ និងទទួលស្គាល់ថាមាន “**ចីរភាព**” និង “**ហានិភ័យកម្រិតទាប**” បើទោះជាសេដ្ឋកិច្ចកម្ពុជា

ក្រាហ្វទី១ ÷ស្ថានភាពបំណុលសាធារណៈ គិតត្រឹមដំណាច់ឆ្នាំ២០២០



កំពុងទទួលរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ក្តី។ ជាក់ស្តែង គិតត្រឹមដំណាច់ឆ្នាំ២០២០ រាល់សូចនាករបំណុលទាំងអស់សុទ្ធតែស្ថិតក្រោមអនុបាតគោល ក្នុងនោះ សូចនាករបំណុលសំខាន់ជាងគេគឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស ស្ថិតក្នុងកម្រិត **២៤%** ធៀបនឹងអនុបាតគោល **៤០%**។ តួលេខលម្អិតនៃស្ថានភាពបំណុលសាធារណៈ មាននៅក្នុងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំជាប្រចាំរៀងរាល់មួយឆមាសម្តង និងផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័រផ្លូវការដែលសាធារណជនអាចទាញយកបានតាមរយៈ÷ http://mef.gov.kh/public-debt-bulletin.html ឬ នៅលើគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលតាមរយៈ÷ https://gdicdm.mef.gov.kh/en/cat/documents-and-publications/bulletins។

*គិតត្រឹមដំណាច់ឆ្នាំ២០២០ រាល់សូចនាករបំណុលទាំងអស់សុទ្ធតែស្ថិតក្រោមអនុបាតគោល ក្នុងនោះសូចនាករបំណុលសំខាន់ជាងគេគឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស ស្ថិតក្នុងកម្រិត ២៤% ធៀបនឹងអនុបាតគោល៤០%។*

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ មានពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ដោយអនុលោមទៅតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្តជាអន្តរជាតិ ដែលមានវិសាលភាពគ្របដណ្តប់លើទិន្នន័យស្តីពី÷

១) បំណុលសាធារណៈក្រៅប្រទេស

២) បំណុលសាធារណៈក្នុងប្រទេស

៣) ការផ្តល់ឥណទានរបស់រដ្ឋដល់សហគ្រាសសាធារណៈ ព្រមទាំងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកអានទិន្នន័យទាំងអស់ត្រូវបានបែងចែកជា ៤ ក្រុមគឺ÷

❶. ការចុះកិច្ចព្រមព្រៀងខ្ចី

❷. ការដកសាច់ប្រាក់

❸. សេវាបំណុល (ការទូទាត់ជូនឥណទាយក និងការប្រមូលពីឥណទាយិកក្រោមក្របខណ្ឌ នៃការផ្តល់ឥណទានរបស់រដ្ឋ)

❹. សន្និធិបំណុល ហើយដែលត្រូវបានចាត់ចំណាត់ប្រភេទទៅតាម÷វិស័យ ឥណទាយក/ឥណទាយិក និងរូបិយប័ណ្ណ។

**ក្រាហ្វទី២÷ សន្និធិបំណុលសាធារណៈកម្ពុជា ធៀបនឹង ផសស**




*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល*



# ផ្នែកទី ៣

# សុន្ទរកថា

# សុន្ទរកថា
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី «អនាគតរបស់អាស៊ី»
# ក្រោមប្រធានបទ «ការរៀបចំសម័យកាលថ្មីក្រោយវិបត្តិកូវីដ តួនាទីរបស់អាស៊ីក្នុងការស្តារពិភពលោកឡើងវិញ»

ថ្លែងតាមប្រព័ន្ធវីដេអូ, ថ្ងៃទី២០-២១ ខែឧសភា ឆ្នាំ២០២១

*-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសទាំងអស់*

*-លោក រ៉ូ តាកាហាស៊ី (Taro Takahashi) និពន្ធនាយកទទួលបន្ទុកតំបន់អាស៊ី នៃទីស្នាក់ការ កណ្តាលសម្រាប់តំបន់អាស៊ី*

*-ឯកឧត្តម លោកជំទាវ, លោក, លោកស្រី!*



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី "អនាគតរបស់អាស៊ី" តាមរយៈប្រព័ន្ធវីដេអូ នៅថ្ងៃទី២០-២១ ខែឧសភា ឆ្នាំ២០២១*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីរីករាយជាអនេក ដែលបានចូលរួមជាមួយថ្នាក់ដឹកនាំនៃបណ្តាប្រទេស ក្នុងតំបន់អាស៊ីដទៃទៀត ថ្លែងសុន្ទរកថាក្នុងសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី «អនាគតរបស់អាស៊ី» ក្រោមប្រធានបទ«**ការរៀបចំសម័យកាលថ្មីក្រោយវិបត្តិកូវីដ÷ តួនាទីរបស់អាស៊ីក្នុងការស្តារពិភពលោកឡើងវិញ**» នាថ្ងៃនេះ។ ជាមួយគ្នានេះ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះ ក្រុមហ៊ុននីកកេ (Nikkei) ដែលបាន ខិតខំរៀបចំវេទិកានេះឡើងតាមរយៈប្រព័ន្ធវីដេអូ លើប្រធានបទដ៏មានសារៈសំខាន់នេះ សម្រាប់ថ្នាក់ដឹកនាំ និងដៃគូពាក់ព័ន្ធទាំងអស់ ពិភាក្សា និងផ្លាស់ប្តូរទស្សនៈអំពីស្ថានការណ៍ និងការវិវឌ្ឍក្នុងតំបន់ និងសកលលោកជាពិសេស ការគិតគូរអំពីទិសដៅអនាគត សម្រាប់កិច្ចអភិវឌ្ឍតំបន់អាស៊ីក្នុង និងក្រោយពេលវិបត្តិជំងឺកូវីដ-១៩។

ជាការពិតណាស់ ឆ្នាំ២០២០ គឺជាឆ្នាំដ៏លំបាកបំផុតក្នុងប្រវត្តិសាស្ត្រទំនើបរបស់ពិភពលោកដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបាននិងកំពុងបង្កជាវិបត្តិសុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរ និងឈានដល់ការបន្ទច់បង្អាក់ការអភិវឌ្ឍ សេដ្ឋកិច្ច-សង្គម ជាសកល។ គ្រប់ប្រទេស និងតំបន់លើសកលលោកសុទ្ធសឹងតែកំពុងរងការប៉ះទង្គិចលើគ្រប់វិស័យ ហើយប្រជាជនជាងមួយរយលាននាក់បានឆ្លង និងរាប់លាននាក់ត្រូវបានបាត់បង់អាយុជីវិត។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចសកលក៏ធ្លាក់ចុះក្នុងអត្រាអវិជ្ជមាន ដែលមិនធ្លាប់មានបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកល (Global Financial Crisis) ដោយសារការបង្អាក់ភ្លាមៗ មកលើសកម្មភាពសេដ្ឋកិច្ច, ពាណិជ្ជកម្ម, ច្រវាក់ផ្គត់ផ្គង់, ការតភ្ជាប់ និងការធ្លាក់ចុះយ៉ាងគំហុក នៃតម្រូវការពិភពលោក គួបផ្សំនឹងការដាក់ចេញនូវវិធានការរដ្ឋបាលរឹតត្បិតការធ្វើដំណើរ និងបិទខ្ទប់ប្រទេស ដើម្បី ទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

យ៉ាងណាមិញ ទោះបីសេដ្ឋកិច្ចសកលឆ្នាំ២០២១ នេះ ត្រូវបានរំពឹងថានឹងងើបឡើងវិញក៏ដោយ, សកលលោកនៅតែ

ប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ដោយសារហានិភ័យពីរលកថ្មី នៃជំងឺកូវីដ-១៩ និងការបំប្លែងខ្លួនថ្មីនៃវីរុសកូរ៉ូណា ដែលមានសភាពកាន់តែកាចសាហាវ និងស្រួចស្រាល់ ដែលអាចនឹងបន្តរំខានដល់ជីវភាពសេដ្ឋកិច្ចសកល។ បន្ថែមលើនេះ ការទទួលបានវ៉ាក់សាំង ដែលអាចធានាបាននូវភាពស៊ាំសហគមន៍ (Herd Immunity) នឹងត្រូវចំណាយពេលយូរទៀត ស្របពេលដែលគម្លាតនៃការទទួលបានវ៉ាក់សាំងរវាងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍន៍ នឹងធ្វើឱ្យមានវិសមភាពសម្រាប់ការងើបឡើងវិញ នៃសេដ្ឋកិច្ចដោយសារមានតែប្រទេសមួយចំនួនប៉ុណ្ណោះអាចស្តារសេដ្ឋកិច្ចខ្លួនឡើងវិញបានប្រសើរ ខណៈដែលប្រទេសជាច្រើនផ្សេងទៀតនឹងបន្តប្រឈមនឹងផលប៉ះពាល់ទាំងក្នុងផ្នែកសុខាភិបាល និងផ្នែកសេដ្ឋកិច្ច។

ជាងនេះទៅទៀត ពិភពលោកទាំងមូលក៏កំពុងបន្តប្រឈមនឹងវិបត្តិ និងហានិភ័យជាច្រើនទៀតផងដែរ ជាពិសេស ការកើនឡើងនូវភាពតានតឹងនៃស្ថានភាពភូមិសាស្ត្រនយោបាយតំបន់ និងសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងប្រទេសមហាអំណាចនានា ក៏នឹងជះឥទ្ធិពលដល់ការអភិវឌ្ឍសកលសម្រាប់ ទាំងរយៈពេលខ្លី និងវែងខាងមុខ។ ម្យ៉ាងទៀត កត្តាគំរាមកំហែងលើសន្តិភាព, ស្ថិរភាព និងសន្តិសុខផ្សេងៗទៀតក៏កំពុងលេចឡើងកាន់តែច្បាស់ និងបង្កើនការដាក់សម្ពាធមកលើតំបន់អាស៊ីយើងរួមមាន និន្នាការពហុប៉ូល ការប្រកួតប្រជែងដើម្បីផលប្រយោជន៍ ការប្រែប្រួលនៃតុល្យភាពអំណាចក្នុងតំបន់ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិជាដើម ដែលការណ៍ទាំងនេះបាននិងកំពុងបង្កផលប៉ះពាល់ដល់ និងអាចបង្អាក់ បង្អាក់ និរន្តភាពនៃដំណើរការអភិវឌ្ឍផងដែរ។

*“ កម្ពុជានឹងផ្តល់អាទិភាពលើការកែទម្រង់ដោយបន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមាន ការធ្វើឱ្យប្រសើរឡើងបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្ម, ការវិនិយោគ និងធុរកិច្ច, និងការជំរុញនិងការអភិវឌ្ឍឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ចទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។”*

*-ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ក្នុងបរិការណ៍នេះ ខ្ញុំយល់ថាអាស៊ី គឺពិតជាតំបន់ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួសត្រាយ ផ្លូវដល់ការរៀបចំសម័យកាលថ្មីក្រោយវិបត្តិកូវីដ ជាមួយនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន។ ជាក់ស្តែង វិបត្តិជំងឺកូវីដ-១៩ ក៏បានសបញ្ជាក់យ៉ាងច្បាស់សារជាថ្មីថា អាស៊ីគឺនៅតែជាតំបន់ មួយដែលបន្តមានសក្តានុពល និងជាក្តីរំពឹងក្នុងការជំរុញការងើបឡើងវិញនៃការអភិវឌ្ឍរបស់សកលលោក។ ក្នុងឆ្នាំ២០២០ បើទោះបីជាពិភពលោកបានជួបប្រទះនឹងកំណើនអវិជ្ជមានក្តី ប្រទេសមួយចំនួននៅតំបន់អាស៊ីនៅតែអាចរក្សាបាននូវកំណើនវិជ្ជមាន។ ជាងនេះទៅទៀត បច្ចុប្បន្ន ប្រទេសមួយចំនួន ក្នុងតំបន់ អាស៊ីបានចាប់ផ្តើមនាំមុខលើការជំរុញការស្តារសេដ្ឋកិច្ចតំបន់ និងសកលដោយទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ បានល្អប្រសើរក្នុងប្រទេសរបស់ខ្លួនជាពិសេស



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី "អនាគតរបស់អាស៊ី" តាមរយៈប្រព័ន្ធវីដេអូ នៅថ្ងៃទី២០-២១ ខែឧសភា ឆ្នាំ២០២១*

ផ្តល់ការជួយជ្រោមជ្រែងក្នុងការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញរបស់បណ្តាប្រទេសក្នុងតំបន់ តាមរយៈការផ្តល់ជំនួយ, កិច្ចសហប្រតិបត្តិការ និងគំនិតផ្តួចផ្តើមនានាផងដែរ។

ដោយឡែក គួរកត់សម្គាល់ផងដែរថា មុននឹងវិបត្តិជំងឺកូវីដ-១៩, កំណើនខ្ពស់ និងការអភិវឌ្ឍលឿន របស់ប្រទេសក្នុងតំបន់អាស៊ីនៅក្នុងរយៈពេល០២ ទសវត្សរ៍ចុងក្រោយនេះបានប្រែក្លាយតំបន់យើងទៅជា កម្លាំងចលករ ដ៏សំខាន់សម្រាប់វឌ្ឍនភាពសង្គម-សេដ្ឋកិច្ច,ការកាត់បន្ថយភាពក្រីក្រ និងការបង្កើនប្រាក់ចំណូលប្រជាជន។ មកទល់ពេលនេះ ចិនជាប្រទេសមានសេដ្ឋកិច្ចធំលំដាប់ទី២ និងជប៉ុនលំដាប់ទី៣ ខណៈដែលសហគមអាស៊ាន និងឥណ្ឌា មានលំដាប់ ទី៥ និងទី៦ រៀងគ្នានៅលើពិភពលោក។ បន្ថែមលើនេះ ជាមួយនឹងប្រជាជនសរុបប្រមាណជិត៦០% នៃប្រជាជនពិភពលោក និងផលិតផលក្នុងស្រុក សរុប (ផ.ស.ស.) ប្រមាណជា៣០% នៃ ផ.ស.ស. ពិភពលោក, អាស៊ីគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ច, ទីផ្សារ និងចំណុចតភ្ជាប់ (connecting dot) ដ៏សំខាន់ដែលមានសក្តានុពលខ្ពស់ក្នុងការស្តារ និងជំរុញកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ចសកលលោក។ ក្នុងន័យនេះ ក្នុងបរិបទបច្ចុប្បន្នផ្អែកលើថាមភាព និងសក្តានុពល នេះ, សេដ្ឋកិច្ចអាស៊ីនឹងក្លាយជា **ក្បាលម៉ាស៊ីន** នៃការអូសទាញកំណើនសេដ្ឋកិច្ចសកលឱ្យងើបឡើងវិញ ឆាប់រហ័សពីវិបត្តិជំងឺកូវីដ-១៩ ប្រកបដោយចីរភាព។

ដើម្បីជំរុញការងើបឡើងវិញនៃសង្គម-សេដ្ឋកិច្ចប្រកបដោយសមធម៌ ចីរភាព និងបរិយាបន្ន ខ្ញុំសូម គូសរំលេចនូវទស្សនៈមួយចំនួន លើកិច្ចការអាទិភាព និងទិសដៅកិច្ចសហប្រតិបត្តិការ ដែលយើងទាំងអស់គ្នាត្រូវចាំបាច់គិតគូរ÷

**ទី១.** ចំពោះមុខ, ការទប់ស្កាត់ការឆ្លងរីករាលដាល និងការគ្រប់គ្រងផលប៉ះពាល់ដែលបណ្តាលមក ពីជំងឺកូវីដ-១៩ គឺជាកិច្ចការចាំបាច់បំផុត ដើម្បីឱ្យប្រទេសទាំងអស់អាចចាប់ផ្តើមដំណើរការស្តារ និងងើបឡើងវិញបានប្រកបដោយប្រសិទ្ធភាព។ ការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងជាលក្ខណៈសកលបែបនេះ ទាមទារ នូវសាមគ្គីភាព, ការជឿទុកចិត្ត, ការគិតគូរ និងអនុវត្តរួមគ្នាប្រកបដោយភាពហ្មត់ចត់ និងក្រោមយន្តការពហុភាគីនិយម និងគោរពច្បាប់អន្តរជាតិ និងអធិបតេយ្យភាពរបស់ប្រទេសនីមួយៗ។ ក្នុងស្មារតីនេះ អាស៊ីត្រូវផ្តល់អាទិភាពខ្ពស់ និងភាពចាំបាច់បំផុតក្នុងការធានាថា វ៉ាក់សាំងបង្ការ និងថ្នាំព្យាបាលជំងឺកូវីដ-១៩ គឺជា ទំនិញសាធារណៈសកល (global public goods) ដែលនឹងត្រូវបានផ្គត់ផ្គង់ និងចែកចាយក្នុងស្មារតីមនុស្សធម៌ទៅដល់គ្រប់ប្រទេសទាំងអស់ ជាពិសេសប្រទេសដែលងាយរងគ្រោះ។

**ទី២.** អាស៊ីចាំបាច់ត្រូវដឹកមុខក្នុងការបើកចំហរនូវទីផ្សារពាណិជ្ជកម្មលើឧបករណ៍វេជ្ជសាស្ត្រ និងការផ្គត់ផ្គង់ស្បៀងអាហារដោយមិនត្រូវបានដាក់កម្រិតណាមួយនោះទេ, ជាពិសេសត្រូវកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ និងកែសម្រួលវិធានមិនមែនពន្ធនានា លើទំនិញ និងសេវាកម្មវេជ្ជសាស្ត្រ, និងលុបបំបាត់ការរឹតត្បិតការនាំចេញស្បៀងទៅកាន់ទីផ្សារអន្តរជាតិ។ ម្យ៉ាងវិញទៀត ក្នុងបរិបទ នៃការរាតត្បាតជំងឺកូវីដ-១៩ យើងត្រូវជំរុញ បរិវត្តន៍ឌីជីថល (digital transformation) តំបន់ ដែលជាប្រភពកំណើនថ្មីសម្រាប់ ជំរុញកំណើនសេដ្ឋកិច្ចតំបន់ តាមរយៈការផ្តួចផ្តើម និងជំរុញការរៀបចំអភិបាលកិច្ចរួម សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលរាប់បញ្ចូលទាំងការកំណត់ស្តង់ដារបទប្បញ្ញត្តិ, ឯកជន-



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណា*
*តាមរយៈប្រព័ន្ធវីដេអូ នៅថ្ងៃទី២០-២១ ខែឧសភា ឆ្នាំ២០២១*

ភាព និងការចែក រំលែកទិន្នន័យជាដើម។

**ទី៣.** ជាងនេះទៅទៀត អាស៊ីត្រូវពង្រឹងយន្តការក្នុងតំបន់ក្នុងការសម្របសម្រួលការដាក់ចេញគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុតំបន់ ទន្ទឹមនឹងការបន្តខិតខំជំរុញលើកកម្ពស់ពិពិធកម្មវិស័យហិរញ្ញវត្ថុ, នវានុវត្តន៍ ក៏ដូចជាជំរុញលើកស្ទួយតួនាទី និងជីវភាពរបស់វិស័យឯកជន សំដៅជំរុញការវិនិយោគ និងមូលធនឯកជនទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឬ អភិវឌ្ឍទាប ជាពិសេសគឺការវិនិយោគផ្ទាល់ពីបរទេស ដើម្បីបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុសម្រាប់ការស្តារ ឡើងវិញនូវកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព។

**ទី៤.** ការពង្រឹងគោលការណ៍សកលភាវូបនីយកម្ម, យន្តការពហុភាគីនិយម និងសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម និងការវិនិយោគ នៅតែជាកិច្ចការចាំបាច់ តាមរយៈការបន្តធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ស៊ីជម្រៅ និងពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់, ឧស្សាហកម្ម, ទិន្នន័យព័ត៌មាន, ធនធានមនុស្ស និងកិច្ចសម្រួល ពាណិជ្ជកម្ម។ នាពេលបច្ចុប្បន្នការបាត់បង់ភាពជឿទុកចិត្ត,



*ចក្រកម្ពុជា ថ្លែងក្នុងសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី "អនាគតរបស់អាស៊ី "*

ការប្រកួតប្រជែង, គម្លាតការអភិវឌ្ឍ និងកម្រិតប្រាក់ចំណូល និងវិសមភាពសង្គម បានបង្កឱ្យមានការភ័យខ្លាច ឬបាត់បង់ការគាំទ្រលើគោលការណ៍សកលភាវូបនីយកម្មជាបណ្តើរៗ ស្របជាមួយនឹងការចាកចេញពីយន្តការពហុភាគីនិយមដោយការគេចវេះពីគោលការណ៍ និងវិធាន នៃច្បាប់អន្តរជាតិ។ ទិដ្ឋភាពទាំងនេះបាន និងកំពុងបង្កក្តីបារម្ភ និងភាពតានតឹងនៅក្នុងសហគមន៍អន្តរជាតិ។ ដូច្នេះ អាស៊ីត្រូវលើកកម្ពស់តួនាទីដឹកនាំរបស់ខ្លួនក្នុងការធានាឱ្យបាននូវកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីបើកចំហ (openness) និងការគាំទ្រប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដើម្បីបន្តលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម ព្រមទាំងធ្វើសមាហរណកម្មការតភ្ជាប់គ្រប់វិស័យ ដើម្បីពង្រឹងភាពធន់របស់យើងចំពោះការផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ច និងសង្គម។

ជារួម អាស៊ីត្រូវបន្តកសាង និងថែរក្សាសន្តិភាព និងសន្តិសុខក្នុងប្រទេស និងតំបន់ដែលជាគ្រឹះមិនអាចខ្វះបាន សម្រាប់កិច្ចការងារស្តារសង្គមសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាការអភិវឌ្ឍរយៈពេលវែង។ ជាងនេះទៅទៀតក្នុងកិច្ចដំណើរការស្តារឡើងវិញ អាស៊ីចាំបាច់ត្រូវពង្រឹងភាពជាដៃគូរវាង បណ្តាប្រទេសក្នុងតំបន់ និងរវាងប្រទេសនានា លើសកលលោក ក៏ដូចជាតួអង្គអភិវឌ្ឍន៍ទាំងអស់។ ដើម្បីសម្រេចគោលបំណងរួមរបស់យើង ប្រកបដោយជោគជ័យ យើងត្រូវតែគោរពនូវគោលការណ៍សន្តិសហវិជ្ជមាន, ការមិនជ្រៀតជ្រែក និងការគោរពបែបផែននៃការរស់នៅ, វប្បធម៌, ប្រពៃណី និងប្រវត្តិសាស្រ្ត ដែលជាគុណតម្លៃរបស់ប្រទេសនីមួយៗ ក្នុងគោលដៅពង្រឹងតម្លៃ នៃសន្តិភាព, សេចក្តីថ្លៃថ្នូរ និងសាមគ្គីភាព។

*-ឯកឧត្តម, លោកជំទាវ, លោក , លោកស្រី!*

កម្ពុជា ផ្តើមចេញពីប្រទេសតូច ដែលធនធានមានកម្រិត ប្តេជ្ញាបន្តខិតខំពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការនានាសំដៅចូលរួមដោះស្រាយបញ្ហាប្រឈមរួម ដើម្បីកសាងភាពធន់ទៅនឹងវិបត្តិ និងធានាឱ្យបាននូវចីរភាព និងបរិយាបន្នកម្ម នៃការអភិវឌ្ឍសេដ្ឋកិច្ច- សង្គមទាំងក្នុងក្របខណ្ឌតំបន់ និងសកល។ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាប្រែក្លាយវិបត្តិនៃជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការដ្ឋានកំណែទម្រង់កាន់តែស៊ីជម្រៅសំដៅកសាងប្រព័ន្ធសេដ្ឋកិច្ច និងសង្គម ដែលកាន់តែរឹងមាំ និងមានភាពធន់ទៅនឹងវិបត្តិនាពេលអនាគត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំ ហើយគ្រោងនឹងដាក់ចេញនូវផែនការស្តារសេដ្ឋកិច្ចឡើងវិញ ពីវិបត្តិកូវីដ-១៩ សម្រាប់ឆ្នាំ២០២១-២០២៣ ក្នុងគោលបំណង *"អូសទាញកំណើន សេដ្ឋកិច្ចឱ្យត្រឡប់ទៅខិតជិតកំណើនសក្តានុពលប្រកបដោយចីរភាព និងបរិយាបន្នកម្ម តាមរយៈការធានា រក្សានូវសន្តិភាព, សន្តិសុខ, ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ លើគន្លងនៃប្រក្រតីភាពថ្មី ព្រមទាំង ការលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេស មូលដ្ឋានឧស្សាហកម្មរឹងមាំ ដែលមានសមត្ថភាពនាំចេញខ្ពស់ និងផ្សារភ្ជាប់កាន់តែខ្លាំងក្លាជាមួយច្រវាក់ផ្គត់ផ្គង់តំបន់ និងពិភពលោក"*។

លើមូលដ្ឋានទាំងនេះ កម្ពុជានឹងផ្តល់អាទិភាពលើការ (១). ស្តារឡើងវិញដោយកសាងមូលដ្ឋានរឹងមាំ សម្រាប់សេដ្ឋកិច្ចវិលទៅមាគ៌ានៃកំណើនឡើងវិញ ដោយផ្តោតលើការធានាសុវត្ថិភាព, ការគ្រប់គ្រងផលប៉ះពាល់, ការរក្សាលំនឹង និងការជំរុញឱ្យងើបឡើងវិញនៃធុរកិច្ចដែលមានសក្តានុពល ជាពិសេស ក្នុងវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំង និងការបង្កើតការងារបន្ថែមឱ្យបានច្រើន និងឆាប់រហ័ស; (២). កែទម្រង់ ដោយបន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមាន ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្ម, ការវិនិយោគ និងធុរកិច្ច, និង ការជំរុញ និងការអភិវឌ្ឍឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និងវិស័យឯកជន; និង (៣). កសាងភាពធន់ ដោយពង្រឹងការត្រៀមខ្លួន និងការឆ្លើយតបទៅនឹងជំងឺ ឬស្ថានភាពស្រដៀងគ្នា ដែលអាចផ្ទុះឡើងនាពេល អនាគត ដោយផ្តោតលើការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដែលរឹងមាំ, មានប្រសិទ្ធភាព និងការធានានូវចីរភាព និងបរិយាប័ន្នកម្មនៃការស្តារ និងការអភិវឌ្ឍសេដ្ឋកិច្ច- សង្គម។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរឱ្យសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី «អនាគតរបស់អាស៊ី» នាពេល នេះ ទទួលបានជោគជ័យដ៏ត្រចះត្រចង់ ហើយខ្ញុំត្រូវត្រៀមឆ្លើយតបប្រសិនជាមានសំណួរ៕■

***សូមអរគុណ!***

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីប្រកាសដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

ថ្ងៃចន្ទ ១០រោច, ខែជេស្ឋ, ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០, ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រី*

*-ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា*

*-សមាជិក សមាជិកានៃអង្គពិធីជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំមានមោទនភាព និងកិត្តិយសដ៏ឧត្តុង្គឧត្តម ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី សំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យខ្ញុំធ្វើជាអធិបតីនៅក្នុងពិធីប្រកាសដាក់ដំណើរការជាផ្លូវការ នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដែលជាបង្គោលចរថ្មីមួយនៃកំណែទម្រង់មុតស្រួចរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងគោលបំណងលើកកម្ពស់ភាពប្រកួតប្រជែងនិងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគនៅក្នុងប្រទេស។




*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងពិធីប្រកាសដាក់ដំណើរការជាផ្លូវការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។*

ទោះបីជាកម្ពុជា, ក៏ដូចជាពិភពលោកទាំងមូល, កំពុងតែបន្តទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩, រាជរដ្ឋាភិបាល, ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណដ៏ឈ្លាសវៃ, ចក្ខុវិស័យវែងឆ្ងាយ និងភាពប្រាកដនិយមរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, មិនបានបន្ថយល្បឿននៃការងារកែទម្រង់របស់ខ្លួនទេ។ ផ្ទុយទៅវិញ, យើងចាត់ទុកកាលៈទេសៈនៃវិបត្តិនេះ ជាកាលានុវត្តភាពសម្រាប់ជំរុញកិច្ចការកែទម្រង់មុតស្រួច ឱ្យកាន់តែសកម្មឡើងថែមទៀត សំដៅឆ្លើយតបទៅនឹងវិបត្តិផង និងសំលៀងសម្រេចភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ដើម្បីជំរុញធ្វើពិពិធកម្មមូលដ្ឋាននៃកំណើន និងគាំទ្រដល់កំណើនប្រកបដោយចីរភាពសម្រាប់រយៈពេលវែងផង។ ក្នុងស្មារតីនេះ, ម្ខាង, រាជរដ្ឋាភិបាលបានរៀបចំដាក់ចេញនូវវិធានការចម្រុះ, ធំៗ, ទាំង វិធានការខាងរដ្ឋបាល, វិធានការខាងសុខាភិបាល និងវិធានការខាងសង្គម-សេដ្ឋកិច្ច(ចំនួន៤ ជុំរួចមកហើយ) សំដៅប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ផង និងជួយរក្សាលំនឹងអាជីវកម្មក្នុងវិស័យមួយចំនួន ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងជួយសម្រាលបន្ទុកដល់ជីវភាពរបស់បងប្អូនកម្មករ-និយោជិត និងប្រជាជនក្រីក្រងាយរងគ្រោះផង ដែលមកដល់ពេលនេះ អាចវាយតម្លៃបានថាកម្ពុជាសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់ និងម្ខាងទៀត រាជរដ្ឋាភិបាលក៏បន្តជំរុញការអនុវត្តជាប់មិនដាច់នូវកម្មវិធីកែទម្រង់

នានាដែលត្រូវបានដាក់ចេញនាពេលកន្លងមក គួបផ្សំជាមួយនឹងការដាក់ចេញបន្ថែមនូវវិធានការកែទម្រង់មុតស្រួចជាប្រព័ន្ធប្រទាក់ក្រឡាគ្នា សំដៅលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងដំណាក់កាល ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩។



*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

កន្លងមក, វិស័យឯកជនបានបង្ហាញពីកង្វល់ និងលើកឡើងបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងដំណើរការចុះបញ្ជីអាជីវកម្មនៅកម្ពុជា ដែលត្រូវប្រើពេលយូរ, ចំណាយថវិកាច្រើន, ឆ្លងកាត់នីតិវិធីច្រើន និងស្មុគស្មាញ នៅតាមក្រសួង-ស្ថាប័នជាច្រើនដាច់ដោយឡែកពីគ្នា ដែលតម្រូវឱ្យមានការផ្តល់ព័ត៌មានច្រើនដង និងច្រំដែល។ ជាការឆ្លើយតប, **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសម្រេចដាក់ចេញនូវវិធានការមុតស្រួចជាកញ្ចប់ កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៨, សំដៅលើកស្ទួយភាពប្រកួតប្រជែងរបស់កម្ពុជា ដែលក្នុងកញ្ចប់នៃវិធានការនេះ មានរួមបញ្ចូលនូវវិធានការនៃ «**ការរៀបចំនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន**» នេះផងដែរ។

តាមរយៈរបាយការណ៍របស់ឯកឧត្តម **ផាន់ ផល្លា** ប្រធានក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន, យើងឃើញថាប្រព័ន្ធចុះបញ្ជីអាជីវកម្មនេះ ពិតជាបានឆ្លុះបញ្ចាំងនូវស្មារតីនៃការកែទម្រង់មុតស្រួចរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** តាមរយៈការកាត់បន្ថយជាអតិបរមានូវនីតិវិធីស្មុគស្មាញ, ពេលវេលា និងចំណាយ ដែលកើតមាននៅតាមបណ្តាដំណាក់កាលនៃការចុះបញ្ជីក្រុមហ៊ុននៅក្នុងក្របខណ្ឌយន្តការចាស់។ ខ្ញុំពិតជាមានសេចក្តីរីករាយ និងសូមវាយតម្លៃខ្ពស់ចំពោះប្រព័ន្ធចុះបញ្ជីថ្មីនេះ ដែលអនុញ្ញាតឱ្យធុរជនអាចធ្វើការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម, ចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ និងធ្វើសេចក្តីប្រកាសផ្តល់ដំណឹងបើកសហគ្រាស ជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**ក្នុងពេលតែមួយ និងត្រូវការពេលវេលាយ៉ាងយូរត្រឹម៨ ថ្ងៃ នៃថ្ងៃធ្វើការប៉ុណ្ណោះ ជាមួយនឹងចំណាយតិចជាងមុនរហូតជាងពាក់កណ្តាល។** ការរៀបចំឱ្យបាននូវការចុះបញ្ជីដ៏មានប្រសិទ្ធភាព និងចំណាយតិចជាងមុន គឺជាគោលបំណងដ៏ពិសិដ្ឋរបស់រាជរដ្ឋាភិបាល ក្នុងការជួយសម្រួល និងកាត់បន្ថយជា អតិបរិមា នូវបញ្ហាប្រឈមដែលវិនិយោគិនជួបប្រទះ ក៏ដូចជាលើកទឹកចិត្តដល់អាជីវកម្មថ្មីៗទៀត ឱ្យមកចុះបញ្ជី ប្រែក្លាយជាអាជីវកម្មស្របច្បាប់។

ទន្ទឹមនេះ, ខ្ញុំក៏សូមចូលរួមអបអរសាទរក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបន្ទាប់ពីទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានខិតខំបញ្ចប់នូវប្រព័ន្ធចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន និងបានភ្ជាប់ខ្លួនជាមួយប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានរួចរាល់ក្នុងពេលដ៏ខ្លី។ តទៅមុខ, ប្រព័ន្ធទាំងពីរនេះនឹងចាប់ផ្តើមធ្វើសមាហរណកម្មព្រមទាំងផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ដែលការងារនេះនឹងផ្តល់ភាពងាយស្រួលយ៉ាងច្រើនដល់វិនិយោគិន ពោលគឺលែងមានការតម្រូវឱ្យផ្តល់ព័ត៌មានច្រើនដង ហើយអាចទទួលបានមកវិញនូវឯកសារគតិយុត្ត នៅក្នុងរយៈពេលខ្លី។ កំណែទម្រង់នេះ នឹងចូលរួមលើកកម្ពស់ភាពទាក់ទាញរបស់កម្ពុជា ដោយប្រែក្លាយកម្ពុជាទៅជាទិសដៅវិនិយោគប្រកបដោយសក្តានុពល ជាពិសេសនៅក្នុងបរិការណ៍នៃការប្រែប្រួលខ្សែច្រវាក់ផលិតកម្មសកល និងការផ្លាស់ប្តូរទីតាំងរបស់រោងចក្រ។

លើសពីនេះ, ប្រព័ន្ធចុះបញ្ជីថ្មីនេះ នឹងផ្តល់ឱកាសដ៏សំខាន់មួយទៀតផងដែរ ដល់ធុរជនដែលកំពុងចង់បានឯកសារគតិយុត្តកំណត់អត្តសញ្ញាណអាជីវកម្មរបស់ខ្លួន ដើម្បីពន្លឿន និងទទួលបានឥណទានពីកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាលក្នុងវិធានការជួយដល់វិស័យឯកជន ដែលទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ក្នុងន័យនេះ, ខ្ញុំសូមស្នើ និងលើកទឹកចិត្តឱ្យធុរជនប្រើប្រាស់ និង ទាញប្រយោជន៍ពីប្រព័ន្ធ និងយន្តការនៃការចុះបញ្ជីអាជីវកម្មថ្មីនេះឱ្យអស់សក្តានុពល។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ក្នុងស្មារតីជួយសម្រួលបន្ថែមដល់ដំណើរការចុះបញ្ជីអាជីវកម្ម, កែសម្រួលបរិយាកាសធ្វើធុរកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា, រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បានបង្កើតថ្នាលផ្លាស់ប្តូរទិន្នន័យជាឆ្អឹងខ្នងមួយ ដែលមានឈ្មោះថា Cambodia Data Exchange ឬ CamDX ដែលអនុញ្ញាតឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នសម្រាប់ការចុះបញ្ជីក្រុមហ៊ុន អាចផ្លាស់ប្តូរទិន្នន័យជាមួយគ្នាបាន ដោយមិនចាំបាច់ច្របាច់បញ្ចូលគ្នាជាប្រព័ន្ធតែមួយ និងមិនត្រូវការចំណាយវិនិយោគច្រើន ដោយឈរលើ «**គោលការណ៍វិមជ្ឈការ**» (Decentralized Principle) **និង «គោលការណ៍ធ្វើតែមួយលើកគត់»** (The Once-only Principle)។

ប្រព័ន្ធចុះបញ្ជី និងការបង្កើតថ្នាលផ្លាស់ប្តូរទិន្នន័យនេះ គឺជាប្រព័ន្ធទីមួយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាលក្ខណៈអន្តរក្រសួងដោយទិន្នន័យទាំងអស់នឹងត្រូវបានបញ្ជូនចែករំលែកដោយស្វ័យប្រវត្តិ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង- ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការត្រួតពិនិត្យ និងផ្តល់ការអនុម័ត។ ដំណើរការនៅក្នុងការចុះបញ្ជី, ការដាក់ឯកសារយោង និងការទទួលបានមកវិញក្នុងទម្រង់អេឡិចត្រូនិកនូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម, វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ, ប័ណ្ណប៉ាតង់ ក៏ដូចជាឯកសារផ្សេងទៀតទាំងអស់ដែលនឹងត្រូវបានធ្វើឡើងទាំងស្រុងនៅលើថ្នាលបច្ចេកវិទ្យាព័ត៌មាន ហើយមិនមានការប្រើប្រាស់ជាឯកសាររូបី(ក្នុងទម្រង់រឹង)គឺជាការកែទម្រង់ដ៏ធំមួយនៅក្នុងវិស័យរដ្ឋបាលសាធារណៈ ជាពិសេសគឺការកែទម្រង់នូវផ្នត់គំនិត និង របៀបធ្វើការងាររបស់មន្ត្រី, ទាំងការប្រែក្លាយពីការពិនិត្យឯកសារជាទម្រង់រូបី ទៅជាទម្រង់អេឡិចត្រូនិក, ការពង្រឹងកិច្ចសហការរវាងស្ថាប័ន និងការពង្រឹងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ព្រមទាំងការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការលុបបំបាត់នូវការតម្រូវឱ្យមានការជួបគ្នារវាងមន្ត្រី និងអតិថជនដែលត្រូវការសេវារបស់ស្ថាប័នរដ្ឋ។


*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងពិធីប្រកាសដាក់ដំណើរការជាផ្លូវក នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។*

លើសពីនេះទៀត, អ្វីដែលយើងបានសម្រេចនាថ្ងៃនេះ គឺបានបង្ហាញអំពីគោលជំហររបស់រាជរដ្ឋាភិបាលក្នុងការទទួលយក និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាឧបករណ៍ដ៏សំខាន់មួយ ក្នុងការងារកែទម្រង់ និងការបង្កើនប្រសិទ្ធភាពលើការងាររដ្ឋបាលប្រចាំថ្ងៃ។ ការងារតូចមួយនេះ គឺជាជំហានដ៏ធំមួយនៃការចាប់ផ្តើមដំណើរការក្នុងភាពជាក់ស្តែង នូវរដ្ឋបាលគ្មាន



ការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

ក្រដាស ក្នុងលក្ខណៈទូលំទូលាយ, ជាការចូលរួមចំណែកដ៏សំខាន់ក្នុងការជំរុញអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិក និងបដិវត្តន៍ឧស្សាហកម្មទី៤ ហើយក៏ជាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពផងដែរទៅនឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ដែលបានបង្ខំឱ្យមនុស្សជាតិកាត់បន្ថយការជួបគ្នា តាមរយៈការជំរុញប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ក្នុងន័យនេះ, ជោគជ័យនៃ ប្រព័ន្ធនេះ នឹងក្លាយទៅជាកាតាលីករ ព្រមទាំងជាការលើកទឹកចិត្តដ៏សំខាន់មួយដល់រាជរដ្ឋាភិបាល ក្នុងការបន្តជំរុញប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការកែទម្រង់ផ្សេងៗទៀតនាអនាគត។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា,*

*លោកឧកញ៉ា, លោក, លោកស្រី!*

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រុមការងារអន្តរក្រសួង ដែលអាចបញ្ចប់បានទាំងស្រុងនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានក្នុងរយៈពេលតែមួយឆ្នាំ។ ខ្ញុំពិតជាមានមោទនភាព ដែលគម្រោងនវានុវត្តន៍នេះត្រូវបានគិតគូរ និងរៀបចំឡើងដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ខ្មែរសុទ្ធសាធ ដោយមិនបានប្រើប្រាស់ជំនួយបច្ចេកទេសពីបរទេសសោះឡើយ។ ខ្ញុំសូមយកឱកាសដ៏វិសេសវិសាលនេះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដែលក្នុងនោះរួមមាន÷អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពន្ធដារ, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី **«តេជោ»** នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ, ក្រសួងពាណិជ្ជកម្ម, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីរហូតសម្រេចបានលទ្ធផលដ៏ល្អប្រសើរ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ជាការគិតគូរបន្តទៅមុខទៀត, ខ្ញុំសូមគូសបញ្ជាក់ផងដែរថា ពិធីប្រកាសដាក់ដំណើរការជាផ្លូវការនូវ «**ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន**» នាពេលនេះ គ្រាន់តែជាដំណាក់កាលទី១ ដែលផ្តោតជាសំខាន់លើការចុះបញ្ជីអាជីវកម្មថ្មីតែប៉ុណ្ណោះ។ នៅក្នុងដំណាក់កាលបន្ទាប់, រាជរដ្ឋាភិបាលនឹងបន្តពង្រីកវិសាលភាពនៃប្រព័ន្ធនេះ ឈានទៅគ្របដណ្តប់ដល់គ្រប់ក្រសួង-ស្ថាប័នផ្សេងទៀត ដើម្បីរៀបចំការផ្តល់អាជ្ញាបណ្ណនានាតាមថ្នាលបច្ចេកវិទ្យាព័ត៌មានថែមទៀត។ ខ្ញុំក៏សូមស្នើឱ្យក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជី អាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន បន្តតាមដានធានាការអនុវត្តឱ្យបានរលូន និងវាយតម្លៃប្រសិទ្ធភាពនៃការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានេះ, ហើយក្នុងករណីចាំបាច់, ត្រូវបន្តកែសម្រួលប្រព័ន្ធនេះឱ្យបានកាន់តែប្រសើរឡើងថែមទៀត។

ទន្ទឹមនេះដែរ, ខ្ញុំសូមស្នើឱ្យគ្រប់តួអង្គពាក់ព័ន្ធបន្តលើកកម្ពស់ទស្សនៈ និងស្មារតីនៃការចូលរួមនៅក្នុងកិច្ចការកែទម្រង់របស់រាជរដ្ឋាភិបាល ឱ្យកាន់តែខ្ពស់ឡើងថែមទៀត ដើម្បីឧត្តមប្រយោជន៍របស់ជាតិកម្ពុជាទាំងមូល។ បន្ថែមលើនេះទៀត, ខ្ញុំក៏សូមលើកទឹកចិត្តឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ចូលរួមផ្សព្វផ្សាយដល់ធុរជន និងមហាជនទូទៅ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រព័ន្ធចុះបញ្ជីអាជីវកម្មថ្មីនេះ ឱ្យបានទូលំទូលាយ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យ ជូនដល់ឯកឧត្តម លោកជំទាវ, អ្នកឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធីទាំងមូល សូមជួបប្រទះតែពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ខ្ញុំសូមប្រកាសដាក់ឲ្យដំណើរការជាផ្លូវការនូវ «**ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការចុះបញ្ជីអាជីវកម្ម**» ពីពេលនេះតទៅ៕■

***សូមអរគុណ !***



## ផ្នែកទី ៤

# ទស្សនៈ និងមតិ



“ ក្នុងឆ្នាំ២០២០ កន្លងទៅ និងរហូតមកដល់ជិតពាក់កណ្ដាលឆ្នាំ២០២១នេះ កម្ពុជាក៏ដូចជាបណ្ដាប្រទេសនៅលើពិភពលោក បាននិងកំពុងរងនូវផលប៉ះពាល់អវិជ្ជមានពីជំងឺកូវីដ-១៩ មកលើបញ្ហាសុខភាព សង្គម សេដ្ឋកិច្ច ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ហើយថែមទាំងអាចបន្ទុចបង្អាក់ដល់កិច្ចដំណើរការអភិវឌ្ឍឈានឡើងរបស់កម្ពុជាផងដែរ។ តាមការប៉ាន់ស្មាន សេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមានប្រមាណជាង - ៣% ។ កម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ន និងធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាព ហើយបានជំរុញ និងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចភាពប្រកួតប្រជែង ព្រមទាំងការផលិត និងការប្រើប្រាស់ក្នុងស្រុក។ ”

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងសារលិខិតផ្ញើជូនជនរួមជាតិកម្ពុជា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិឆ្នាំឆ្លូវ ត្រីស័ក ព. ស. ២៥៦៥*

“ថវិកាឆ្នាំ២០២០ ត្រូវបានរៀបចំឡើងតាមគោលនយោបាយ «វិត្ថារកម្មថវិកា» ក្នុងគោលបំណងទ្រទ្រង់កំណើនសេដ្ឋកិច្ច និងការងារកែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាល ដោយរក្សាបាននូវតុល្យភាពថវិកា ក៏ដូចជាដើម្បីគោលដៅនៃការត្រៀមខ្លួន និងពង្រឹងសមត្ថភាពផ្ទៃក្នុងឱ្យបានល្អ សម្រាប់ត្រៀមទប់ទល់នឹងបញ្ហាប្រឈម និងហានិភ័យ ទាំងក្នុង និងក្រៅប្រទេស ហើយអាចប្រសិទ្ធនាមបានថាជា «ថវិកាយុទ្ធសាស្ត្រនៃការផ្ដុំកម្លាំងសរុបដើម្បីទប់ទល់នឹងបញ្ហាប្រឈម និងហានិភ័យ ទាំងក្នុង និងក្រៅប្រទេសតាមរយៈការពង្រឹងសមត្ថភាពផ្ទៃក្នុង ដោយជំរុញឱ្យបានខ្លាំងក្លានូវការកែទម្រង់ស៊ីជម្រៅ និងមុតស្រួច ដើម្បីធានាសុខសន្តិភាព ស្ថិរភាព និងចីរភាពនៃកំណើនសេដ្ឋកិច្ចសំដៅលើកម្ពស់សុខុមាលភាពជូនប្រជាជន លើមាគ៌ាឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០» ”



*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងកិច្ចប្រជុំជាមួយនឹងគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា ស្តីពី សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។ រដ្ឋសភា ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩*



“រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ ដែលជាផែនទីបង្ហាញផ្លូវដើម្បីជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។ គោលនយោបាយថ្មីនេះ នឹងជួយបង្កើនល្បឿនកំណើនសេដ្ឋកិច្ចលឿនជាងមុន ដើម្បីឱ្យព្រះរាជាណាចក្រកម្ពុជាប្រែក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្នុងនាមខ្លួនខ្ញុំផ្ទាល់«ខ្ញុំមានសេចក្តីរីករាយ ហើយចង់ឃើញយុវជនរបស់យើងចាប់ផ្តើមយកបំណិនសតវត្សរ៍ទី២១ ជាពិសេសបំណិនឌីជីថល ដើម្បីចូលរួមនូវក្នុងការកសាងសេដ្ឋកិច្ចឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។» ”

*ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ថ្លែងក្នុងសាររីដេអូ អបអរសាទរក្នុងកម្មវិធី “យុវជន២១” នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១។*



EUROPEAN UNION

“យើងទទួលស្គាល់អំពីសារៈសំខាន់នៃការកៀរគរចំណូល និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការធ្វើពិពិធកម្មចំណូលបន្ថែម ជាពិសេសនៅក្នុងកាលៈទេសៈដែលយើងគិតថានឹងមានគំនាប ឬការរួមតូចនៃចំណូលក្នុងរយៈពេលខ្លី ឬមធ្យមបន្ទាប់ពីវិបត្តិកូវីដ-១៩។ ដៃគូអភិវឌ្ឍន៍សូមកោតសរសើរចំពោះកិច្ចខិតខំរបស់រាជរដ្ឋាភិបាលក្នុងពេលបច្ចុប្បន្ននេះ ហើយក៏ពិនិត្យឃើញថា ទន្ទឹមនឹងការកៀរគរចំណូលពីប្រភពសក្តានុពលថ្មីៗ, កិច្ចខិតខំរបស់រាជរដ្ឋាភិបាលគួរតែពង្រីកមូលដ្ឋានពន្ធបន្ថែម តាមរយៈការពង្រឹងរដ្ឋបាលពន្ធ និងការបង្កើនអនុលោមភាព ព្រមទាំងការជំរុញឱ្យមានប្រសិទ្ធភាពលើការប្រមូលចំណូលបន្ថែមទៀត។ ”

*មតិរបស់ដៃគូអភិវឌ្ឍន៍ លើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២០ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។*

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ÷

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ **អ.គ.ហ.** |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង **អ.គ.ហ.** |
| មាស សុខសេនសាន | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង **អ.គ.ហ.** |
| យ៉េត វិណែល | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង **អ.គ.ហ.** |
| អ៊ុង លុយណា | អគ្គលេខាធិការរង **អ.គ.ហ.** |

## រៀបចំអត្ថបទដោយ ÷

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| រទ្ធី សត្រា | មន្ត្រីជំនាញ |
| ស៊ុន គឹមហេង | មន្ត្រីជំនាញ |

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |
| គុណ មុនីរ័ត្នភួង | មន្ត្រីជំនាញ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | មន្ត្រីជំនាញ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញជាន់ខ្ពស់ |
| រស់ ដាលីន | មន្ត្រីជំនាញ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ន | មន្ត្រីជំនាញជាន់ខ្ពស់ |
| ផែង សុខម៉ៃ | មន្ត្រីជំនាញ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីជំនាញជាន់ខ្ពស់ត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យន ម៉ាលីមឆេង | មន្ត្រីជំនាញជាន់ខ្ពស់ថវិកា |
| ឈុន ម៉ារឌី | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ជា សុខផេង | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| អ៊ុង វលក្ខទេវី | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ឡេង ចាន់ភួង | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

ការចូលរួមផ្សេងៗ÷

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានពន្ធដារ
ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល

## នវានុវត្ត និងកែសម្រួលដោយ ÷

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |
| គុណ មុនីរ័ត្នភួង | មន្ត្រីជំនាញ |

អាស័យដ្ឋានទំនាក់ទំនង÷
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ:(៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm